ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 17-Dec-2013, 13:25
CMS/CFO: Sann Rada

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចប្រជុំរៀបចំសវនាការក្នុងសំណុំរឿង០០២/០២

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៣**

**ម៉ោង ០៩: ០២នាទី**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr.Nicolas KOUMJIAN)*

លោក សេង ប៊ុនឃាង

កញ្ញា សុង ឆវ័ន្ត

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក វាំងសង់ វ៉ាយឌ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក ឃីត រេយ៍ន័រ *(Mr. Keith RAYNOR)*

លោក ឌេល លីសាក់ *(Mr.Dale LYSAK)*

**ជនជាប់ចោទ៖**

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី បេនី យេ *(Ms. Beini YE)*

លោក ឡៅ ជុនធី

លោកស្រី ជេត វណ្ណលី

លោកស្រី អេលេន័រ ហ្វែរណង់ដេស *(Ms. Eleonor FERNANDEZ)*

**ការិយាល័យរដ្ឋបាល៖**

ឯកឧត្តម ក្រាញ់ តូនី

លោក ឃ្នុត រ៉ូសាន់ហោក *(Mr. Knut ROSANDHAUG)*

លោក គង់ សុភី

**ផ្នែកគាំពារការពារក្តី៖**

លោក អ៊ីសាក់ អែនដឺលី *(Mr. Isaac ENDELEY)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី គ្រីស្តាល់ ថមសុន *(Mr. Krystal THOMPSON)*

លោក សាន់ វ៉ាដា

លោកស្រី ស្វ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ ម៉ាកឡាវែន៍ | បារាំង |
| ឯកឧត្តម ក្រាញ់ តូនី | ខ្មែរ |
| លោក ឃ្មុត រ៉ូសាន់ហោក | អង់គ្លេស |
| លោក នីកូឡាស គូមជែម | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោកស្រី បេនី យេ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក គង់ សំអុន | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |

# កិច្ចដំណើរការនីតិវិធី

[០៩:០២:២០]

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ!

បាទ យើងបន្តកិច្ចប្រជុំពិភាក្សារបស់យើងជាបន្តទៅទៀតសម្រាប់របៀបវារៈថ្ងៃនេះ ហើយនិងមុននឹងផ្តល់វេទិកាជូនទៅភាគីពាក់ព័ន្ធ សូមលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានបុគ្គល និងភាគីដែលអង្គជំនុំជម្រះបានអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចប្រជុំពិភាក្សាថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់កិច្ចប្រជុំនៅថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្តី និងបុគ្គលដែលអង្គជំនុំជម្រះបានអញ្ជើញឲ្យចូលរួមមានវត្តមាន។ លើកលែងតែលោកមេធាវី សុន អរុណ មេធាវីការពារ -- មេធាវីជាតិការពារឲ្យលោក នួន ជា អវត្តមានដោយមូលហេតុបញ្ហាសុខភាព។ ចំណែកឯលោក ខៀវ សំផន មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ ជាកិច្ចចាប់ផ្តើមនៅក្នុងកិច្ចប្រជុំពិភាក្សានេះ យើងខ្ញុំសូមប្រគល់វេទិកាជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយធ៍ ដើម្បីបន្តការតាំងសំណួរមួយចំនួនចំពោះឯកឧត្តមប្រធាន និងលោកអនុប្រធានការិយាល័យរដ្ឋបាលពាក់ព័ន្ធនឹងបញ្ហារដ្ឋបាលនៃការរៀបចំកិច្ចដំណើរការសវនាការសំណុំរឿង ០០២/០២។ សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយធ៍៖**

សូមអរគុណលោកប្រធាន។

អង្គជំនុំជម្រះយល់ឃើញថា អាចនឹងមានសារប្រយោជន៍ដើម្បីធ្វើឲ្យប្រាកដថា ខ្លួនបានយល់ច្បាស់អំពីបញ្ហាថវិកា ហើយនិងព័ត៌មានបច្ចេកទេសរហូតដល់ថ្ងៃស្អែកនោះ។ ក្នុងនាមលោកប្រធាន ខ្ញុំសូមសង្ខេបអំពីការយល់ដឹងរបស់យើងខ្ញុំនៅផ្នែកខ្លះ នូវការពិភាក្សាដ៏លម្អិតមួយចំនួនដែលយើងបានពិភាក្សាម្សិលមិញ។ បញ្ហានេះទាក់ទងទៅនឹងការផ្តល់នូវធនធានសម្រាប់អង្គជំនុំជម្រះទី២ ហើយនិង

បុគ្គលិករបស់ខ្លួន ហើយនិងនិយាយតែបុគ្គលិកបន្ថែមដែលត្រូវគាំទ្រការបង្កើតនៅអង្គជំនុំជម្រះថ្មីនោះ។ នេះជាសេចក្តីសង្ខេបដើម្បីពិនិត្យថាតើយើងយល់ច្បាស់បែបនោះដែរឬទេ។

ចំណុចទី១ តម្លៃចំណាយនៃការផ្តល់មូលនិធិទៅដល់អង្គជំនុំជម្រះទី២ ហើយនិងបុគ្គលិករបស់ខ្លួន ហើយនិងបុគ្គលិកបន្ថែមចំពោះអង្គជំនុំជម្រះបច្ចុប្បន្ន នឹងត្រូវចំណាយចេញពីមូលនិធិគ្រាអាសន្ន ហើយត្រូវគ្របដណ្តប់តែភាគីខាងអន្តរជាតិនោះទេ។ តើអ៊ីចឹងត្រូវដែរឬទេ?

[០៩:០៥:៣៦]

**លោក ឃ្នុត រ៉ូសាន់ហោក៖**

សូមអរគុណលោកស្រីចៅក្រម ខ្ញុំនឹងឆ្លើយក្នុងនាមសហភាគី ហើយសម្រាប់គោលបំណងនានា គឺថាសំណើមកដល់មុន យើងដោះស្រាយមុន។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

អ៊ីចឹងរាប់បញ្ចូលទាំងអង្គចៅក្រមថ្មីនៅក្នុងអង្គជំនុំជម្រះទី២ ចៅក្រមជាតិ ហើយនិងបុគ្គលិកផងដែរ។ អ៊ីចឹងជាសក្តានុពល?

**លោក ឃ្នុត រ៉ូសាន់ហោក៖**

គឺអ៊ីចឹងហើយ។ គឺអាចនឹងចេញអំពីមូលនិធិគ្រាអាសន្ននេះ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

អ៊ីចឹងនៅក្នុងផ្នែកមូលនិធីគ្រាបន្ទាន់នេះគឺស្ថិតនៅក្នុងថវិកាត្រូវបានដាក់បញ្ជូនទៅក្រុមម្ចាស់ជំនួយសំខាន់ៗរួចហើយ។ ប៉ុន្តែមិនទាន់បានផ្តល់ការអនុម័តឯកភាពទេ។ តើអ៊ីចឹងដែរឬទេ?

[០៩:០៦:៣៧]

**លោក ឃ្នុត រ៉ូសាន់ហោក៖**

បាទត្រឹមត្រូវ គឺថវិកាមិនទាន់ត្រូវបានអនុម័តទេ ប៉ុន្តែការប្រជុំ និងពិនិត្យមើលការចែងចំណុចផ្សេងៗ ហើយនិងរង់ចាំមើលថាតើមានសំណើអ្វីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ គេនឹងសម្រេចតាមនោះ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

ចំណុចថវិកាគ្រាអាសន្ននេះ គឺផ្នែកនៃថវិកាដែលនឹងត្រូវអនុម័តនៅក្នុងអនាគតដែលយើងមិនកំណត់បាន។ អ៊ីចឹងគឺថាអាចនឹងក្នុងខែកុម្ភៈ ឆ្នាំ២០១៤។ តើការយល់អ៊ីចឹងត្រឹមត្រូវឬទេ?

**លោក ឃ្លុត វ៉ូសាន់ហោក៖**

ត្រឹមត្រូវហើយ ដោយសារថវិកាចុងក្រោយរបស់យើងហ្នឹង គឺត្រូវបានអនុម័តក្នុងខែកុម្ភៈ កាលឆ្នាំមុននោះ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ហើយបើសិនជាម្ចាស់ជំនួយសំខាន់ៗអាចនឹងគាំទ្រ និង\ឬ បុគ្គលិករបស់ខ្លួនទៅតាមការណែនាំរបស់លោកប្រធាន ប៉ុន្តែផ្ទុយទៅវិញ គឺត្រូវតែមានថវិកា មានលុយដើម្បីធ្វើការងារនោះ។ តើខ្ញុំនិយាយបែបនេះត្រូវដែរឬទេ ថាយើងមិនទំនងឃើញថាជាសាច់ប្រាក់នោះនឹងមានមុនខែកុម្ភៈ។ ជាពិសេសគឺថាប្រហែលជាឆ្នាំ២០១៤ ខែកុម្ភៈនោះ?

**លោក ឃ្លុត វ៉ូសាន់ហោក៖**

ថវិកា លុយ នឹងត្រូវរៀបចំឲ្យមាន គឺថានៅពេលដែលម្ចាស់ជំនួយសំខាន់ៗចេញសេចក្ដីសម្រេចដើម្បីគាំទ្រ ហើយសាច់ប្រាក់ដែលនឹងយកមកប្រើ គឺនឹងយកចេញមកពីសាច់ប្រាក់ដែលមាននៅក្នុងដៃ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

អ៊ីចឹងយើងមិនទំនងថាអាចជាសេចក្ដីសម្រេចឆាប់ៗដើម្បីផ្ដល់មូលនិធិនោះទេ ដោយសារថាមានស្មុគស្មាញក្នុងការសម្រេចរបស់សហគមន៍ម្ចាស់ជំនួយនៅក្នុងឆ្នាំនេះទេ។ ជាពិសេសទៅទៀតពេលវេលាហ្នឹងគឺថាដើម្បីឲ្យគណៈកម្មការនោះគឺថាវាយតម្លៃចំណាយ ហើយនិងមូលនិធិ ឬក៏សាច់ប្រាក់ដែលនឹងត្រូវមកពីណា។ អ៊ីចឹងដែរឬទេ?

[០៩:០៨:៥៤]

**លោក ឃ្លុត វ៉ូសាន់ហោក៖**

បញ្ហាសាច់ប្រាក់ហ្នឹងគឺថាចេញពីគណនីរបស់ យូ.អិន អង្គការសហប្រជាជាតិមិនចោទទេ។ ប៉ុន្តែចំពោះការគាំទ្រសំណើនោះទាល់តែមានសំណើសិនដើម្បីគេអាចនឹងធ្វើសេចក្ដីសម្រេច បើសិនយើងរង់ចាំដល់ថ្ងៃ២៤ ខែធ្នូ គឺថាអាចនឹងជាករណីដែលយឺតបន្តិច។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ហើយសំណើហ្នឹងគប្បីដាក់បញ្ចូលមូលនិធិសម្រាប់អន្តរជាតិ ហើយនិងជាតិផងដែរនៅក្នុងអង្គជំនុំជម្រះរបស់អង្គជំនុំជម្រះនោះ។ ប្រសិនបើម្ចាស់ជំនួយសំខាន់ៗធ្វើសេចក្ដីសម្រេចផ្ដល់មូលនិធិលើអង្គជំនុំជម្រះទី២នោះ ហើយបើមានការប្រជុំបែបនោះ តើសម្រេចទាន់ពេលទេ?

**លោក ឃ្នុត រ៉ូសាន់ហោក៖**

គឺថាម្ចាស់ជំនួយសំខាន់ៗ គឺថានឹងត្រូវពិភាក្សាដោះស្រាយបញ្ហាទាំងពីរភាគី។ ខ្ញុំមិនដឹងថាតើសេចក្ដីសម្រេចចុងក្រោយរបស់ម្ចាស់ជំនួយសំខាន់ៗនៅពេលណាទេ ខ្ញុំមិនអាចនិយាយស្មានជាមុនទេ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

រហូតដល់ពេលដែលថាថវិកាត្រូវបានអនុម័ត និយាយអំពីការជ្រើសតាំងបុគ្គលិក ហើយចៅក្រមផ្សេងៗហ្នឹងត្រូវតែចប់ជាមុនទេ?

**លោក ឃ្នុត រ៉ូសាន់ហោក៖**

ពិតហើយ ត្រឹមត្រូវ។ គឺថាយើងត្រូវតែមានដំណើរការចាប់ផ្ដើម ដើម្បីមានការឯកភាពពីម្ចាស់ជំនួយសំខាន់ៗ។

[០៩:១០:២៣]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ដូច្នេះ ប្រសិនបើសេចក្ដីសម្រេចមិនត្រូវបានធ្វើឡើងរហូតដល់ឆ្នាំថ្មី ឧទាហរណ៍ថាត្រឹមខែកញ្ញាដោយសារតែអាស្រ័យទៅលើតែម្ចាស់ជំនួយសំខាន់ៗ។ ការជួលបុគ្គលិកមិនអាចចាប់ផ្ដើមទេរហូតទាល់តែមូលនិធិ ឬក៏ថវិកានោះ ត្រូវបានសន្យា។ បើថាមិនទាន់លុយចូលដល់ធនាគារហ្នឹងក៏ដោយ ទាល់តែមានការឯកភាព។

**លោក ឃ្នុត រ៉ូសាន់ហោក៖**

ដោយមានការធ្វើសេចក្ដីសម្រេចហើយ ការជ្រើសរើសអាចចាប់ផ្ដើមបាន។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ប៉ុន្តែការដាក់បុគ្គលិកឲ្យធ្វើការសម្រាប់អង្គជំនុំជម្រះទី២ហ្នឹង មិនអាចកើតបានទេ រហូតទាល់តែមានលុយនៅក្នុងធនាគារសិន។ តើអ៊ីចឹងដែរឬទេ?

**លោក ឃ្នុត រ៉ូសាន់ហោក៖**

មិនដូច្នោះទេ។ ការចាត់បុគ្គលិកឲ្យមកធ្វើនោះគឺចាប់ផ្ដើមពីកាលបរិច្ឆេទនៃការធ្វើសេចក្ដីសម្រេចនោះ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

អ៊ីចឹងនិយាយដោយសង្ខេប នៅពេលដែលប្រធានធ្វើសេចក្ដីសម្រេច ដែលថាអាចនឹងដាក់បុគ្គលិក

ឲ្យធ្វើការនៅក្នុងអង្គជំនុំជម្រះទី២ ហើយតែងតាំងចៅក្រម ហើយបុគ្គលិកក៏ត្រូវមានដែរ។

**លោក ឃ្លុត វ៉ូសាន់ហោក៖**

នេះហើយដែលខ្ញុំនិយាយថា គឺថាត្រូវមានការយល់ព្រមពីក្រុមម្ចាស់ជំនួយ។

[០៩:១១:៤៨]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

លោកនិយាយថា គេត្រូវតែធ្វើសេចក្តីសម្រេចបន្ទាប់ពីមានការសម្រាកបុណ្យនូអែល ញូវយ៉ក។

**លោក ឃ្លុត វ៉ូសាន់ហោក៖**

គេបានបញ្ជាក់ថា គេនឹងយកសំណើនេះជាអាទិភាពខ្ពស់របស់ពួកគេ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

លោកនិយាយពីម្សិលមិញថា ពេលវេលាដែលត្រូវការដើម្បីផ្តល់បុគ្គលិកនោះ គឺអាចនឹងត្រូវប្រើពេលប៉ុន្មានសប្តាហ៍ឯណោះ។ នេះជាបទពិសោធន៍របស់អង្គជំនុំជម្រះនេះ ហើយនិងអង្គជំនុំជម្រះផ្សេងទៀត គឺថាពាក្យថាពីរបីសប្តាហ៍នោះ គឺថាអាចនឹងនៅក្នុងកម្រិតយ៉ាងហោចណាស់ក៏ពីរខែដែរ។ តើលោកទទួលស្គាល់ថាអ៊ីចឹងដែរឬទេ?

**លោក ឃ្លុត វ៉ូសាន់ហោក៖**

ខ្ញុំមិនមានបញ្ហាទេ ខ្ញុំទទួលស្គាល់ថាអ៊ីចឹង។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

តើនៅក្នុងទាក់ទងទៅនឹងមន្ត្រី ដូចជាចៅក្រមរបស់អង្គជំនុំជម្រះ តើអាចនឹងប្រើពេលយូរជាងហ្នឹងទេ ដោយហេតុថាគេនឹងរៀបចំខ្លួនដើម្បីមកធ្វើការមុនហ្នឹង។ តើអ៊ីចឹងត្រឹមត្រូវដែរឬទេ?

[០៩:១២:៥៣]

**លោក ឃ្លុត វ៉ូសាន់ហោក៖**

នោះក៏អាចនឹងត្រឹមត្រូវ នៅពេលដែលអ្នកទាំងនោះ មកពីក្រៅ អ.វ.ត.ក។ ប៉ុន្តែបើចៅក្រមស្ថិតនៅក្នុង អ.វ.ត.ក អាចនឹងខ្លីជាងហ្នឹង បាទ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ពេលនោះ គឺថាឧត្តមប្រឹក្សានៃអង្គចៅក្រម បើសិនជាចៅក្រមមិនទាន់បានផ្តល់ការយល់ព្រមទេ គេនឹងត្រូវធ្វើសេចក្តីសម្រេចលើហ្នឹងទៀត ហើយនិងប្រើពេលបន្ថែមទៀត បើក្នុងករណីនោះ។

**លោក ឃ្លុត វ៉ូសាន់ហោក៖**

បាទ គឺត្រូវបែបនោះមែន។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

យើងនឹងប្រើឧទាហរណ៍នៃការផ្តល់ការឯកភាព ដូចជាសហព្រះរាជអាជ្ញារងអន្តរជាតិ។ ថាតើលោកបានប្រើពេលប៉ុន្មាន ដើម្បីឲ្យឧត្តមប្រឹក្សានៃអង្គចៅក្រមផ្តល់ការយល់ព្រមដល់ការតែងតាំងនោះ ដែលប្រកាសក្នុងសារព័ត៌មានពីម្សិលមិញនោះ?

**ឯកឧត្តម ក្រាញ់ តូនី៖**

បាទ លោកស្រីចៅក្រម តាមខ្ញុំនៅចាំ គឺដូចខ្ញុំបានជម្រាបជូនហើយ ថានៅក្រោមមួយខែ បាទ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

នោះគឺពេលប្រើពេលក្នុងករណីតែមួយហ្នឹង ឬក៏ប៉ាន់ប្រមាណរបស់ឯកឧត្តម ដែលថាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងប្រើពេលអ៊ីចឹងដែរឬទេក្នុងអនាគតនោះ?

**ឯកឧត្តម ក្រាញ់ តូនី៖**

បាទ តាមទម្លាប់ យើងធ្លាប់ធ្វើការងារនេះជាពីរបីដងហើយ។ មួយខែនេះ ខ្ញុំយកមធ្យមភាគដែលខ្ពស់ជាងគេ មានខ្លះបីអាទិត្យ ខ្លះពីរអាទិត្យ ខ្លះមួយខែ។ នេះជាការបទពិសោធន៍កន្លងទៅ។

[០៩:១៤:៥២]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ខ្ញុំនឹងនិយាយសង្ខេបៗអំពីដំណើរការនៃការស្វែងរកឧបត្ថម្ភថវិកា។ នៅក្នុងសេចក្តីសង្ខេបរបស់ខ្ញុំហ្នឹង គឺបច្ចុប្បន្ននេះ គឺថាដំណើរការនៃការប្រាក់ឧបត្ថម្ភធននោះគឺថាត្រូវបានអនុម័តដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ គឺនឹងផ្តល់ថវិកាសម្រាប់២០១៤។ សម្រាប់ភាគីខាងអន្តរជាតិ ជាសក្តានុពលនោះគឺថ្នាក់ខាងជាតិដែរ ដកចេញតែចៅក្រមនោះទេ។ លើកលែងតែមានការឯកភាពពីគណៈកម្មាធិការទី៥ ដើម្បីបញ្ចូលមន្ត្រីដូចជាចៅក្រមទៅក្នុងកញ្ចប់នោះ។

**លោក ឃ្លុត វ៉ូសាន់ហោក៖**

ចម្លើយគឺអនុលោមទៅតាមលក្ខខណ្ឌ ហើយនិងការសម្រេចរបស់គណៈកម្មាធិការទី៥។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

អំពីប្រាក់ឧបត្ថម្ភធននោះ គឺថាមិនតម្រូវឲ្យមានការព្រមព្រៀង ហើយជាពិសេសការខកខានមិន

បានជំទាស់របស់សមាជិកទាំងអស់នៃមហាសន្និបាតហ្នឹង អាចនឹងថាយល់ព្រម?

[០៩:១៦:០៩]

**លោក ឃ្មុត រ៉ូសាន់ហោក៖**

បាទ គឺសមាជិកជារដ្ឋទាំងអស់គឺមានតំណាងនៅក្នុងមហាសន្និបាត។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

អ៊ីចឹងសេចក្ដីសម្រេចគឺថាមិនត្រូវរង់ចាំដល់មានការកោះប្រជុំទី២ទៀតរបស់មហាសន្និបាតនៅឆ្នាំក្រោយ?

**លោក ឃ្មុត រ៉ូសាន់ហោក៖**

បាទ គឺត្រឹមត្រូវមែនហើយ គឺគេត្រូវសម្រេចនឹងយល់ព្រមឲ្យមានលទ្ធផលនៅក្នុងខែធ្នូ ឆ្នាំនេះ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអរញ្ជើញលោកស្រី -- សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ បាទ ជម្រាបសួរអស់លោក លោកស្រីទាំងអស់គ្នា។ បាទ ខ្ញុំមានសំណួរបន្តមួយចំនួន។ ជាបឋម យើងបានយល់អ្វីដែលលោកនិយាយកាលពីព្រឹកនេះៗ គឺថាក្រុមអ្នកជំនួយបានបង្ហាញថាពួកគេចាប់អារម្មណ៍នឹងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២ ហើយនិងចាំទទួលសំណើហ្នឹង។ តើមានព័ត៌មានជាក់លាក់ណាដែលត្រូវបានផ្ដល់ទៅក្រុមអ្នកជំនួយចម្បងៗហ្នឹង? ហើយអ្នកណាអ្នកផ្ដល់ព័ត៌មានទាំងអស់ហ្នឹង? គឺថារហូតដល់ពេលនេះមិនទាន់មានតួលេខណាបានបង្ហាញឲ្យជាក់លាក់ទេ។

**លោក ឃ្មុត រ៉ូសាន់ហោក៖**

និយាយពីពាក្យបច្ចេកទេស គឺថាម្ចាស់ជំនួយៗសំខាន់ៗគឺថាមិនចាប់អារម្មណ៍នូវការបង្កើតអង្គ-ជំនុំជម្រះទី២ទេ។ នៅក្នុងការពិភាក្សាជាសាធារណៈរបស់គេៗ -- ជាពិសេស គេបានពិនិត្យមើលគំនិតដែលនិយាយនៅក្នុងសេចក្ដីសម្រេចរបស់តុលាការកំពូលដែរ។ ខ្ញុំបានជម្រាបពួកគេឲ្យចាប់អារម្មណ៍គឺថានៅក្នុងពេលដែលពួកគេពិភាក្សា ខ្ញុំបានសួរពួកគេ ឲ្យពួកគេត្រៀមខ្លួនដើម្បីធ្វើសេចក្ដីសម្រេចក្នុងករណីចាំបាច់នោះ។ ហើយពួកគេបានរៀបចំខ្លួនដោយស្ថិតនៅក្នុងជាមូលដ្ឋានអត្ថិភាពរបស់ពួកគេ។ ពីរសំណួររបស់លោកចៅក្រមពីម្សិលមិញ គឺថាមិនទាន់មានការប្រមាណតម្លៃចំណាយទេ គឺត្រឹមត្រូវ

ហើយ ប៉ុន្តែខ្ញុំបានធ្វើកម្មវិធីប្រាក់ចំណាយ គឺថាផ្អែកលើសំណួរម្សិលមិញ ខ្ញុំត្រៀមខ្លួននឹងជម្រាបជូននៅថ្ងៃនេះ។

អង្គជំនុំជម្រះបច្ចុប្បន្ន គឺថាដោយមានបុគ្គលិកបច្ចុប្បន្ននេះ គឺមានថវិកា១,១លានសម្រាប់បុគ្គលិកហើយនិង ៦៤.០០០ *(ស៊ីក)* សម្រាប់ចៅក្រមអន្តរជាតិ ហើយចំពោះចៅក្រមជាតិគឺ ១៥.០០០ នេះប្រចាំខែទេ ខ្ញុំនឹងពិនិត្យម្តងទៀត។ នេះជាថវិកាប្រចាំឆ្នាំសម្រាប់ យូ.អិន។ ជាអកុសល ខ្ញុំមានកំណត់ជាប្រចាំខែទេសម្រាប់ជាតិនោះ។ គឺ១,៨លានក្នុងមួយឆ្នាំចំពោះភាគីអន្តរជាតិនៃអង្គជំនុំជម្រះសាលាដំបូង, ហើយចំនួនសម្រាប់ខាងជាតិវិញគឺថា ៧៧.០០០ *(ស៊ីក)* ក្នុងរយៈពេលប្រចាំខែ។ ដូច្នេះ ផ្នែកដែលត្រូវគ្នានោះគឺអាចនឹងប្រាំមួយខែ។ ខ្ញុំយល់ថាសាលក្រមនៅក្នុងដំណាក់កាលទី១ គឺថានឹងត្រូវចេញត្រីមាសទី២នៃខែក្រោយ គឺថាយើងនឹងប្រើពេលប្រាំមួយខែ ពីមករា ដល់ខែមិថុនា។ យើងអាចធ្វើការគណនាផ្អែកទៅតាមកាលវេលានេះ។ ដោយថានៅខាងអន្តរជាតិដែលថាចៅក្រម ហើយនិងបុគ្គលិក មានបុគ្គលិកស្មើគ្នាគឺថាអាចនឹងប្រហាក់ប្រហែលជា១លានដុល្លារ។ ហើយចំពោះជាតិសម្រាប់រយៈពេលនេះគឺថាអាចនឹង ២២៥.០០០ ក្នុងមួយខែ។

[០៩:២០:៥៣]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ ខ្ញុំយល់ថាក្រុមប្រទេសផ្តល់ជំនួយសំខាន់ៗហើយនិងគោល ដែលគេចាប់អារម្មណ៍ដោយសារលោកបាននិយាយពីបញ្ហានេះ។ ម្សិលមិញយើងបានឮព័ត៌មានមួយចំនួន។ ខ្ញុំគិតថា ការបង្កើតទៅក្រុមប្រឹក្សាទី២ នេះត្រូវបានបង្ហាញជូនហើយដោយមានគំនិតថា ប្រហែលជាអាចចំណេញពេលវេលាអាចកាត់ក្តីបានលឿនជាងហ្នឹង ហើយនិងវានឹងអាចចំណេញទាក់ទងទៅនឹងការចំណាយរបស់តុលាការយើងនេះ។ ក៏ប៉ុន្តែមានព័ត៌មានមួយចំនួនអាចឲ្យយើងពិភាក្សាវែកញែកបានទៅលើការសន្និដ្ឋានបែបនេះ ម្សិលមិញសហព្រះរាជអាជ្ញាអន្តរជាតិបាននិយាយថា ប្រសិនបើមានការបង្កើតក្រុមជំនុំជម្រះទី២ និងត្រូវបានតែងតាំងនោះនឹងធ្វើឲ្យមានការកែប្រែឡើងវិញជាច្រើនទៅលើរយៈពេលកាត់ក្តី។ នេះគឺជាបញ្ហាមួយ។ ប៉ុន្តែអ្វីដែលខ្ញុំចង់ដឹងដោយហេតុថា លោកជាអ្នកផ្តល់ព័ត៌មាននេះទៅឲ្យគេតើពេលដែលប្រជុំចប់នេះហើយលោកអាចផ្តល់ព័ត៌មានបន្ថែមទៅក្រុមប្រទេសផ្តល់ជំនួយសំខាន់នេះទេ? តើលោកនឹងធ្វើការប្រជុំជាមួយគាត់ឆាប់ៗនេះ តើប្រទេសទាំងអស់នេះគេនឹងទទួលបានព័ត៌មានដែលចេញពីការប្រជុំយើងថ្ងៃនេះយ៉ាងម៉េចដែរ?

**លោក ឃ្មុត រ៉ូសាន់ហោក៖**

ខ្ញុំបានយល់ថា សហព្រះរាជអាជ្ញាបានស្នើឲ្យអង្គជំនុំជម្រះបច្ចុប្បន្ននឹងបន្តហើយក្នុង -- បើសិនជាមានការចាំបាច់ត្រូវបន្ថែមបុគ្គលិកគឺអាចបន្ថែម។ ប៉ុន្តែផ្នែកទី២នៃសំណួររបស់ចៅក្រមខ្ញុំបានពិភាក្សាជាមួយក្រុមម្ចាស់ជំនួយសំខាន់ៗ នៅញូវយ៉កគឺថាតាមមូលដ្ឋានទៀងទាត់ ហើយដែលហៅថា *"ដេសា"* នោះគឺគណៈកម្មការកិច្ចការសេដ្ឋកិច្ច ហើយនិងលោក ដេវីឌ សេហ្វហ្វើ ជាតំណាងក្នុងកិច្ចការនេះគឺថាអាចជាអ្នកផ្លោះប្តូរព័ត៌មានហើយខ្ញុំមានការពិភាក្សាជាទៀតទាត់ជាមួយម្ចាស់ជំនួយអំពីដំណើរការប្រព្រឹត្តទៅរបស់តុលាការជាទៀងទាត់។

[០៩:២៣:៣៦]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បើអ៊ីចឹងគឺថាទៅតាមរយៈលោក ដេវីដ សេហ្វហ្វើ នេះហើយដែលប្រទេសផ្តល់ជំនួយសំខាន់ៗហ្នឹងទទួលបានពីព័ត៌មានទាក់ទងនឹងការបង្កើតក្រុមប្រឹក្សាទី២នេះ បើសិនខ្ញុំមិនច្រឡំទេ ប្រទេសផ្តល់ជំនួយសំខាន់ៗទាំងអស់នេះបានសុំឲ្យលោកកាត់បន្ថយថវិកាដែលលោកបានបង្ហាញ ខ្ញុំមិនច្រឡំទេ គឺថាបានកាត់បន្ថយ ២លានដុល្លារឯណោះ។ តើអ៊ីចឹងមែនទេ?

**លោក ឃ្មុត រ៉ូសាន់ហោក៖**

លោក ដេវីដ សេហ្វហ្វើ គឺថាជាប្រភពមួយចំនួនក្នុងប្រភពដែលម្ចាស់ជំនួយគេចង់បានព័ត៌មានហ្នឹង។ គាត់មិនមែនជាបុគ្គលតែម្នាក់ដែលបញ្ជូនព័ត៌មានពីខ្ញុំទៅម្ចាស់ជំនួយនោះទេ គឺថាគេមានប្រភពមួយចំនួនទៀតគឺថាមានការិយាល័យទទួលបន្ទុកខាងសេដ្ឋកិច្ចរបស់ យូ.អិន ហ្នឹងដែរ។ គឺថាគេមានការពិភាក្សានោះគឺមិនភ្ជាប់ទៅនឹងដំណើរការថវិកាទេ ដូចដែលខ្ញុំនិយាយម្សិលមិញអ៊ីចឹង គឺថាថវិកានោះ គឺដាច់ដោយឡែកអំពីការបង្កើតនៃអង្គជំនុំជម្រះទី២ ហើយគេៗបានស្នើឲ្យយើងខ្ញុំកំណត់ថ្លៃចំណាយធ្វើម៉េចឲ្យចំណាយមានប្រសិទ្ធភាពរបស់តុលាការ។ គំនិតនេះផ្តួចផ្តើមមកដល់យើងតាំងពីឆ្នាំ២០០៦។ រីឯអង្គជំនុំជម្រះទី២ មិនត្រូវបានលើកមកពិភាក្សានៅក្នុងកិច្ចប្រជុំម្ចាស់ជំនួយនោះទេ។ បាទ ដូចដែលខ្ញុំជម្រាប គឺថាយើងបានជូនដំណឹងអំពីថាមានការពិភាក្សានៅក្នុងតុលាការ។ ខ្ញុំបានជម្រាបពួកគេហើយដើម្បីឲ្យពួកគេបានព័ត៌មាន ដើម្បីឲ្យគេត្រៀមខ្លួនធ្វើសេចក្តីសម្រេចបត់បែនឆាប់ៗនៅពេលដែលយើងត្រូវការអង្គជំនុំជម្រះទី២ នោះបាទ។

[០៩:២៥:៥១]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ សូមអរគុណ។ អ៊ីចឹងខ្ញុំសន្មតថាចំពោះប្រទេសផ្តល់ជំនួយទាំងអស់នោះ គឺថាការផ្តល់ជំនួយនេះជាតម្លៃនៃការបង្កើតក្រុមប្រឹក្សាទី២ នេះគឺសំខាន់ណាស់។ ឥឡូវខ្ញុំសូមចូលប្រធានបទថ្មី។ ដោយសារយើងនិយាយពីថវិកា ខ្ញុំសូមត្រឡប់ចូលមកនិយាយអំពីបញ្ហាផ្តល់ប្រាក់ឧបត្ថម្ភធន។ បាទ លោកនិយាយពីការប្រមូលមូលនិធិ ហើយយើងបាននិយាយពីបញ្ហានេះក្រោមទ្រង់ទ្រាយផ្សេងៗ។ បើសិនជាសំណើសុំឧបត្ថម្ភប្រាក់ធននេះត្រូវបានអនុម័តការចំណាយហ្នឹងនឹងជាបន្ទុកនៃថវិការួមនៃអង្គការសហប្រជាជាតិ។ ដើម្បីឲ្យប្រាក់ឧបត្ថម្ភធនត្រូវបានអនុម័ត តើជាការត្រឹមត្រូវដែរឬទេ ដែលថាប្រទេសជាសមាជិកនៃអង្គការសហប្រជាជាតិទាំងអស់នេះត្រូវតែផ្តល់ការអនុញ្ញាត ឬក៏យល់ព្រម ឬក៏ជាការចាំបាច់ដែរឬទេ ដែលថាត្រូវតែមានសេចក្តីសម្រេចជាឯកឆន្ទនៃសមាជិកអង្គការសហប្រជាជាតិនៅក្នុងមហាសន្និបាត ដើម្បីផ្តល់ប្រាក់ឧបត្ថម្ភធននេះ?

[០៩:២៧:១៤]

**លោក ឃ្លុត រ៉ូសាន់ហោក៖**

នៅក្នុងចំណុច គឺថាមានការ -- ប៉ុន្តែនៅក្នុងនោះក៏យើងពន្លឿននីតិវិធីដែរ គឺដើម្បីឲ្យគេគាំទ្រនូវកិច្ចព្រមព្រៀងណា -- កិច្ច -- គំនិតចាប់ផ្តើមណាដើម្បីពន្លឿននីតិវិធី។ បាទ ដូច្នេះយើងនឹងគិតពីបញ្ហានេះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

អ៊ីចឹង គឺថាសេចក្តីសម្រេចហ្នឹងត្រូវមានសំឡេងភាគច្រើនទេ នៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិហ្នឹង។ អ៊ីចឹងមែនទេ?

**លោក ឃ្លុត រ៉ូសាន់ហោក៖**

បាទ នៅក្នុងគណៈកម្មាធិការទី៥ យើងមិននិយាយអំពីអ្នកបោះឆ្នោត១៩៣នោះទេ។ គឺកម្រិតត្រឹមតែគណៈកម្មាធិការទី៥ ដែលត្រូវបោះឆ្នោតលើ -- បាទ ជាគណៈកម្មាធិការចុងក្រោយដែលថាមានតំណាងនៅក្នុងអង្គភាពតូចនេះ។ គឺមានការបោះឆ្នោតនៅទីនោះ ដំណើរការនៅគឺបញ្ចប់ហើយ គឺថាមិនមែនមានន័យថារដ្ឋមួយគឺថាអាចនឹងមានសិទ្ធិវេតូ ទល់នឹង១៩៣ ផ្សេងទៀតនោះទេ។ វាអាចខុសពីហ្នឹងបាទ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ហើយសេចក្ដីសម្រេចនៅក្នុងគណៈកម្មាធិការទី៥នេះ គឺជាសេចក្ដីសម្រេចដែលត្រូវធ្វើជាឯកឆន្ទ ឬក៏គ្រាន់តែសំឡេងភាគច្រើនជាការគ្រប់គ្រាន់?

[០៩:២៨:៥៩]

**លោក ឃ្នុត វ៉ូសាន់ហោក៖**

ខ្ញុំជឿថា គឺថាសំឡេងបោះឆ្នោតភាគច្រើន។ បាទ នេះជាសំណួរបច្ចេកទេសពេកហើយ ខ្ញុំពិបាកនឹងឆ្លើយ ហើយខ្ញុំនឹងត្រូវស្រាវជ្រាវបន្តិច បើខ្ញុំឆ្លើយទៅល្អៀង ខ្ញុំនឹងរក្សាសិទ្ធិ និងកែតម្រូវនៅពេលក្រោយបាទ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយជាបន្តទៅនេះ ខ្ញុំសូមផ្ដល់វេទិកាជូនទៅបណ្ដាភាគីនានានៃរឿងក្ដីអាចសួរបន្ថែមទៅលើបញ្ហាទាំងឡាយដែលពាក់ព័ន្ធទៅនឹងរបៀបវារៈទី២នេះ។ គឺបែបបទរដ្ឋសម្រាប់ការរៀបចំសវនាការលើសំណុំរឿង ០០២/០២ ដែលបានជជែកពិភាក្សាកាលពីរសៀលម្សិលមិញ ហើយនិងការសាកសួរបន្ថែមដោយចៅក្រមអន្តរជាតិ ចំពោះឯកឧត្ដមប្រធាន និងលោកអនុប្រធានការិយាល័យរដ្ឋបាល។

ហើយជាដំបូងនេះ ផ្ដល់វេទិកាជូនទៅសហព្រះរាជអាជ្ញាមុនភាគីដទៃទៀតនៃរឿងក្ដី ប្រសិនបើសហព្រះរាជអាជ្ញាមានបំណងចង់សាកសួរសំណួរពាក់ព័ន្ធនឹងបញ្ហានេះ ចំពោះឯកឧត្ដមប្រធាន និងលោកអនុប្រធានការិយាល័យរដ្ឋបាល។ សូមអញ្ជើញ!

[០៩:៣០:១៤]

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន អរុណសួស្ដីលោក លោកស្រីចៅក្រម ភាគីទាំងអស់។ លោកស្រីជាលាង មិនមានវត្តមានចូលរួមនៅក្នុងពេលនេះទេ ដោយសារគាត់ជាប់រវល់ ប៉ុន្តែផ្ដាំឲ្យខ្ញុំនេះសួរសំណួរទៅកាន់ប្រធានរដ្ឋបាលស្ដីទី។ លោកស្រីបានបញ្ជាក់ប្រាប់ខ្ញុំថា ផ្អែកទៅលើដំណើរការថវិកានេះ គាត់នឹងបានកាត់បុគ្គលិកពីរនាក់សម្រាប់ឆ្នាំ២០១៤។ ហើយនៅពេលបច្ចុប្បន្ននេះបានទទួលសំណើពីរដ្ឋបាល

សូមឲ្យកាត់បុគ្គលិកជាតិម្នាក់ទៀត។ ដោយសារតម្រូវរបស់សហព្រះរាជអាជ្ញានៅក្នុងឆ្នាំក្រោយ បានន័យថានឹងមានបណ្ដឹងសាទុក្ខទៅលើសំណុំរឿង០០២/០១ យើងសង្ឃឹមថានៅពេលចាប់ផ្ដើមសំណុំរឿង ០០២/០២ ហើយនិងនៅពេលដែលយើងរំពឹងថានឹងមានសេចក្ដីសន្និដ្ឋាននៅសំណុំរឿង ០០៣ និង០០៤ ទៀត ថាតើនៅក្នុងកញ្ចប់ថវិកាសង្គ្រោះបន្ទាន់នេះមានកញ្ចប់ថវិកាហ្នឹងដែលមានលុយសម្រាប់ជួលបុគ្គលិកបន្ថែមដើម្បីបំពេញការងាររបស់យើងពាក់ព័ន្ធទៅនឹងការងារដូចដែលខ្ញុំរៀបរាប់នេះដែរឬទេ?

**ឯកឧត្ដម ក្រាញ់ តូនី៖**

បាទសូមគោរពអង្គប្រជុំជាថ្មីម្ដងទៀត។ ពាក់ព័ន្ធលើបញ្ហានេះ អ្វីដែលក្នុងក្របខ័ណ្ឌដែលយើងធ្វើឲ្យរដ្ឋបាលយើងមានសុក្រិត្យភាពជាងមុននោះ វាមានប៉ុស្ដិ៍មួយចំនួនដែលមិនត្រូវបានបន្តនៅគ្រប់ការិយាល័យ។ ហើយអ្វីដែលយើងបានធ្វើហ្នឹងអាចថា -- និយាយជាខ្លីទៅមានកាត់ប៉ុស្ដិ៍មួយចំនួនហ្នឹងក៏យើងបានធ្វើដោយមានការពិគ្រោះយោបល់លើការឯកភាពជាមុនជាមួយការិយាល័យពាក់ព័ន្ធ។

បាទ ចំពោះបញ្ហានេះ អ្វីដែលសម្រាប់២០១៣នេះគឺវាចប់រួចទៅហើយ។ កញ្ចប់២០១៤-២០១៥ហ្នឹង ដែលគេហៅថាកញ្ចប់ ជី.ធី.អេ – កញ្ចប់ដែលសម្រាប់មិនមែនជាបុគ្គលិកនោះ -- កញ្ចប់លុយមិនមែនជាបុគ្គលិកហ្នឹងដើម្បីបម្រើមកសកម្មភាពដែលយើងមិនអាច មិនមានបានគិតមុននៅក្នុងគម្រោងសកម្មភាព២០១៤-២១០៥ហ្នឹង យើងអាចយកមកចែកបាន យោងទៅតាមសកម្មភាពជាក់ស្ដែងនៅ២០១៤ ក្នុងក្របខ័ណ្ឌនូវអ្វីដែលយើងហៅថាការកែសម្រួលថវិការៀងរាល់ឆ្នាំ។

[០៩:៣៣:០៥]

**លោក នីកូឡាស គូមជែន៖**

ដើម្បីសួរបន្តទៅនឹងសំណួររបស់លោកស្រីបន្ថែមទៀត ខ្ញុំមានសំណួរបន្តពីសំណួរលោកស្រីចៅក្រម ខាតរ៉ាយច៍។ សំណួរនេះគឺថាតើបុគ្គលិកបន្ថែម ប្រសិនបើសហចៅក្រមអន្តរជាតិ ឬក៏ចៅក្រមខាងជាតិហ្នឹងត្រូវការបុគ្គលិកបន្ថែម ហើយខ្ញុំសួរថាតើគេអាចយកកញ្ចប់ថវិកា*ខន់ធិនជេនស៊ី* នេះ យកមកប្រើប្រាស់សម្រាប់ជាតិបានដែរឬទេ? ហើយខ្ញុំដឹងថាសម្រាប់ផ្នែកជាតិនោះ គឺថាគេប្រើឈ្មោះផ្សេងដែលថា ជី.ធី.អេ។ ដូច្នេះ ខ្ញុំសូមសួរតើកញ្ចប់ថវិកាសង្គ្រោះសម្រាប់អន្តរជាតិអាចយកមកប្រើប្រាស់សម្រាប់ចាយទៅលើបុគ្គលិកជាតិនៅអង្គជំនុំជម្រះសាលាដំបូងបានដែរឬទេ?

**លោក ឃ្នុត វ៉ូសាន់ហោក៖**

សូមអរគុណ។ ដោយសារតែសំណួរទី១ ពាក់ព័ន្ធនឹងខ្ញុំ គឺថាខ្ញុំសូមឆ្លើយ។ អត់បានទេ មិនអាច

ប្រើប្រាស់បាននោះទេ។ ថវិកាខាងអន្តរជាតិមិនអាចយកប្រើប្រាស់សម្រាប់ជាតិបាននោះទេ។ ម្ចាស់ជំនួយត្រៀមខ្លួនក្នុងការឆ្លើយតបទៅនឹងសំណើសុំណាមួយពីតុលាការ មិនថាពីខាងភាគីណានោះទេ ប្រសិនបើនឹងស្នើឡើង។ ចំពោះថវិកាខាងជាតិអត់មានកញ្ចប់ *ខន់ធិនជេនស៊ី* នេះទេ តែគេមានកញ្ចប់ ជី.ធី.អេ កញ្ចប់លុយសម្រាប់មិនមែនបុគ្គលិក។ ដូច្នេះកញ្ចប់ហ្នឹង កញ្ចប់ជី.ធី.អេហ្នឹង គេប្រើប្រាស់នៅពេលដែលមានការងារណាដែលវាកើនឡើងខ្លាំង គេអាចយកកញ្ចប់នេះមកប្រើប្រាស់បាន។ ជាពិសេសនៅពេលដែលការងារហ្នឹងរវល់ដល់ចំណុចដែលថាត្រូវការប្រើប្រាស់កញ្ចប់ថវិកានេះ។ បានន័យថានៅពេលទំហំការងារច្រើននោះ គឺគេអាចយកមកប្រើប្រាស់បាន។

[០៩:៣៥:០០]

**លោក នីកូឡាស គូមជែន៖**

ពាក់ព័ន្ធទៅនឹងបុគ្គលិកបន្ថែមដែលត្រូវការ ដើម្បីចូលរួមជួយការងារ០០២/០២។ ដូច្នេះតើគេអាចកញ្ចប់ ជី.ធី.អេ លុយមិនមែនបុគ្គលិកនេះ យកមកចាយសម្រាប់ជួលបុគ្គលិកបន្ថែមឲ្យធ្វើការងារលើសំណុំរឿង០០២/០២ នេះដែរឬទេ?

**ឯកឧត្តម ក្រាញ់ តូនី៖**

បាទៗ។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណ។ មានសំណួរបន្ថែមមួយទៀត បន្តពីសំណួររបស់លោក លោកស្រីចៅក្រម។ ពាក់ព័ន្ធនឹងលុយសាច់ប្រាក់ នៅពេលដែលយើងមានប្រាក់សុទ្ធនោះ គឺថាយើងអាចជួលបុគ្គលិកបាន។ ខ្ញុំសូមឲ្យកែតម្រូវខ្ញុំ ប្រសិនបើខ្ញុំនិយាយខុស។ កាលពីម្សិលមិញគឺបានលើកឡើងថាមានលុយ២,៧លាននៅសល់។ ហើយនៅត្រឹមពេលនេះ មានកញ្ចប់ថវិកាហ្នឹងមានលុយថែម ៤លានទៀត។ បានន័យថាការសន្យាថែមឲ្យ ៤លានទៀត ដល់តុលាការខាងអន្តរជាតិ។ ដូច្នេះ ថាតើលុយសរុបទាំងពីរនេះអាចយកមកចាយសម្រាប់បុគ្គលិកបានដែរឬទេ?

[០៩:៣៦:១៧]

**លោក ឃ្លុត រ៉ូសាន់ហោក៖**

បាទ ចំនួននេះគឺសម្រាប់ខាងអន្តរជាតិតែប៉ុណ្ណោះ។ ចំពោះលុយ ២,៧ ដែលថាសល់នៅឆ្នាំនេះ ហើយដូចដែលបានបញ្ជាក់អ៊ីចឹង គឺថា ៤លាននេះគឺគេសន្យាបន្ថែមមកទៀត។

**លោក នីកូឡាស គូមជែន៖**

អ៊ីចឹង បានន័យថា លុយអម្បាញ់មិញនេះ ត្រៀមសម្រាប់រួចមកហើយ សម្រាប់ជួលបុគ្គលិកបន្ថែម សម្រាប់អង្គជំនុំជម្រះសាលាដំបូង ក្នុងឆ្នាំក្រោយ។ តើអ៊ីចឹងដែរឬទេ?

**លោក ឃ្នុត រ៉ូសាន់ហោក៖**

បាទ លុយ ៦,៧ នេះគឺថាមាននៅក្នុង អាកខោនហើយ ក្នុងគណនីហើយ។ ដូច្នេះហើយត្រៀមសម្រាប់ប្រើប្រាស់គ្រប់តម្រូវការ ប្រសិនបើត្រូវការ។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមអរគុណលោកប្រធាន។ ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្ត អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានមានសំណួរពាក់ព័ន្ធនឹងបញ្ហានេះ ចំពោះឯកឧត្តមប្រធាន និងអនុប្រធាន។ សូមអញ្ជើញ!

[០៩:៣៧:១៧]

**លោកស្រី បេនី យេះ៖**

សូមអរគុណលោកប្រធាន។ អរុណសួស្តី លោក លោកស្រីចៅក្រម ភាគី អស់លោក លោកស្រីឯកឧត្តមទាំងអស់។ ខ្ញុំមានសំណួរបន្តមួយចំនួន សូមអាធ្យាស្រ័យ សូមសួរទៅកាន់ប្រធានរដ្ឋបាលស្តីទីនិងអនុប្រធានរដ្ឋបាល។ ទី១ ខ្ញុំចង់សួរបន្តសំណួរពីខាងសហព្រះរាជអាជ្ញា ទាក់ទងនឹងការសន្យាផ្តល់ថវិកា។ យើងដឹងហើយ ថាមានការសន្យាផ្តល់ឲ្យ ហើយមានលុយខ្លះនៅខាងអន្តរជាតិ។ ចំពោះខាងជាតិវិញ ថាតើមានគេសន្យាផ្តល់ប្រាក់ឲ្យហើយឬនៅ សម្រាប់ឆ្នាំ២០១៤ និង២០១៥។ អ៊ីចឹងថាខាងជាតិបានទទួលការសន្យាហើយឬនៅ ២០១៤-២០១៥?

**ឯកឧត្តម ក្រាញ់ តូនី៖**

បាទ ដូចខ្ញុំបានជម្រាបជូនអង្គប្រជុំពីម្សិលមិញហើយថា តាមដំណាក់កាលនីតិវិធីរបស់វា គឺគេចាំថវិកាត្រូវបានអនុម័តសិន។ ថវិការួមដែលយើងដាក់ជូនប្រទេសផ្តល់ជំនួយធំៗហ្នឹង ពេលណាគេត្រូវបានអនុម័ត គេនឹង ប្រទេសផ្តល់ជំនួយធំៗគេនឹងចាប់ផ្តើមសន្យាទៅលើតម្រូវការរបស់យើង។ មកដល់សព្វថ្ងៃនេះ មានតែភាគីកម្ពុជាដែលបានសន្យាមុនថាថវិកាបដិភាគសម្រាប់ដំណើរការ អ.វ.ត.ក

២០១៤-២០១៥ នេះ នឹងត្រូវបានផ្តល់ជូនដូចឆ្នាំមុនៗអ៊ីចឹង បាទមកដល់សព្វថ្ងៃ។

[០៩:៣៨:៥០]

**លោកស្រី បេនី យេះ**

សូមអរគុណ។ ដោយផ្អែកពិនិត្យលើស្ថានភាពនេះ និងការលើកឡើងរបស់ឯកឧត្តមកាលពីម្សិលមិញ ចាប់ពីឆ្នាំ២០០៨នេះ គឺថាខាងជាតិជួបបញ្ហាថវិកា។ តើឯកឧត្តមនឹងឃើញថាមានបញ្ហាលើលំហូសាច់ប្រាក់នេះដែរឬទេ ចាប់ពីឆ្នាំក្រោយទៅនេះ?

**ឯកឧត្តម ក្រាញ់ តូនី៖**

បើសិនជា -- យើងចាំគេសន្យាសិនបានយើងដឹង ប៉ុន្តែមកដល់ថ្ងៃនេះ សាច់ប្រាក់ដែលយើងមាននៅក្នុងគណនី គឺសម្រាប់ដាច់ខែនេះ ដាច់ខែ១២នេះ បាទ។

**លោកស្រី បេនី យេះ**

សូមអរគុណ។ តាមខ្ញុំយល់ ប្រសិនបើបុគ្គលិកជាតិត្រូវការជ្រើសរើសមកគាំទ្រសម្រាប់អង្គជំនុំជម្រះទី២ រួមទាំងត្រូវការរើសចៅក្រមសម្រាប់ក្រុមប្រឹក្សាជំនុំជម្រះទី២ផងនោះ អ៊ីចឹងបានន័យថាចំពោះខាងជាតិនោះ ត្រូវយកលុយខាងជាតិយកមកចំណាយ។ តើអ៊ីចឹងដែរឬទេ?

**ឯកឧត្តម ក្រាញ់ តូនី៖**

បាទ ត្រឹមត្រូវ។

**លោកស្រី បេនី យេះ**

ដូច្នេះ នៅក្នុងករណីនេះ តើការជ្រើសរើសបន្ថែមបន្ទុកទៅលើបញ្ហាថវិកាដែលឬទេ ប្រសិនបើឆ្នាំក្រោយៗនោះមានបញ្ហាលំហូសាច់ប្រាក់នោះ? ហើយដោយសារយើងពិចារណាថាមិនទាន់មានថវិកាដែលគេសន្យាហើយនោះទៀតនោះ?

[០៩:៤០:៣៤]

**ឯកឧត្តម ក្រាញ់ តូនី៖**

បាទ បញ្ហាលំហូសាច់ប្រាក់ហ្នឹង យើងបានជួបប្រទះជា -- តាំងពីឆ្នាំ២០០៩ មក ហើយពាក់ព័ន្ធនឹងរឿងថវិកាជារឿងមួយ បញ្ហាលំហូសាច់ប្រាក់ជារឿងមួយទៀត។ យើងអនុវត្តទៅតាម -- ក្នុងបរិបទហ្នឹងរហូតមកដល់សព្វថ្ងៃហ្នឹងវាមានបញ្ហាខ្លះក្នុងការទទួលបានប្រាក់ខែទៀងទាត់ ប៉ុន្តែយើងជាបញ្ចប់យើងទទួលបានពេញលេញ យើងមិនមានពេលណាដែលថវិកាបានអនុម័តលើតួលេខ យើងតែង

តែអនុម័តទៅតាមតួលេខទាំងអស់នោះបាទ បញ្ហាសាច់ប្រាក់វាជាបញ្ហាដែលយើងធ្លាប់ស្គាល់ ប៉ុន្តែវាមិនជាឧបសគ្គ ដើម្បីឲ្យយើងធ្វើការងារ ឬក៏ជ្រើសរើសបុគ្គលិកថ្មីនោះទេ។

[០៩:៤១:៣២]

**លោកស្រី បេនី យេ៖**

សូមអរគុណច្រើនឯកឧត្តម ខ្ញុំពុំមានសំណួរទៀតទេ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី។ បាទ ជាបន្តនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា មុន ប្រសិនបើមានសំណួរអ្វីចង់សួរទៅឯកឧត្តមប្រធាន និងលោកអនុប្រធានពាក់ព័ន្ធនឹងបញ្ហាដែលកំពុងតែពិភាក្សានេះ។ សូមអញ្ជើញបាទ!

**លោក វ៉ិចទ័រ កូប៉េ៖**

អរុណសួស្តីលោកចៅក្រម លោកប្រធាន យើងខ្ញុំពុំមានសំណួរនោះទេ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ចុះខាងក្រុមការពារក្តីលោក ខៀវ សំផន តើមានសំណួរអ្វីដែរឬទេ?

**កញ្ញា អង់តា ហ្គីសសេ៖**

ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រមជាទីគោរព! សហភាតាទាំងអស់ជាទីគោរព។ ខ្ញុំសូមសួរសំណួរបំភ្លឺមួយចំនួន ប្រហែលជាសួរដដែលៗ ប៉ុន្តែខ្ញុំសូមបំភ្លឺតែបន្តិចទេ សួរបំភ្លឺបន្តិច។ លោកប្រធាន អនុប្រធាន កាលម្សិលមិញបានពន្យល់ថា ថវិកាសម្រាប់ភាគីការពារក្តីសម្រាប់ពីរឆ្នាំចុងក្រោយនេះត្រូវបានអនុម័តហើយៗ ដោយសមាសភាពសព្វថ្ងៃនេះ សមាជិកនៅក្នុងការពារក្តីថ្ងៃនេះ។ អ៊ីចឹងមានការបញ្ជាក់ហើយៗអំពីថវិកាដដែលហ្នឹងសម្រាប់អង្គភាពការពារក្តី សម្រាប់រយៈពេលពីរឆ្នាំទៅខាងមុខនេះ។ អ៊ីចឹងមែនទេ? តើអ៊ីចឹងមែនទេលោកអនុប្រធាន?

[០៩:៤៣:១៤]

**លោក ឃុត វ៉ូសាន់ហោក៖**

សូមអរគុណចំពោះសំណុំរឿងវគ្គទី២ គឺត្រឹមត្រូវ គឺអ៊ីចឹងមែន។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមអរគុណ។ ដូច្នេះ ការប្រកាសដែលបានធ្វើ ដែលនិយាយអំពីហានិភ័យ ដែលថាកាត់បន្ថយ

បុគ្គលិកនៅក្នុងបុគ្គលិកគាំទ្រនៅខាងការពារក្តី ឧទាហរណ៍ដូចជា *ខេសមេនេចជើ* ហើយនិង*ខនសាល់ធេន* អន្តរជាតិហ្នឹងពីរនាក់ត្រូវបន្ថែម ដែលធ្វើការនៅសព្វថ្ងៃនេះ។ ហើយយើងត្រូវរើសបន្ថែម ព្រោះថាបន្តិចទៀតហ្នឹងមានការប្តឹងឧទ្ធរណ៍ ហើយនិងការបន្តរឿងវគ្គ២ នេះ។ យើងមើលឃើញថា អ៊ីចឹងបានថា មិនអាចមានទេ ដោយសារមានការបញ្ជាក់ពីថវិកានេះហើយ យើងគិតថាអត់មានហានិភ័យក្នុងការកាត់បន្ថយបុគ្គលិកផ្នែកខាងភាគីការពារក្តីនេះទេ។ អ៊ីចឹងមែនទេ បុគ្គលិកពីរនាក់?

**លោក ឃ្នុត រ៉ូសាន់ហោកៈ**

ទំហំក្រុមមេធាវីការពារក្តីមិនអាស្រ័យទៅលើថវិកានោះទេ គឺវាអាស្រ័យទៅលើតម្រូវការការងារតែប៉ុណ្ណោះ។ ខ្ញុំជឿថា ឌី.អេស.អេស គឺកំពុងតែលើកឡើងសាជាថ្មីអំពីតម្រូវការបុគ្គលិកបច្ចុប្បន្នដែលត្រូវមានវត្តមានក្នុងពេលសវនាការនៅក្នុងពេល *ក្លូសស៊ីងស្តេតមិន* – បានន័យថាការបញ្ចប់ការពិភាក្សាដេញដោលនេះ។ ចំពោះដំណាក់កាល០២នេះ គឺមិនទាន់មានផែនការបញ្ជាក់ឱ្យបានច្បាស់លាស់ដូច្នេះហើយទើបយើងកាត់បន្ថយបុគ្គលិក។ ចំណុចហ្នឹងហើយដែលវាជាហេតុផលក្នុងការកាត់បន្ថយបុគ្គលិកហើយមិនទាន់បានលើកឡើង -- ខាង ឌី.អេស.អេស ហ្នឹងមិនទាន់បានលើកឡើងបញ្ហានេះជូនខ្ញុំសាជាថ្មីនោះឡើយ។

[០៩:៤៥:១៤]

**កញ្ញា អង់តា ហ្គីសសេះ**

អ៊ីចឹងគឺថានៅតែមានបញ្ហាដដែលចំពោះខាងភាគីការពារក្តីហ្នឹងគឺថាអាចមានកាត់បន្ថយបុគ្គលិកពីរនាក់គឺមាន*ខេសមេនេចជើ*មួយ ហើយនិង*ខនសាល់ធេន*មួយ បើតាមការវាយតម្លៃរបស់លោកឥឡូវនេះ។ គឺថាដោយសារការងារកាត់បន្ថយអ៊ីចឹងលោកគិតថាត្រូវកាត់បុគ្គលិកពីរនាក់ ឬក៏យ៉ាងម៉េច ខ្ញុំត្រូវយល់អ៊ីចឹង ឬក៏យ៉ាងម៉េច?

**លោក ឃ្នុត រ៉ូសាន់ហោកៈ**

ពិតជាត្រឹមត្រូវ។ នេះគឺកើតចេញពីបញ្ហានៃខាងប៉ះពាល់ទៅលើបញ្ហាថវិកានេះ។

**កញ្ញា អង់តា ហ្គីសសេះ**

ខ្ញុំសូមជម្រាបជូនអង្គជំនុំជម្រះថា ការពិភាក្សានៅពេលនោះសំខាន់ណាស់ ហើយដោយយោងទៅលើអ្វីដែលការិយាល័យរដ្ឋបាលបានប្រាប់នោះ អ៊ីចឹងធ្វើឱ្យប៉ះពាល់ដល់ការត្រៀមលក្ខណៈរបស់ពួកយើងនៅប៉ុន្មានសប្តាហ៍ខាងមុខនេះ មានការលំបាកខ្លាំងណាស់។ យើងពិបាកគ្រោងទុកណាស់។ ហើយ

សូមឲ្យតុលាការជ្រាបថា មិនមែនជាចេតនារបស់យើងទេក្នុងការដែលធ្វើឲ្យមានការលំបាកដោយសារមានការកាត់បន្ថយបុគ្គលិក ហើយយើងមិនអាចជម្នះនឹងឧបសគ្គនេះបានទេ។ យើងគ្រាន់តែសុំជម្រាបជូនតុលាការថាបើថាយើងត្រូវឆ្លើយតបទៅនឹងសារណាមួយចំនួន ឬក៏យើងត្រូវគ្រោងធ្វើពិភាក្សាលម្អិតអំពីបញ្ហា០០២/២ ឬក៏បណ្តឹងឧទ្ធរណ៍ជាដើម អ៊ីចឹងការ -- ព្រោះថាមិនមានសេចក្តីសាលក្រមនោះទេ គឺថាមានសេចក្តីសម្រេចមួយចំនួនដែលយើងត្រូវឆ្លើយតបទៅដែរ។ ហើយដោយសារយើងពុំមានបុគ្គលិក គ្រប់គ្រាន់នេះយើងនឹងមានការលំបាកក្នុងការឆ្លើយតបទៅនឹងបញ្ហាទាំងអស់នេះ។ ហើយខ្ញុំសូមឲ្យតុលាការយល់អំពីការរៀបចំការងារនៅកន្លែងក្នុងកន្លែងការពារក្តីយើងនេះ ពីព្រោះថាមានបញ្ហាថវិកាត្រូវតែដោះស្រាយបញ្ហាថវិកានេះ។ អ៊ីចឹងខ្ញុំគ្រាន់តែចង់គូសបញ្ជាក់សង្កត់ធ្ងន់ត្រង់ចំណុចនេះថាមានបញ្ហាថវិកា ខ្វះបុគ្គលិក។

[០៩:៤៧:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក នីកូឡាស គូមជែន៖**

សូមអរគុណ។ លោកប្រធានខ្ញុំសូមផ្តល់ព័ត៌មានខ្លះដែលការិយាល័យរបស់ខ្ញុំបានលើកឡើង រកឃើញលើបញ្ហាសំណើរបស់លោកចៅក្រមឡាវែន៍។ ពាក់ព័ន្ធទៅនឹងគណៈកម្មាធិការទី៥ នៅក្នុងមហាសន្និបាតនីតិវិធីលេខ១២៥ គឺចែងថា “សេចក្តីសម្រេចរបស់គណៈកម្មាធិការទី៥ គឺត្រូវយកតាមសំឡេងភាគច្រើននៃសំឡេងវត្តមានក្នុងពេលប្រជុំ”។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវការផ្តល់ព័ត៌មានច្បាស់លាស់នេះ។ បាទ ជាកិច្ចបន្ត គឺយើងចូលដល់របៀបវារៈទី៣ ដែលត្រូវពិភាក្សានៅក្នុងកិច្ចប្រជុំពិភាក្សារបស់យើងនេះ។ វិសាលភាពអំពីសំណុំរឿង ០០២/០២ និងផ្នែកដែលត្រូវជំនុំជម្រះនៅពេលខាងមុខ។ របៀបវារៈទី៣ គឺពាក់ព័ន្ធទៅនឹងវិសាលភាពនៃសំណុំរឿង០០២/០២។ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា តាមបុរេលក្ខខណ្ឌជាក់ស្តែងមួយចំនួនសហព្រះរាជអាជ្ញាអាចមានលទ្ធភាពដកចេញនូវការចោទប្រកាន់ខ្លះដោយស្របតាមផ្លូវច្បាប់។ ចំណុចនេះហាក់ដូចជាបង្ហាញនូវកត្តាមួយបន្ថែមទៀតសម្រាប់ការសម្រេចអំពីវិសាលភាពនៃផ្នែកដែលត្រូវយកមកជំនុំជម្រះសម្រាប់ដំណាក់កាលទី២នេះ។ ចំណុចនេះក៏បានបង្កឲ្យមានបញ្ហាផ្លូវច្បាប់មួយចំនួនដែល

ចាំបាច់ត្រូវធ្វើការពិភាក្សានិងសម្រេច។

នៅក្នុងកិច្ចប្រជុំរៀបចំសវនាការការកំណត់កាលបរិច្ឆេទបច្ចុប្បន្ននេះមិនបានផ្ដល់ពេលវេលាគ្រប់គ្រាន់ដល់ភាគីនានាក្នុងការពិភាក្សាដេញដោលលើបញ្ហាអង្គច្បាប់ដ៏ស្មុគស្មាញនេះបានឡើយ។ ទោះបីជាយ៉ាងនេះក៏ដោយ ប្រសិនបើមានការពិភាក្សាបឋមអំពីវិសាលភាពនៃសំណុំរឿង ០០២/០២ ដែលនឹងជួយដល់ការបង្ហាញអំពីទស្សនៈដំបូងៗរបស់ភាគីនានានោះ ការពិភាក្សាបែបនេះនឹងផ្ដល់ប្រយោជន៍ដល់អ្នកដែលត្រូវសម្រេចលើបញ្ហាជាចុងក្រោយ។ ហេតុដូច្នេះ ជាចំណុចចាប់ផ្ដើម និងដើម្បីដោះស្រាយឲ្យបានឆាប់រហ័សទៅលើបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងស្នើដល់ភាគីនានាឲ្យលើកឡើងជាសារណាអំពីការចោទប្រកាន់ បទចោទប្រកាន់ទីកន្លែងឧក្រិដ្ឋកម្ម និងអង្គហេតុដែលបានចោទប្រកាន់ណាខ្លះដែលគួរត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំ -- ក្នុងការជំនុំជម្រះដំណាក់កាលទី២ ឬសំណុំរឿង ០០២/០២។ នៅក្នុងសេចក្ដីសម្រេចលើកមុនរបស់ខ្លួនលើបញ្ហានេះ អង្គជំនុំជម្រះតុលាការកំពូលបានចង្អុលបង្ហាញថា តើបញ្ហាការចោទប្រកាន់អ្វីខ្លះដែលគួរដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២/០២ ក្នុងកម្រិតអប្បបរមា ដូចជាការចោទប្រកាន់ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខស-២១ ការដ្ឋាន សហករណ៍ និងអំពើប្រល័យពូជសាសន៍។ ដោយផ្អែកលើមូលដ្ឋាននេះ តើភាគីអាចបញ្ជាក់បានដែរឬទេថាតើការចោទប្រកាន់ បទចោទប្រកាន់ទីតាំងឧក្រិដ្ឋកម្មអ្វីខ្លះ ឬក៏អង្គហេតុចោទប្រកាន់អ្វីខ្លះដែលគួរត្រូវយកមកដាក់បញ្ចូលនៅក្នុងសំណុំរឿង០០២/០២? ដោយផ្អែកលើមូលដ្ឋាននៃសំណើទាំងនេះ តើភាគីអាចវាយតម្លៃអំពីពេលវេលាសម្រាប់កិច្ចដំណើរការនីតិវិធីដែលត្រូវធ្វើដែរឬទេ។

ជាដំបូងនេះ អង្គជំនុំជម្រះសូមជូនវេទិកាជូនទៅភាគីសហព្រះរាជអាជ្ញាមុនភាគីដទៃទៀតនៃរឿងក្ដី។ សូមអញ្ជើញបាទ!

[០៩:៥១:៥៩]

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមឲ្យលោក លីសាក់ ឡើងថ្លែងក្នុងនាមសហព្រះរាជអាជ្ញាឲ្យបានលម្អិតអំពីផែនការជំនុំជម្រះខាងផ្នែកយើង។ ខ្ញុំគ្រាន់តែលើកជាសេចក្ដីផ្ដើមតែប៉ុណ្ណោះ។ យើងខ្ញុំស្នើសុំឲ្យមានផែនការនោះ ដែលខ្ញុំសរសេរជាលាយលក្ខណ៍អក្សររួចមកហើយ ហើយដោយតម្រូវឲ្យដាក់បញ្ចូលលក្ខខណ្ឌតម្រូវទាំងអស់ពីតុលាការកំពូល។ សំណើសុំរបស់យើងគឺកាត់ក្ដីនៅក្នុងវគ្គទី២នេះ គឺកាត់ក្ដីទៅលើបទចោទទាំងឡាយដែលនៅសល់។ បានន័យថា គឺក្ដោបរួមទាំងបទឧក្រិដ្ឋកម្មប្រល័យ

ពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម គឺដាក់ចូលទាំងអស់។ ជាពិសេសការគោលដៅទៅលើក្រុមជាក់លាក់ និងឧក្រិដ្ឋកម្មរៀបការដោយបង្ខំ និងឧក្រិដ្ឋកម្មលើយេនឌ័រ ហើយផែនការដែលយើងស្នើសុំដាក់បញ្ចូលនោះ គឺវាអាចចំណាយពេល៩៦ពេល នៃការជំនុំជម្រះរបស់តុលាការ។ លោក ឌេល លីសាក់ នឹងធ្វើការស្នើឡើងដើម្បីធ្វើយ៉ាងណាឲ្យយើងដំណើរការទៅលឿន។ បទចោទទាំងអស់នេះមិនមែនថាបញ្ចូលទីតាំងឧក្រិដ្ឋកម្មទាំងអស់នោះទេ –ដែលមានសរសេរនៅក្នុងដីកាដំណោះស្រាយ– គ្រាន់តែបញ្ចូលបទចោទទាំងអស់ដែលវាពាក់ព័ន្ធនៅក្នុងហ្នឹងតែប៉ុណ្ណោះ។ យើងខ្ញុំជឿជាក់ថាការដែលធ្វើដូច្នេះនឹងបំពេញទៅតាមលក្ខខណ្ឌតម្រូវរបស់តុលាការកំពូល។ សំខាន់ជាងនេះគឺវាអាចឲ្យសវនាការនេះមានប្រសិទ្ធភាព ហើយចប់ក្នុងពេលមួយសមហេតុផល ហើយវាដែលបំពេញទៅតាមគោលបំណងរបស់តុលាការនេះ។ នៅពេលដែលយើងបញ្ចូលឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការរំលោភសេពសន្ថវៈ និងការរៀបការដោយបង្ខំ និងបទចោទដូចដែលខ្ញុំបានស្នើឡើងនោះ គឺថាវាធ្វើឲ្យសវនាការយើងមានប្រសិទ្ធភាព នឹងបញ្ចប់តាមបេសកម្មរបស់យើង។

ខ្ញុំអស់ សូមអនុញ្ញាតឲ្យលោក ឌេល លីសាក់ ចាប់ផ្តើម។

[០៩:៥៥:០៩]

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ អរុណសួស្តីលោក លោកស្រីចៅក្រម។ យើងខ្ញុំបានដាក់សំណើសុំជាលាយលក្ខណ៍អក្សរ និង លម្អិត ហើយយើងខ្ញុំជឿជាក់ថាវានឹងជួយសម្រួល ហើយនិងអាចទាញជាយោបល់របស់អង្គជំនុំជម្រះ និងភាគីទាំងអស់ផងដែរ។ នៅពេលនេះ យើងខ្ញុំនឹងត្រៀមខ្លួនឆ្លើយតបទៅនឹងសំណួរណាមួយដែលមាន ហើយនិងយោបល់ផ្សេងទៀតរបស់ភាគីប្រសិនបើមាន។ ខ្ញុំសូមអនុញ្ញាតនិយាយដោយសាមញ្ញថា សំណើសុំរបស់យើងភាគច្រើន គឺធ្វើទៅតាមសេចក្តីសម្រេចរបស់តុលាការកំពូលចេញក្នុងខែវិច្ឆិកា។

តុលាការកំពូលបានបញ្ជា បង្គាប់ពីរចំណុច។ ទី១ សវនាការលើកស្តុតាងក្នុងវគ្គទី២ចាប់ផ្តើមឲ្យបានលឿនតាមដែលអាចធ្វើទៅបាន។ ទី២ ការជំនុំជម្រះទី២នេះ គឺក្នុងកម្រិតអប្បបរមាគួរតែបញ្ចូល ស-២១ ការដ្ឋានការងារ សហករណ៍ និងបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍បញ្ចូលផង។

នៅក្នុងសំណើសុំរបស់យើង គឺសំណើសុំរបស់ខ្ញុំនេះគឺសូមដាក់បញ្ចូលទៅតាមការបង្គាប់របស់តុលាការកំពូល។ ដូច្នេះយើងខ្ញុំសូមឲ្យដាក់បញ្ចូលស-២១ ខ្ញុំសូមបញ្ចូលការប្រល័យពូជសាសន៍ទៅលើជនជាតិចាមនិងជនជាតិវៀតណាម។ តុលាការកំពូលស្នើសុំឲ្យបញ្ចូលសហករណ៍។ មានតែសហករណ៍នៅទីតាំងឧក្រិដ្ឋកម្មមួយតែប៉ុណ្ណោះដែលមានសរសេរនៅក្នុងដីកាដំណោះស្រាយ គឺសហករណ៍នៅត្រាំកក់។ យើងខ្ញុំស្នើសុំឡើងថា សហករណ៍១មករានោះក៏គួរបញ្ចូលផងដែរ ដែលវាជាទីតាំងសហករណ៍មួយធំ វាតំណាងរួមនៅលើផែនការជីកទំនប់ លើកប្រឡាយផងដែរ។ ហើយនៅទីនេះ ហើយដែលមានធ្វើការងារដោយបង្ខំ កើតឡើងនៅទីនោះ។

[០៩:៥៦:២៥]

ចំណុចទី២ យើងខ្ញុំស្នើសុំដាក់បន្ថែមការដ្ឋានមួយចំនួនបន្ថែមពីលើនេះ។ យើងខ្ញុំបានធ្វើដូច្នេះដោយក្រោយពីពិចារណាទៅលើចំណោទបញ្ហាទី២ ដែលលេចចេញមកពីសេចក្ដីសម្រេចរបស់តុលាការកំពូល ហើយបានបញ្ជាក់នៅក្នុងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង។ ដោយក្នុងនោះ តើយើងគួរតែរៀបចំផែនការសម្រាប់ការជំនុំជម្រះវគ្គទី៣ ដែរឬទេ។ យើងដូចចម្លើយរបស់របស់យើងខ្ញុំនេះ យើងមិនគួរចាំបាច់ត្រៀមទេ។ នៅក្នុងវគ្គទី២នេះ យើងគួរបញ្ចូលបទចោទទាំងអស់ដែលនៅសល់ទៅ ហើយយកទីតាំងឧក្រិដ្ឋកម្មណាមួយយកមកធ្វើជាតំណាង។ ដូច្នេះហើយការជំនុំជម្រះវគ្គទី២នេះ គឺជាការជំនុំជម្រះចុងក្រោយហើយសម្រាប់ជនជាប់ចោទទាំងពីរនេះ។

នេះគឺជាមូលដ្ឋានដែលយើងបានស្នើឡើងនៅក្នុងសេចក្ដីសន្និដ្ឋានរបស់យើងខ្ញុំ។ ដោយសារហេតុផលនេះហើយ យើងខ្ញុំស្នើសុំបន្ថែមមន្ទីរសន្តិសុខមួយចំនួនថែមទៀត និងការដ្ឋានបន្ថែមមួយ។ ក្នុងនេះគឺដើម្បីធានាថាទីតាំងឧក្រិដ្ឋកម្មដែលយកមកជំនុំជម្រះនៅក្នុងវគ្គទី១ និងវគ្គទី២ រវាងការជំនុំជម្រះទាំងនេះ បានន័យថា បើសិនធ្វើតាមយើងខ្ញុំ គឺថាវានឹងគ្របទីតាំងឧក្រិដ្ឋកម្មទាំងអស់ ហើយយើងអាចគ្របទៅលើបទចោទដែលមាននៅក្នុងដីកាដំណោះស្រាយផងដែរ។

[០៩:៥៧:៥៥]

យើងខ្ញុំសូមសង្ខេបថា ការជម្លៀសដោយបង្ខំពីរក្នុងចំណោមបី បានជំនុំជម្រះរួចមកហើយ។ សហករណ៍បីក្នុងចំណោមប្រាំមួយ ក៏បានជំនុំជម្រះរួចមកហើយ។ មន្ទីរសន្តិសុខប្រាំ ក្នុងចំណោម១៤ ក៏បានជំនុំជម្រះរួចហើយផងដែរ។ បួន ក្រុមបួនដែលគេគោលដៅនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ក៏បានជំនុំជម្រះរួចហើយផងដែរ ហើយការរៀបការដោយបង្ខំក៏បានជំនុំជម្រះរួចផងដែរ។ ទាំងអស់

នេះគឺជាការដែលយើងខ្ញុំពិចារណានៅក្នុងសំណើរបស់យើងខ្ញុំ។ ខ្ញុំរីករាយក្នុងការឆ្លើយតបសំណួរទាំងឡាយប្រសិនបើមាន។ ហើយជាការពិតទៅ ខ្ញុំក៏រីករាយក្នុងការឆ្លើយតបទៅនឹងបញ្ហាចោទណាមួយដែលលើកឡើងដោយក្រុមមេធាវីការពារក្ដីផងដែរ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្វង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្វង់ម៉ាក ឡាវែន៍៖**

តាមពិតទៅយើងមានបញ្ហាជាច្រើនដែលត្រូវដោះស្រាយ។ ហើយក្នុងចំណោមបញ្ហាទាំងអស់នោះ គឺយើងត្រូវគិតអំពីជំហានចាំបាច់មុននឹងពេលដែលយើងអាចចាប់ផ្ដើមសវនាការលើអង្គសេចក្ដីនាពេលខាងមុខ។ ហើយយើងត្រូវកំណត់ឲ្យបានច្បាស់ ថាតើពេលវេលាចាំបាច់មានប៉ុន្មានសម្រាប់ដោះស្រាយបញ្ហានៅតាមដំណាក់កាលនីមួយៗ។ ហើយខ្ញុំគិតថាប្រហែលជាមានបញ្ហាពាក់ព័ន្ធទៅនឹងពាក្យបច្ចេកទេសពាក់ព័ន្ធនឹងការបកប្រែ ពីព្រោះថានៅពេលដែលខ្ញុំស្ដាប់ឮអស់លោកបានប្រាប់អំពីស្នើឲ្យមានការពិនិត្យនៅក្នុងក្របខ័ណ្ឌនៃសវនាការវគ្គបន្ទាប់នេះ បទចោទដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ខ្ញុំយល់ថាមិនមែនឧក្រិដ្ឋកម្មទាំងអស់ទេ។ ពីព្រោះថាពាក្យថា“បទចោទ”នេះ ជាភាសាបារាំង គឺវាពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មជាក់លាក់មួយៗ។ ប៉ុន្តែតាមពិត នៅពេលដែលយើងនិយាយថាបទចោទនីមួយៗនោះ គឺជាប្រភេទផ្សេងគ្នានៃឧក្រិដ្ឋកម្មជាក់លាក់។ យើងត្រូវតែយល់បែបនេះទាំងអស់គ្នា។

[១០:០០:៥០]

ខ្ញុំមានការកត់សម្គាល់មួយពាក់ព័ន្ធទៅនឹងសេចក្ដីចង្អុលបង្ហាញអំពីពេលវេលា។ យើងនឹងត្រឡប់មកនិយាយអំពីខ្លឹមសារនៅពេលក្រោយ។ តើលោកអាចបញ្ជាក់បានទេ ថាតើលោកគណនាពេលវេលាចាំបាច់សម្រាប់សាក្សីនីមួយៗ អ្នកជំនាញនីមួយៗ ឬក៏ដើមបណ្ដឹងរដ្ឋប្បវេណីនីមួយៗយ៉ាងម៉េច? ហើយលោកគ្រោងនឹងការកោះហៅអ្នកទាំងអស់នេះយ៉ាងម៉េច? អ្វីដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលនោះ នៅពេលដែលខ្ញុំអានឯកសាររបស់លោកអស់ទៅ គឺថាសាក្សីភាគច្រើនដែលស្នើនោះ ឲ្យស្ដាប់ចម្លើយគឺថាកន្លះថ្ងៃ ឬក៏បីភាគបួននៃថ្ងៃក្នុងម្នាក់។ តើការចង្អុលបង្ហាញនេះ វាត្រូវនឹងពេលវេលាចាំបាច់សម្រាប់លោកដែលជាសហព្រះរាជអាជ្ញាក្នុងការសួរសាក្សីហ្នឹង? ឬក៏ពេលវេលាហ្នឹង ជាពេលវេលាសរុបសម្រាប់ការសួរសំណួរសាក្សីដោយភាគីទាំងអស់តែម្ដង?

ខ្ញុំដូចជារៀងភ្ញាក់ផ្អើលបន្តិចដែរ ក៏ប៉ុន្តែចំនួនសាក្សីដែលអង្គជំនុំជម្រះអាចស្ដាប់នោះ ក្រោយពី

ភាគីបានសួរសំណួរហើយ អាចស្តាប់តិចជាងមួយថ្ងៃនោះ គឺថាវាជាលក្ខណៈលើកលែងកាលពីមុននោះ។ ជាទូទៅនោះ គឺថាយ៉ាងហោចណាស់ក៏មួយថ្ងៃដែរសម្រាប់ការសួរដើមបណ្តឹងរដ្ឋប្បវេណី ឬក៏សាក្សីមួយរូបនោះ។ តើលោកអាចបញ្ជាក់បំភ្លឺអំពីចំណុចនេះបានដែរឬទេ ថាពេលវេលាដែលអស់លោកគិតនោះ គឺគិតតែសម្រាប់តែពេលវេលាសម្រាប់សហព្រះរាជអាជ្ញា ឬក៏គិតពេលវេលាសម្រាប់ភាគីទាំងអស់តែម្តង?

**លោក ឌេល លីសាក់៖**

សូមអរគុណចៅក្រម ឡាវ៉ែន។ ខ្ញុំសូមជម្រាបទាក់ទងទៅនឹងមតិទី១។ ខ្ញុំសូមបញ្ជាក់ថា សេចក្តីសង្ខេបរបស់លោកចៅក្រម ត្រឹមត្រូវហើយ។ នៅពេលដែលយើងនិយាយថា ការចោទប្រកាន់ទាំងអស់ហ្នឹងត្រូវយកមកជំនុំជម្រះ។ យើងនិយាយអំពីបទចោទ អំពីប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ហើយនិងការបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ហើយយើងនិយាយអំពីបទចោទតាមផ្លូវច្បាប់ ហើយដែលយើងបានស្នើ ដែលថាទីតាំងបទឧក្រិដ្ឋនឹងអាចនឹងបន្ថយ។

[១០:០៣:២៦]

ឆ្លើយតបទៅនឹងសំណួរទាក់ទងទៅនឹងសំណើដាក់សាក្សីនេះ គឺថាពេលវេលាដែលយើងបានស្នើនេះ គឺជាពេលសរុប។ ហើយខ្ញុំសូមកត់សម្គាល់ថា នៅពេលដែលយើងព្យាយាមធ្វើសំណើបែបនេះគឺថាមានការបែងចែករវាងសាក្សីនានា។ នៅពេលដែលយើងនិយាយអំពីសាក្សីដែលអាចនឹងធ្វើសក្ខីកម្មទាក់ទងទៅនឹងហេតុការណ៍មួយចំនួន បទឧក្រិដ្ឋមួយចំនួន ហើយនិងប្រៀបធៀបទៅនឹងសាក្សីផ្សេងទៀតដែលអាចនឹងធ្វើសក្ខីកម្មទូលំទូលាយ ឬក៏អាចជាអតីតកម្មាភិបាលដែលអាចនិយាយអំពីបញ្ហាច្រើន អំពីមន្ទីរសន្តិសុខផ្សេងៗ។ យើងនឹងប្រើពេលច្រើនសម្រាប់សាក្សីរូបនេះ។ ចំពោះសាក្សីខ្លះទៀតយើងនឹងត្រូវប្រើពេល ប្រើធ្វើសក្ខីកម្មមានកម្រិតមួយចំនួននោះ គឺថាយើងនឹងនិយាយដោយសង្ខេបខ្លីៗទេ ចំពោះសាក្សីនិយាយអំពីមូលដ្ឋានបទឧក្រិដ្ឋនោះ។

និយាយអំពីរយៈពេលដែលត្រូវការសម្រាប់ជំនុំជម្រះវគ្គទី១នេះ ខ្ញុំសូមជម្រាបអង្គជំនុំជម្រះថា យើងមានពេលមួយសប្តាហ៍ ឬពីរសប្តាហ៍ នៅពេលដែលយើងបានស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលបានមកធ្វើសក្ខីកម្មនិយាយអំពីបទពិសោធន៍ ហើយនិងអ្វីដែលកើតឡើងនៅក្នុងពេលជម្លៀសដោយបង្ខំ ហើយនិងការឈឺចាប់របស់ពួកគាត់។ យើងបានស្តាប់បួនរូបក្នុងមួយថ្ងៃក្នុងពេលនោះ។ ដូច្នោះ -- ហើយដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺថាម្នាក់បានតែកន្លះថ្ងៃទេ។ បាទ អ៊ីចឹងគឺថាមួយភាគបួន

នៃមួយថ្ងៃ យើងមិនស្នើបែបនោះទេ ប៉ុន្តែសាក្សីភាគច្រើនបែបនេះ គឺថាយើងឃើញថាមានអង្គហេតុជាក់លាក់មានកម្រិត ហើយក៏បានផ្តល់ចម្លើយជាលាយលក្ខណ៍អក្សរហើយ ដែលយើងអាចនឹងរកសាក្សីនោះបានឆាប់រហ័ស។ នេះហើយជាមូលដ្ឋានដែលយើងកម្រិតពេល។ ហើយភាគីផ្សេងទៀតក៏អាចមានទស្សនៈផ្សេងដែរ។ មេធាវីការពារក្តី ហើយនិងភាគីផ្សេងអាចនិយាយថា យើងយល់ថាសាក្សីរូបនេះសំខាន់ណាស់សម្រាប់ថា កន្លះថ្ងៃមិនគ្រប់គ្រាន់ទេ។ ដូច្នេះ យើងនឹងពិនិត្យទៅលើសភាពការណ៍នោះ។ នេះហើយជាការគិតដែលជាមូលដ្ឋាននៃការស្នើសាក្សីរបស់យើងខ្ញុំនោះ។ ប៉ុន្តែចំពោះសាក្សីដែលមានបញ្ហាស្មុគស្មាញ ដែលយើងត្រូវដោះស្រាយនោះគឺថា យើងមាន -- យើងឃើញថាមានអង្គហេតុមានកម្រិតមួយចំនួនដែលនឹងត្រូវធ្វើសក្ខីកម្មចំពោះមុខអង្គជំនុំជម្រះនោះដែរបាទ។

[១០:០៦:១១]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សំណួរទី១ ថាតើដើម្បីបង្កើតរយៈពេលប៉ាន់ស្មាននេះ លោកមានបានពិគ្រោះយោបល់ជាមួយភាគីផ្សេងទៀតទេ ឧទាហរណ៍ដូចជាសហមេធាវីនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ជាមួយមេធាវីការពារក្តី?

**លោក ឌេល លីសាក់៖**

លោកចៅក្រមយើងមានការពិគ្រោះយោបល់ជាមួយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីអំពីផែនការ ហើយជាពិសេស អំពីទីតាំងបទឧក្រិដ្ឋមិនច្រើនលម្អិត សាក្សីនីយមួយៗនោះទេ។ ដើម្បីឲ្យយល់ស្រប លើសំណើពេលវេលាទេ ប៉ុន្តែដើម្បីឆ្លើយតបទៅលោកចៅក្រម យើងបានមានការពិភាក្សាអំពីវិសាលភាពនៃការជំនុំជម្រះមិនមែនលក្ខខណ្ឌតម្រូវពេលវេលាសម្រាប់សាក្សីមួយៗយើងបាននិយាយលម្អិតទេបាទ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដើម្បីត្រឡប់មកអំពីបទពិសោធន៍ដែលយើងអាចមានពាក់ព័ន្ធ នឹងការស្តាប់ចម្លើយសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី។ ពិតណាស់ថា យើងបានស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ដែលបានមកផ្តល់សក្ខីកម្មក្នុងរយៈពេលយ៉ាងខ្លីមែនទែន ជួនកាលទៅយើងបានស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនក្នុងរយៈពេលតែមួយថ្ងៃ ក៏ប៉ុន្តែខ្ញុំសូមរំឭកថា ដើមបណ្តឹងរដ្ឋប្បវេណីនេះគឺត្រូវបានហៅមកឲ្យផ្តល់សក្ខីកម្មតែអំពីការឈឺចាប់ដែលខ្លួនបានទទួលរង គឺមិនឲ្យផ្តល់អំពីភស្តុតាង ឬអង្គហេតុលើអង្គសេចក្តី

នោះទេ។

[១០:០៧:៤៩]

ចំណុចទី២ លោកបាននិយាយថា មានការបែងចែករវាងសាក្សីដែលសក្ខីកម្មអាចនឹងត្រូវបានពង្រីកមានលក្ខណៈ ជាទូទៅគឺពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធជាដើម ឧទាហរណ៍ ឬក៏មានការឆ្លើយបញ្ជាក់សំខាន់អំពីការទទួលខុសត្រូវរបស់ជនជាប់ចោទ។ ហើយយើងមានសាក្សីផ្សេងទៀត ដែលមកផ្ដល់សក្ខីកម្មអំពីឧក្រិដ្ឋកម្ម ឬទីតាំងឧក្រិដ្ឋកម្មជាក់លាក់ណាមួយ។ ខ្ញុំសូមលើកឧទាហរណ៍ ដូចជាទួលពោធិ៍ជ្រៃ។ នេះជាឧក្រិដ្ឋកម្មជាក់លាក់មួយ។ ជាដំបូងនោះ លោកបានគ្រោងថាស្ដាប់តែពីរនាក់ទេកាលណោះ ដល់ហើយ -- បន្ទាប់មកលោកគិតថាមិនគ្រប់គ្រាន់ក៏បានស្នើសុំបន្ថែមទៀត។ ហើយចំពោះសាក្សីដែលផ្ដល់សក្ខីកម្មអំពីទីតាំងឧក្រិដ្ឋកម្មជាក់លាក់នោះ ប្រសិនបើខ្ញុំចងចាំមិនខុសទេ យើងបានចំណាយពេលលើសពីមួយថ្ងៃទៅទៀតក្នុងការសួរសាក្សីម្នាក់។ ដូច្នេះខ្ញុំចង់ដឹងឲ្យច្បាស់ថា តើការប៉ាន់ស្មានពេលវេលារបស់លោកនេះ ផ្អែកទៅលើបទពិសោធន៍កាលពីកន្លងទៅ ឬក៏លោកគ្រោងផ្លាស់ប្ដូររបៀបនៃការសួរចម្លើយទាំងស្រុងតែម្ដង? ខ្ញុំដូចជាមិនយល់អំពីការគិតរបស់លោកទេ។

**លោក ឌេល លីសាក់៖**

អរគុណលោកចៅក្រម ឡាវ៉ែន៍។ ហើយយើងមិនបានស្នើឲ្យមានការកែប្រែអ្វីធំដុំទេ បើយើងមើលត្រឡប់ក្រោយវិញ។ ទៅលើសាក្សីមួយចំនួនដែលបានបង្ហាញខ្លួន និយាយអំពីជម្លៀសដោយបង្ខំ យើងឃើញថាភាគច្រើនដែលបានមកធ្វើសក្ខីកម្មហ្នឹងគឺថា គាត់បំភ្លឺមួយថ្ងៃ ឬក៏តិចជាងមួយថ្ងៃ ទោះបីជាអ្នកទាំងអស់នោះមិនតិចជាងមួយថ្ងៃក៏ដោយ ប៉ុន្តែចំពោះការជំនុំជម្រះគឺថាយើងមានមេធាវីការពារក្ដីពីរក្រុមនៅពេលនេះ។ មិនមានការកែប្រែច្រើនធំនោះទេ ក៏ប៉ុន្តែនេះគឺជាសំណើដូចដែលយើងបានស្នើ។ ប្រសិនភាគីផ្សេងៗ ឬអង្គជំនុំជម្រះយល់ថា មិនគ្រប់គ្រាន់ទេ អាចនឹងពិនិត្យមើលចម្លើយសាក្សីថាតើសាក្សីហ្នឹងត្រូវនិយាយអ្វីខ្លះលើបញ្ហាណាមួយ ភាគីឬលោកចៅក្រមអាចបន្ថែមពេលវេលា។ នេះជាសំណើរបស់យើងខ្ញុំ។ យើងបានធ្វើយើងពិនិត្យមើលចម្លើយសាក្សីធ្វើការវាយតម្លៃថាតើសាក្សីនេះឬក៏ចំណុចសំខាន់អង្គហេតុហ្នឹងម្នាក់ៗនោះនឹងអាចផ្ដល់ជូនតុលាការបានប៉ុណ្ណារយៈពេលប៉ុនណា? តាមយើងស្មាន ដើម្បីឲ្យអង្គជំនុំជម្រះពិនិត្យមើលថានេះពេលយ៉ាងអប្បបរមាដែលយើងត្រូវស្ដាប់អ្នកទាំងនោះ។

[១០:១០:៤៧]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

មានចំណុចផ្សេងទៀតដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលនៅពេលដែលខ្ញុំអានឯកសារសារណារបស់លោក។ គឺការប្រៀបធៀបសវនាការដែលទើបនឹងបញ្ចប់មុននេះ។ គឺសំណុំរឿង ០០២/០១ ដែលបានប្រព្រឹត្តទៅក្នុងរយៈពេល២២០ថ្ងៃ។ ហើយក្នុងបន្ទាប់ពីក្នុងរយៈពេល ២២០ថ្ងៃនេះគឺថាយើង -- នៅក្នុងរយៈពេល ២២០ថ្ងៃនេះយើងបានសួរមនុស្ស ៩០នាក់។ នៅពេលដែលលោកស្នើថា ៩៦ថ្ងៃនេះតើលោកអាចបញ្ជាក់បានទេថាតើរយៈពេលសរុបនៃថ្ងៃសវនាការតែម្តងនោះវាប៉ុន្មានដែរសម្រាប់ការជំនុំជម្រះលើសំណុំរឿង ០០២/០២ នេះ?

**លោក ឌេល លីសាក់៖**

ខ្ញុំសូមបំភ្លឺថា ៩៦ថ្ងៃនេះ គឺជាពេលវេលាសរុបដែលបូកសំណើដែលយើងបានស្នើពេលវេលាទៅតាមសាក្សីដែលយើងបានលើកឡើង។ អ៊ីចឹង៩៦ថ្ងៃនេះ តំណាងឲ្យសំណើរបស់យើងទាក់ទងទៅនឹងថាតើយើងត្រូវការពេលប៉ុន្មានសម្រាប់សាក្សីទាំងអស់នេះ។ ជាក់ស្តែងគឺថាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងមេធាវីការពារក្តីអាចនឹងបន្ថែមសាក្សីផ្សេងទៀតដែលចង់ស្តាប់នោះដែរ។ ដូច្នេះ និយាយអំពីការប្រៀបធៀបទៅនឹងការជំនុំជម្រះវគ្គទី១ ខ្ញុំរីករាយណាស់ដែលលោកចៅក្រមសួរបញ្ហានេះ។ គឺថាមានភាពខុសគ្នារវាងការបែងចែកសាក្សី ហើយនិងការបែងចែកភាគរយអំពីបញ្ហាស្មុគស្មាញ ឬក៏ទំនាក់ទំនងទៅនឹងសាក្សីដែលយើងបានស្តាប់នៅក្នុងសវនាការវគ្គទី១ ហើយដែលថាយើងនឹងត្រូវស្តាប់នៅក្នុងវគ្គទី២នេះ។ នៅវគ្គដំបូងនោះគឺថាលោកចៅក្រមជ្រាបហើយគឺថាចង់ឲ្យសាក្សីបំភ្លឺពីមូលដ្ឋានសម្រាប់វគ្គបន្ទាប់។ អ៊ីចឹងនៅក្នុងវគ្គទី១នោះ គឺថាយើងលើកឡើងអំពីសាក្សីស្មុគស្មាញមួយចំនួនដើម្បីនិយាយទៀតថាតើរបបនោះដំណើរការដូចម្តេច? តើប្រព័ន្ធទំនាក់ទំនងយ៉ាងដូចម្តេច? តួនាទីរបស់ជនជាប់ចោទយ៉ាងដូចម្តេច? ថាតើតួនាទីមុខងារអ្វីខ្លះដែលអង្គការកម្ពុជាប្រជាធិបតេយ្យត្រូវធ្វើនោះ។ នោះហើយដែលយើងត្រូវការប្រើពេលមួយចំនួន។

[១០:១៣:២៩]

ចំពោះវគ្គទី២នេះ គឺថាយើងមិនមានសាក្សីច្រើនដែលបញ្ជាក់អំពីបញ្ហាទាំងនោះទេ ដោយសារថាយើងបានស្តាប់សាក្សីភាគច្រើនបែបនោះរួចហើយនៅក្នុងសវនាការ០០២/០១ នោះ។ ដូច្នេះយើងមិនត្រូវពិនិត្យសាឡើងវិញនូវភស្តុតាងទាំងឡាយដែលបានស្តាប់នៅក្នុងវគ្គទី១ រួចហើយទេ។ ដូច្នេះឯកសារដែលក្នុងវគ្គទី១ បានស្តាប់នោះ យើងប្រើជាឯកសារសម្រាប់វគ្គទី២។ នេះហើយជាអ្វីដែលខ្ញុំហៅថា

ភាពស្មុគស្មាញនៃសក្ខីកម្មដែលត្រូវស្តាប់ក្នុងវគ្គទី២ នេះដែលយើងត្រូវផ្តោតទៅលើសាក្សីដែលបញ្ជាក់អំពីមូលដ្ឋានបទឧក្រិដ្ឋដែលខ្លីជាង។ នេះហើយដែលយើងអាចកំណត់បានគឺថារយៈពេលថ្ងៃសវនាការហ្នឹងអាចនឹងខ្លីជាង ហើយសាក្សីច្រើនតែក្នុងរយៈពេលខ្លីជាងសវនាការក្នុងរឿងក្តី០០២/០១។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ក្នុងសំណុំរឿង០០២/០១ យើងបានចំណាយពេលជាច្រើនថ្ងៃទៅលើការពិភាក្សាគ្នាអំពីឯកសារ។ យើងក៏បានដោះស្រាយបញ្ហាផ្សេងៗដែលបានកើតឡើងពាក់ព័ន្ធទៅនឹងបញ្ហានីតិវិធី។ បន្ថែមទៀតនេះ យើងនឹងពិនិត្យមើលជំហានផ្សេងៗដើម្បីឈានទៅដល់សវនាការលើអង្គសេចក្តី។ តើលោកអាចប៉ាន់ប្រមាណបានទេអំពីរយៈពេលសរុបនៃថ្ងៃសវនាការលើអង្គសេចក្តីដែលត្រូវការចាំបាច់សម្រាប់បញ្ចប់សវនាការ០០២/០២?

[១០:១៥:២៧]

**លោក ឌេល លីសាក់៖**

ការប៉ាន់ប្រមាណដែលយើងបានផ្តល់ជូនលោកចៅក្រមនោះ គឺថាផ្អែកទៅលើនីតិវិធី ទៅលើភស្តុតាងដែលយើងត្រូវការប្រហែលជា១២ ឬ១៨ខែ។ យើងមិនមានភាពជាក់លាក់នោះទេ ពីព្រោះថា យើងមិនដឹងថាមានសាក្សីប៉ុន្មានដែលមេធាវីការពារក្តីស្នើ។ ថាតើមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវស្នើចំនួនប៉ុន្មាន។ យើងខ្ញុំបានផ្តល់នូវចំនួនប៉ាន់ប្រមាណ រយៈពេលប៉ាន់ប្រមាណនេះគឺថា សវនាការនោះអាចនឹងបញ្ចប់បាន។ គឺថាបើយើងមើលរយៈពេលដែលយើងស្មានថា ៩៦ថ្ងៃនេះ គឺថាដូចដែលលោកចៅក្រមមានប្រសាសន៍គឺថាអាចនឹងត្រូវប្រើពេលបន្ថែមនៅពេលដែលមានសាក្សីបន្ថែម ហើយនិងសវនាការលើឯកសារជាដើម។

ហើយនៅក្នុងសំណើរបស់យើងហ្នឹងគឺថាអាចយើងបញ្ជាក់ថានឹងត្រូវការពេលខ្លីក្នុងការសវនាការលើឯកសារ ប៉ុន្តែសំណើរបស់យើងប្រសិនបើត្រូវបានអនុម័តនោះ គឺថាចាប់ពីយើងអាចនឹងថាត្រូវចាប់ផ្តើមសវនាការវគ្គ០០២ហ្នឹងបានដូចដែលយើងបញ្ជាក់ហ្នឹង។ គឺថាឯកសារទាំងពីរដែលបានយើងស្នើចំពោះរឿងក្តី០០២/០២ នឹងត្រូវបានយល់ស្របដូចជាករណីស-២១ សហករណ៍ត្រាំកក់។ ហើយឯកសារទាំងអស់ទាក់ទងទៅនឹងបញ្ហានេះ យើងត្រូវបានស្នើចំពោះទីតាំងទាំងពីរហ្នឹងគឺត្រូវបានទទួលយកអស់ហើយ។ ហើយឯកសារដែលនៅសេសសល់ជាឯកសារប្រភេទដូចគ្នាបេះបិទដែលអាចនឹងតុលាការប្រកាសទទួលស្គាល់ប្រើជាភស្តុតាង។

[១០:១៧:១៧]

ខ្ញុំអាចឆ្លើយថានឹងត្រូវប្រើពេលសម្រាប់សវនាការលើឯកសារ ក៏ប៉ុន្តែនឹងត្រូវពេលខ្លីជាងដែលយើងប្រើនៅក្នុងសវនាការ ០០២/០១នោះបាទ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បញ្ហាពេលវេលាចាំបាច់សម្រាប់ការពិនិត្យទៅលើឯកសារសម្រាប់ការបង្ហាញឯកសារ ក៏ដូចជាពេលវេលាចាំបាច់សម្រាប់ការស្តាប់ចម្លើយសាក្សីនឹងមានការប្រែប្រួល អាស្រ័យទៅតាមសមាសភាពនៃក្រុមប្រឹក្សាជំនុំជម្រះដែលនឹងកាត់សេចក្តីក្នុងសំណុំរឿងបន្ទាប់មកនេះ។ ប្រសិនបើជាក្រុមប្រឹក្សាជំនុំជម្រះថ្មី -- បើតាមពីម្សិលមិញនោះ ខ្ញុំយល់ថាត្រូវមានការពិនិត្យមើលឡើងវិញជាច្រើន។ ដូច្នេះពេលវេលាចាំបាច់នេះ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ទេថា លោកធ្វើការគណនារវាងជម្រើសទី១ដែលថាយើងមានក្រុមប្រឹក្សាជំនុំជម្រះដដែល ហើយនិងជម្រើសទី២មានក្រុមប្រឹក្សាជំនុំជម្រះថ្មី។ លោកមានបានពិចារណាអំពីចំណុចនេះទេ លោកមានបានសិក្សាអំពីបញ្ហានេះទេ ថាមានអាចមានជម្រើសពីរបែបនេះនោះ?

**លោក ឌេល លីសាក់៖**

យើងមិនបានធ្វើគណនាអំពីសេណារីយ៉ូ ថាតើការជំនុំជម្រះប្រើពេលប៉ុនណាទេ ដោយប្រើអង្គជំនុំជម្រះទី២។ ប៉ុន្តែយើងបានពិនិត្យមើលបញ្ហាថាអាចនឹងមានការងារច្រើនណាស់នៅពេលដែលថាយើងដាក់សំណើហ្នឹង គឺថាអាចនឹងមានប្រសិទ្ធភាព ហើយនិងឆាប់រហ័សជាងក្នុងវិសាលភាពដែលយើងប្រើអង្គជំនុំជម្រះសាលាដំបូងដដែល ដែលចៅក្រមភាគច្រើនទាំងអស់ដែលបានដឹង យល់អំពីដំណើរការនីតិវិធី ហើយនិងភស្តុតាង និងអ្វីផ្សេងៗទៀតនេះ។ មិនមានចំណោទអ្វីទេលោកចៅក្រមឡាវែន៍ គឺថាតាមយើងគិត គឺថាបើសិនជាមានអង្គជំនុំជម្រះទី២ថ្មីនោះនឹងប្រើពេលច្រើនជាងឆ្ងាយជាងអង្គជំនុំជម្រះបច្ចុប្បន្នដែលមាននេះ។

[១០:១៩:៥០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំមានសំណួរផ្សេងទៀត ក៏ប៉ុន្តែខ្ញុំមិនដឹងថាតើជាពេលសមស្របដែរឬទេដែលត្រូវសួរសហព្រះរាជអាជ្ញានៅពេលនេះអំពីជំហានចាំបាច់មុនពេលដែលយើងឈានចូលទៅដល់ដំណាក់កាល លើអង្គសេចក្តី។ ក៏ប៉ុន្តែខ្ញុំគិតថា សូមផ្តល់ឱកាសឲ្យភាគីឡើងមានមតិជាទូទៅអំពីរយៈពេលនៃសវនាការសិន

ជាពិសេសអំពីបញ្ហាសាក្សី និងភស្តុតាង ដែលនឹងត្រូវស្តាប់នៅពេលខាងមុខនេះ។

ដូច្នេះ សូមលោកប្រធានមេត្តាពិចារណា។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតរ៉ាយច៍!

**ចៅក្រម ស៊ីលវៀ ខាតរ៉ាយច៍៖**

សូមអរគុណលោកប្រធាន។ នេះជាការងាររបស់សហព្រះរាជអាជ្ញាដើម្បីឲ្យមានលក្ខណៈសុទិដ្ឋិនិយមនៅក្នុងរយៈពេលដំណើរការ។ ខ្ញុំសូមទទួលស្គាល់អំពីការដែលសុទិដ្ឋិនិយមនេះ។ ម្សិលមិញសហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជាក់ថា ប្រហែលជាត្រូវប្រើពេល ពីរ ឬបីឆ្នាំសម្រាប់រយៈពេលទាំងមូលនៃការជំនុំជម្រះ។ ដូច្នេះ យើងសូមឲ្យមានការច្បាស់លាស់លើចំណុចនេះ។ នៅក្នុងសំណើរបស់លោក ពីសហព្រះរាជអាជ្ញា លោកប៉ាន់ប្រមាណថាប្រហែលជាសាក្សី៩០ ម្នាក់មួយថ្ងៃ គឺយើងត្រូវប្រើពេល៩០ថ្ងៃ។ ផ្អែកតាមការគណនាពេលវេលាដែលថា ការជំនុំជម្រះនឹងប្រើពេល១២ ទៅ១៨ថ្ងៃ ថាតើត្រូវដាក់បញ្ចូលទាំងមេធាវីការពារក្តី សហមេធាវីនាំមុខ តើយើង -- តើបានដាក់បញ្ចូលថ្ងៃសម្រាកផ្លូវការប្រហែលជា២០ថ្ងៃទេ នៅឆ្នាំក្រោយនោះ?

[១០:២១:៤៩]

**លោក ឌេល លីសាក់៖**

យើងបានទទួលស្គាល់ គឺថាអាចនឹងមានការឈប់សម្រាកថ្ងៃបុណ្យជាដើម។ ប៉ុន្តែចង់ជម្រាបជូនឲ្យច្បាស់ថា សហព្រះរាជអាជ្ញាអន្តរជាតិដែលបានបញ្ជាក់ពីម្សិលមិញ ពេលដែលគាត់និយាយថា ពីរ ឬបីឆ្នាំ – ពីរឆ្នាំ គាត់និយាយថាចាប់ពីពេលឥឡូវនេះទៅ រហូតដល់មានសាលក្រមចេញ។ បីឆ្នាំដែលយើងទទួលស្គាល់ថា ដែលលោកស្រី លោក លោកស្រីចៅក្រម គឺថាយើងឃើញមានបញ្ហាមិនជាក់លាក់ ហើយសំណើនេះគឺថាបញ្ជាក់បែបនោះគឺថាយើងឃើញឧបសគ្គមួយចំនួន ប៉ុន្តែត្រូវគោរពទៅតាមគោលការណ៍នាប់របស់នោះឯង ប្រសិនបើយើងបាត់ពេលមួយចំនួន ដែលយើងបានជួបប្រទះពីមុននោះ ពេលនោះគឺថាយើងមិនអាចសម្រេចបាន បញ្ចប់បាននៅក្នុងពេលដែលកំណត់នោះទេ។

**ចៅក្រម ស៊ីលវៀ ខាតរ៉ាយច៍៖**

អ៊ីចឹងលោកផ្អែកលើបញ្ហាដែលថា សុខភាពអន់ខ្សោយរបស់ជនជាប់ចោទ ហើយនិង -- ហើយមានការអូសបន្លាយនីតិវិធីខ្លះ ដោយសារបញ្ហាផ្សេងៗ ប៉ុន្តែយើងពិនិត្យមើលទៅតាមអ្វី សំណើបញ្ជី

សំណើរបស់សាក្សី របស់សហព្រះរាជអាជ្ញា តើយើងមើលភស្តុតាងដែលបានជំនុំជម្រះនោះ ប្រហែលជា៥០ភាគរយនៃសាក្សី និងអ្នកជំនាញ គឺត្រូវដាក់មកពីភាគីផ្សេងៗ ប៉ុន្តែក្នុងករណីនេះ គឺថាអាចនឹងចំនួនហ្នឹង គឺកើនពីរដង។ តើតាមការវាយតម្លៃត្រួសៗរបស់លោកហ្នឹងយ៉ាងដូចម្តេចដែរ?

**លោក ឌេល លីសាក់៖**

តាមអ្វីដែលខ្ញុំពិនិត្យទៅលើ -- ហើយចំនួនរបស់ខ្ញុំនោះ ខុសពីលោកស្រីចៅក្រមគិត។ គឺថាយើងមានបន្ទុកក្នុងការបង្ហាញភស្តុតាង។ សហព្រះរាជអាជ្ញា គឺកាតព្វកិច្ចនេះ គឺយើងមើលសាក្សីរួមទាំងអស់ដែលយើងបានស្តាប់រួចហើយ គឺថាយើងពិនិត្យមើលសាក្សីដែលបានស្តាប់ គឺថាមានចំនួនខ្ពស់ជាងហ្នឹង។ គឺថាមិនអ្វីចម្លែកទេ គឺថាដោយថាយើងមានបន្ទុកក្នុងការបង្ហាញភស្តុតាង គឺថាយើងមើលទីតាំងបទឧក្រិដ្ឋទាំងអស់នេះ គឺថាយើងឃើញមានសាក្សីខ្លះសំខាន់ជាងសាក្សីផ្សេង។ ហើយខ្ញុំមិនគិតថា វាមានចំនួនកើន និងចំនួនច្រើនទេ ប៉ុន្តែគឺអាចមានបន្ថែម គឺថាមានប្រហាក់ប្រហែល ប៉ុន្តែយើងនឹងត្រូវរង់ចាំមើលការពិត។ ហើយភាគច្រើននោះ គឺថាអាស្រ័យទៅលើសេចក្តីសម្រេចរបស់ចៅក្រមដែលត្រូវធ្វើសវនាការលើរឿងក្តីនេះ។ ហើយអាចនឹងមានសំណើបន្ថែមពីភាគីសហព្រះរាជអាជ្ញា ឬក៏ភាគីផ្សេង។ ប៉ុន្តែខ្ញុំមិនបដិសេធថាមិនមានពេលវេលាបន្ថែមច្រើនជាងអ្វីពីយើងស្នើ៩៦ថ្ងៃនោះទេ។

[១០:២៤:២៨]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ខ្ញុំនឹងផ្អែកទៅលើ៥០ភាគរយ ដែលខ្ញុំបានលើកខាងដើមនោះ នៅក្នុងកថាខណ្ឌមួយ នៅក្នុងសំណើរបស់លោកនោះ លោកនិយាយថា អង្គជំនុំជម្រះបានស្តាប់សាក្សី៩២ គឺថា២០ ដែលស្នើឡើងដោយលោក នួន ជា ហើយ២៣ ដោយលោក ខៀវ សំផន ដែលថាទាក់ទងទៅនឹងការជំនុំជម្រះទៅលើសវនាការដែលបានធ្វើក្នុងរឿងក្តី០០២/០១។ ប៉ុន្តែ៩២នេះ គឺយើងពិនិត្យមើលចំនួនប្រហាក់ប្រហែល។ ហើយបើយើងពិនិត្យមើលរឿងក្តី០០២/០១ យើងពិនិត្យឃើញថា បញ្ហាទាក់ទងទៅនឹងស-២១ ជើងឯក ហើយនិងព្រៃសនោះ ភស្តុតាងនៅក្នុងការជំនុំជម្រះហ្នឹងប្រើពេលតិចជាង៦ខែទេ ចំពោះផ្នែកទាំងអស់នេះ ដែលខ្ញុំបានលើកខាងដើមនូវភស្តុតាងបង្ហាញពីអង្គហេតុទាំងអស់នោះ។ បើយើងអាចនឹងធ្វើលឿនជាងហ្នឹងគឺថាមានសាក្សីតិចជាង ក៏ប៉ុន្តែយើងត្រូវស្តាប់ភស្តុតាងឡើងវិញទាំងអស់ទេ ឬក៏មិនចាំបាច់ទេ?

[១០:២៥:៥១]

**លោក ខេល លីសាក់៖**

ខ្ញុំសូមបញ្ជាក់បញ្ហាពីរ។ ទី១គឺទាក់ទងទៅនឹងចំនួនមេធាវីរបស់ នួន ជា -- អ៎! សាក្សីដែលស្នើឡើងដោយ នួន ជា និង ខៀវ សំផន នោះគឺថា មិនថាទាំងអស់នោះសុទ្ធតែពួកគាត់ស្នើនោះទេ ប៉ុន្តែភាគីច្រើនអ្នកទាំងអស់នោះក៏សហព្រះរាជអាជ្ញាក៏បានស្នើសាក្សីទាំងអស់នោះដែរ មួយចំនួននោះដែរ។ បើយើងមើលសាក្សីទាំងនោះដែលមិនត្រូវបានស្នើឡើងនៅលើបញ្ជីរបស់យើង គឺថាមានភាគរយតិចទេនៅក្នុងចំនួនសាក្សីនោះ។ និយាយអំពីមន្ទីរស-២១ មានការលំបាកក្នុងការប្រៀបធៀបទៅនឹងសវនាការជំនុំជម្រះវគ្គទី១នោះ គឺថាយើងប្រើពេលមួយចំនួនច្រើន គឺមួយចំនួនយើងត្រូវប្រើស្តាប់សក្ខីកម្មរបស់ ឌុច តែយើងមិនត្រូវស្តាប់សក្ខីកម្មទាំងអស់នោះឡើងវិញទេ គឺថា ពីព្រោះថា ឌុច បានធ្វើសក្ខីកម្មនៅក្នុងរឿង០០២/០១ ហើយទីនេះ ហើយយើងមិនត្រូវ -- ហើយខ្ញុំមិនមានតួលេខទេ ប៉ុន្តែគាត់បានប្រើពេលមួយចំនួនថ្ងៃ គឺថានៅក្នុងរឿងក្តី០០២/០១ យើងមិនត្រូវធ្វើឡើងវិញទេ។

[១០:២៧:០៦]

មានបញ្ហាផ្សេងទៀតដែលខ្ញុំគិតថាវាខុសដែរ។ គឺថាការផ្តោតអារម្មណ៍លើការជំនុំជម្រះលើកក្រោយនេះ គឺនិយាយអំពីតួនាទីរបស់ជនជាប់ចោទថា តើគេបញ្ជូនជនរងគ្រោះទៅស-២១ នោះថា តើរបៀបណា? អ្នកណាជាអ្នកសម្រេច? វិធីណា? យើងនឹងពិនិត្យមើលការងារបែបនេះ គឺមិនពិនិត្យការប្រព្រឹត្តទៅនៅក្នុងផ្ទៃក្នុងនៅស-២១ទេ។ ប៉ុន្តែខ្ញុំសូមជម្រាបអង្គជំនុំជម្រះ និងភាគីផងដែរថា នៅពេលដែលយើងដាក់បញ្ចូលមន្ទីរស-២១ហ្នឹង គឺថាអង្គជំនុំជម្រះតម្រូវឲ្យយើងខ្ញុំថា ឲ្យយើងមើល ស្តាប់សក្ខីកម្មតែពី ឌុច ប៉ុន្តែខ្ញុំគិតថាទីតាំងបទឧក្រិដ្ឋនេះ គឺថានឹងត្រូវជំនុំជម្រះឲ្យបានឆាប់រហ័សតាមដែលអាចធ្វើទៅបាន។ ប៉ុន្តែភាគីផ្សេងទៀតអាចនឹងដាក់សំណើ ប៉ុន្តែអាចនឹងប្រើពេលច្រើនជាង៩០ថ្ងៃដែលយើងស្នើ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

នៅក្នុងករណីដែលលោកស្នើថា ប្រាំថ្ងៃសម្រាប់សក្ខីកម្មរបស់គាត់ គឺ២៥ម៉ោង។ ដូច្នេះគាត់ក៏ជាសាក្សីដ៏សំខាន់ដែរ ឌុច នោះ។ ហើយនិងទាក់ទង -- យើងមើលថាអាចនឹងខ្លីជាងសាក្សីផ្សេងទៀតតិចទេ ហើយយើងឃើញថាអាចមានលក្ខណៈច្បាស់លាស់ជាងចំពោះព្រឹកនេះ។ ចំពោះសាក្សីផងដែរ ហើយអាចនឹងគេមានទស្សនៈផ្ទាល់របស់ពួកគេ។ តើលោកទទួលស្គាល់ដែរឬទេថា សំណួរនេះគឺចេញតែពីសហព្រះរាជអាជ្ញាទេ? គឺមិនបានដឹងពេលវេលា ឬក៏សាក្សីផ្សេងទៀតដែលត្រូវការដាក់បញ្ចូល

ដោយសហមេធាវីនាំមុខ ឬក៏មេធាវីការពារក្ដីទេ។ ហើយលោកមិនស្នើថា រយៈពេល៩០ថ្ងៃហ្នឹងគឺជាសំខាន់ ប៉ុន្តែអាចនឹងមានរយៈពេលបន្ថែមតទៅទៀត ហើយផ្សេងទៀត ហើយការប៉ាន់ប្រមាណនេះគឺផ្អែកតែអង្គជំនុំជម្រះដែលមានបច្ចុប្បន្ននេះ គឺថាមិនត្រូវប្រើសម្រាប់អង្គជំនុំជម្រះទី២ទេ។ អ៊ីចឹង ខ្ញុំឃើញលោកងក់ក្បាល។ តើអ៊ីចឹងដែរឬទេសហព្រះរាជអាជ្ញា?

**លោក ឌេល លីសាក់៖**

គឺពិតដូច្នោះមែនលោកស្រីចៅក្រមបាទ។

[១០:២៩:៤៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកតំណាងសហព្រះរាជអាជ្ញា -- លោកសហព្រះរាជអាជ្ញារងអន្តរជាតិ។ បាទ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយដែរ ឥឡូវយើងសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីដំណើរការកិច្ចប្រជុំពិភាក្សារបស់យើង។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣០ នាទី ដល់ម៉ោង ១០:៥១ នាទី)*

[១០:៥១:៥៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

បាទ យើងតកិច្ចប្រជុំពិភាក្សាតទៅទៀត។ ហើយមុនផ្ដល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំសូមសួរសំណួរមួយចំនួនទៅលោកសហព្រះរាជអាជ្ញារងអន្តរជាតិ។ ខ្ញុំបានស្ដាប់នូវបទបង្ហាញរបស់លោកអម្បាញ់មិញនេះនូវការស្នើសុំឲ្យការដែលអង្គជំនុំជម្រះដែលនឹងទទួលភារកិច្ចក្នុងការជំនុំជម្រះសំណុំរឿង ០០២/០២ នាពេលខាងមុខនេះ នូវបទចោទប្រកាន់មួយចំនួនដោយទម្លាក់បទចោទប្រកាន់មួយចំនួនចោលហើយបញ្ហានេះគឺបានសម្ដែងឡើងនៅក្នុងឯកសារE301/2 ផងដែរដែលសហព្រះរាជអាជ្ញាបានផ្ញើជូនមកអង្គជំនុំជម្រះសាលាដំបូង។ ខ្ញុំបានពិនិត្យមើលនូវកថា

ខណ្ឌ៦៣ នៃសំអាងហេតុសេចក្ដីសម្រេចរបស់តុលាការកំពូលចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ បានបង្ហាញថាពាក់ព័ន្ធនឹងភាពចាំបាច់ដើម្បីធានានូវភាពយុត្តិធម៌បានសមស្របសំណុំរឿងនៃការបញ្ជូនរឿងទៅជំនុំជម្រះដែលមានលក្ខណៈធំធេង តុលាការ អាយ.ស៊ី.ធី.វ៉ាយ និងតុលាការ អេស.ស៊ី.អេស.អិល គីសេរ៉ាឡេអូន និងតុលាការយូហ្គោស្លាវី បានវិសោធនកម្មវិធានផ្ទៃក្នុងរបស់គេដើម្បីអនុញ្ញាតឲ្យអង្គជំនុំជម្រះសាលាដំបូងស្នើសុំទៅអយ្យការកាត់បន្ថយ ឬបង្គាប់តាមគំនិតផ្ដួចផ្ដើមរបស់ខ្លួនក្នុងការកាត់បន្ថយនូវបទចោទប្រកាន់។ ហើយនៅក្នុងនោះគឺខ្ញុំសូមបញ្ជាក់ថានៅក្នុងការអនុវត្តច្បាប់ដែលយើងទទួលយកសំណុំរឿង០០២ មកជំនុំជម្រះនេះគឺអង្គជំនុំជម្រះបានអនុវត្តទៅតាមវិធាន៧៩ នៃវិធានផ្ទៃក្នុងត្រង់អនុវិធាន១ អង្គជំនុំជម្រះសាលាដំបូងទទួលបណ្ដឹងដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត ឬតាមសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ។ ហើយនៅក្នុងសំណុំរឿង០០២នេះអង្គជំនុំជម្រះសាលាដំបូងបានទទួលយកមកជំនុំជម្រះតាមសាលដីការបស់អង្គជំនុំជម្រះសាលាដំបូង។

[១០:៥៤:៤៤]

សំណួរពាក់ព័ន្ធគឺសួរថា តើសហព្រះរាជអាជ្ញាដែលមានលទ្ធភាពទម្លាក់បទចោទប្រកាន់ ឬឧក្រិដ្ឋកម្ម ទីកន្លែងឧក្រិដ្ឋកម្ម ឬផ្នែកខ្លះនៃបទចោទប្រកាន់នៅចំពោះមុខអង្គជំនុំជម្រះនេះ តើប្រព្រឹត្តទៅតាមអង្គច្បាប់ណា? តើយើងផ្អែកលើច្បាប់ណា ដែលនាំឲ្យអង្គជំនុំជម្រះសាលាដំបូងនឹងអាច ឬព្រះរាជអាជ្ញាខ្លួនឯងអាចទម្លាក់ចោលនូវផ្នែកខ្លះនៃបទប្រកាន់ដោយមិនចាំបាច់ជំនុំជម្រះ?

បញ្ហាពីរខុសគ្នា។ ១) ទម្លាក់បទចោទសំអាងលើអង្គច្បាប់ជាមូលដ្ឋាន, ទី២) ផ្នែកដែលនៅសល់អង្គជំនុំជម្រះមិនមានលទ្ធភាពក្នុងការបន្តការជំនុំជម្រះនាពេលអនាគត។ រឿងខុសគ្នា។ ច្បាប់កម្ពុជាមិនមានទេនូវការទម្លាក់បទចោទប្រកាន់។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ មូលដ្ឋាននៃការស្នើសុំរបស់យើង គឺសេចក្ដីសម្រេចរបស់តុលាការកំពូលបានទទួលស្គាល់ថា នីតិវិធីហ្នឹងមានចែង អាចឲ្យយើងធ្វើទៅបាន។ ហើយខ្ញុំយល់ថាភាគីមួយចំនួនអាចមិនយល់ស្របជាមួយនឹងការបកស្រាយនេះ។ ក៏ប៉ុន្តែតុលាការកំពូល អង្គជំនុំជម្រះតុលាការកំពូលនៅពេលនេះផ្ដល់ជម្រើសទៅដល់អង្គជំនុំជម្រះសាលាដំបូង។ បញ្ហានេះវាស្មុគស្មាញ យើងមិនមែនព្យាយាម ហើយយើងមិនស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការសម្រេចលើបញ្ហានេះទេ។ ខ្ញុំជឿថា បញ្ហាហ្នឹងវាខ្លី ក៏ប៉ុន្តែចំពោះឧក្រិដ្ឋទីតាំងឧក្រិដ្ឋកម្ម ហើយនិងការកំណត់ទៅលើបញ្ហាស្មុគស្មាញ។

ចំណុចទាំងអស់នេះ គឺតុលាការអាចពិចារណា តុលាការអាចបំបែកទីតាំងឧក្រិដ្ឋកម្មមួយចំនួនមិនដាក់បញ្ចូលមកក្នុងការជំនុំជម្រះនេះ។ ក៏ប៉ុន្តែចំណុចនេះយើងត្រូវលើកឡើងបញ្ហានេះបន្តទៀត។ តុលាការកំពូលលើកឡើងវិធីសាស្ត្រចំនួនពីរក្នុងការដោះស្រាយជំនុំជម្រះទៅលើទីតាំងឧក្រិដ្ឋកម្មមួយចំនួន មិនមែនថាយើងមិនយកមកជំនុំជម្រះនោះទេ។ ខ្ញុំយល់នីតិវិធីរបស់កម្ពុជាមិនមានទេ ហើយប្រហែលជាថៅក្រមតុលាការកំពូលផ្អែកទៅលើយុត្តិសាស្ត្រ ឬក៏ច្បាប់បង្កើតឡើងក្នុងកម្រិតអន្តរជាតិ។

នៅក្នុងកថាខណ្ឌចេញមកពីសេចក្តីសម្រេចរបស់តុលាការកំពូល ដែលក្នុងនោះផ្តល់ជាជម្រើសមួយចំនួន។ កថាខណ្ឌ៦១ទៅដល់៦៣នៃសេចក្តីសម្រេចចុះខែវិច្ឆិកា គឺបានលើកឡើងអំពីបញ្ហាទាំងអស់នេះ។

[១០:៥៨:៣០]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមបន្ថែម ដើម្បីពន្យល់ជំហររបស់យើងខ្ញុំ។ ជំហររបស់យើងខ្ញុំ គឺការជំនុំជម្រះសំណុំរឿង ០០២/០២ គួរតែក្តោបរួមបទចោទទាំងអស់។ នៅពេលដែលយើងមើលដីកាដំណោះស្រាយនៅក្នុងផ្នែកនៃសេចក្តីសម្រេចនៃដីកាដំណោះស្រាយនោះ អ្វីដែលលើកឡើងក្នុងនោះ គឺថាបទចោទតាមផ្លូវច្បាប់ជាក់លាក់។ យើងទទួលស្គាល់ថាវាមានលក្ខណៈគ្រប់គ្រាន់ ប្រសិនបើយើងដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្ម និងបទចោទទាំងអស់ដែលមាននៅក្នុងដីកាដំណោះស្រាយ។ អ្វីដែលដីកាដំណោះស្រាយបញ្ជាក់យ៉ាងច្បាស់នោះគឺថាឧក្រិដ្ឋកម្មដែលសចោទប្រកាន់ទៅលើជនជាប់ចោទគឺកើតឡើងនៅទូទាំងប្រទេស គឺដីកាដំណោះស្រាយចេញមកពីសាលដីការបស់អង្គបុរេជំនុំជម្រះ ដែលក្នុងនោះទទួលស្គាល់ជនរងគ្រោះមិនបានដាក់ឈ្មោះទីតាំងឧក្រិដ្ឋកម្មមួយចំនួន ហើយមិនបានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ។

អង្គបុរេជំនុំជម្រះបានលើកឡើងថា តាមដីកាដំណោះស្រាយ ឧក្រិដ្ឋកម្មដែលបានកើតឡើងនោះគឺកើតឡើងនៅទូទាំងប្រទេស។ យើងព្យាយាមបង្ហាញករណីហ្នឹងនៅក្នុងវគ្គទី២ ហើយដោយយើងមិនផ្តោតទៅលើកម្រិតថ្នាក់អន្តរជាតិ ដែលគេលើកឡើងទៅលើបញ្ហាមួយចំនួននោះទេ។ យើងគ្រាន់តែចង់បង្ហាញឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ទៅលើប្រជាជន៦លានទៅ៧លាននាក់ ហើយយើងធ្វើយ៉ាងណាឲ្យបទចោទឧក្រិដ្ឋកម្ម ទីតាំងឧក្រិដ្ឋកម្មទាំងអស់នោះជាតំណាងទៅលើគោលនយោបាយនៃរបបនោះ។ បន្ថែមពីលើនេះ រឿងនេះ សំណុំរឿងនេះ គឺវាខុសពីសំណុំរឿងនៅក្នុងប្រទេសកម្ពុជា មិនថានៅប្រទេសផ្សេងទៀតនោះទេ។ ទំហំ និងវិសាលភាពគឺមានលក្ខណៈខុសគ្នា ហើយតួនាទី

របស់ជនរងគ្រោះក៏មានលក្ខណៈសំខាន់ដែរ។ ដូចបញ្ជាក់នៅក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ។ ហើយគឺចំពោះសំណង គឺគ្រាន់តែជាសំណងតំណាងទៅអ្វីដែលកើតឡើងចំពោះជនរងគ្រោះតែប៉ុណ្ណោះ ដើម្បីឱ្យគេទទួលស្គាល់ថា ជនរងគ្រោះនោះគឺជាជនរងគ្រោះនៃឧក្រិដ្ឋកម្មទូទាំងប្រទេស មិនមែនទៅលើទីតាំងមួយណាជាក់លាក់នោះទេ។

[១១:០០:៥០]

ហេតុដូច្នេះហើយ យើងជឿថាសេចក្ដីសម្រេចរបស់តុលាការកំពូល និងយុត្តិសាស្ត្រនានាដែលលើកឡើងអំពីបញ្ហានេះ គឺយើងគួរតែដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មមួយចំនួនដែលវាតំណាងទាំងអស់ ហើយយើងចង់បញ្ជាក់ឱ្យបានច្បាស់ថា សំណើរបស់យើងខ្ញុំគឺបន្ទាប់ពីជំនុំជម្រះវគ្គទី២នេះទៅ បានន័យថាវានឹងបញ្ចប់កិច្ចជំនុំជម្រះទាំងអស់តែម្ដង។ ហើយការធ្វើដូច្នេះ គឺវាបំពេញទៅតាមផែនការរបស់រាជរដ្ឋាភិបាលកម្ពុជា និងម្ចាស់ជំនួយ។ បានន័យថាបន្ទាប់ពីហ្នឹងចប់បេសសកម្មរបស់ អ.វ.ត.ក។ ដូច្នេះអ្វីដែលយើងស្នើសុំគឺនៅពេលបញ្ចូលដូច្នេះ វាក្ដោបរួម និងបញ្ចប់រឿងរបស់យើងត្រឹមនោះតែម្ដង។

**ប្រធានអង្គជំនុំ៖**

អរគុណ។ ប៉ុន្តែបញ្ហាដែលខ្ញុំសួរ គឺសួរផ្លូវច្បាប់។ ខ្ញុំយល់ ហើយអរគុណដែលបានធ្វើការជ្រើសរើសនូវបណ្ដាអង្គហេតុ នូវទីតាំងឧក្រិដ្ឋកម្មមួយចំនួនដាក់បញ្ចូនមកនេះ។

សំណួរខ្ញុំសួរថា ផ្លូវច្បាប់ថាតើផ្អែកលើផ្លូវច្បាប់យ៉ាងដូចម្ដេចដើម្បីធ្វើការងារនេះបាន? ទី១។ ទី២ថាតើវិធីសាស្ត្រ ឬក៏នីតិវិធីនឹងប្រព្រឹត្តទៅដូចម្ដេចនៅក្នុងការទម្លាក់ចោលបទមួយចំនួនចេញពីសាលដីកាបញ្ជូនរឿងឱ្យជំនុំជម្រះរបស់អង្គបុរេជំនុំជម្រះ? និយាយតែផ្លូវច្បាប់ប៉ុណ្ណោះ។ ដោយខ្ញុំបានឃើញនៅក្នុងវិធាន៧៣ស្ទួន នៃតុលាការ អាយ.ស៊ី.ធី.វ៉ាយ ត្រង់ចំណុច(យ) បានសរសេរពីបញ្ហានេះ។ “បន្ទាប់ពីស្ដាប់រដ្ឋអាជ្ញាដើម្បីជាប្រយោជន៍នៃការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌និងឆាប់រហ័ស អង្គជំនុំជម្រះសាលាដំបូងជាស្នើឱ្យរដ្ឋអាជ្ញាកាត់បន្ថយបទចោទដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងអាចកំណត់ចំនួនទីតាំងឧក្រិដ្ឋកម្ម ឬហេតុការណ៍នៅក្នុងការចោទប្រកាន់មួយ ឬច្រើន។” បាទមានហូរហែចប់មក។

[១១:០២:៥៥]

ខ្ញុំចង់បញ្ជាក់ថា អាយ.ស៊ី.ធី.វ៉ាយ ដើម្បីអនុវត្តនូវការដកចេញ ឬក៏ទម្លាក់បទចោទបាន គាត់បានសរសេរចូលនៅក្នុងវិសោធនកម្មនៅក្នុងវិធានផ្ទៃក្នុង អាយ.ស៊ី.ធី.វ៉ាយ។ ចំណែកឯវិធានផ្ទៃក្នុង

របស់កម្ពុជា ខ្ញុំមើលមិនឃើញទេ រហូតដល់ម៉ោងនេះ ខ្ញុំចូលរួមប្រាំឆ្នាំ ប្រាំមួយឆ្នាំនេះ គឺមិនបានឃើញទេ ហើយមិនដែលអ្នកណាលើកមកពិភាក្សាទេ។ សំណួរបញ្ហាទី១ គឺទិដ្ឋភាពផ្លូវច្បាប់ តើយើងផ្អែកលើច្បាប់ណាដើម្បីដោះស្រាយបញ្ហាហ្នឹង? ទី២ តើនីតិវិធីយើងគួរប្រព្រឹត្តទៅដូចម្ដេច? បញ្ហានេះវាប្រឈមដល់អង្គជំនុំជម្រះសាលាដំបូង ពីព្រោះបញ្ហាលោកសហព្រះរាជអាជ្ញាបានបញ្ចេញនេះ គឺសារព័ត៌មានបានចេញព្រោងព្រាតហើយ។ អ្នកដែលផ្ទាល់បញ្ហាដែលមិនអាចចេញព័ត៌មាន គឺអង្គជំនុំជម្រះសាលាដំបូងខ្លួនឯង។ ពីព្រោះក្នុងនាមចៅក្រមមិនអាចនិយាយជាសាធារណៈបានទេ។

[១១:០៣:៥៩]

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ ជាបឋម យើងទទួលស្គាល់ថាសំណើសុំដែលយើងធ្វើឡើង គឺអាស្រ័យទៅលើសេចក្ដីសម្រេចចុងក្រោយរបស់អង្គជំនុំជម្រះសាលាដំបូងដែលត្រូវការពិចារណាសម្រេចទៅលើវិសាលភាពនៃការជំនុំជម្រះរបស់យើង។ ប៉ុន្តែយើងខ្ញុំសូមបញ្ជាក់ថាវិធាន និងការអនុវត្តរបស់សាលាក្ដីអន្តរជាតិដទៃៗទៀត គឺជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ដូច្នេះការអនុវត្តទាំងអស់នោះគឺវាមានលក្ខណៈស៊ីសង្វាក់គ្នាដើម្បីឱ្យយើងអាចយកមកអនុវត្តដោះស្រាយទៅលើសំណុំរឿងស្មុគស្មាញនានា។ ដូច្នេះហើយអង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិកម្រិតអប្បបរមាទៅលើទីតាំងឧក្រិដ្ឋកម្មមួយចំនួននិងបទចោទ។ ខ្ញុំយល់ថាវិធានផ្ទៃក្នុងនៅក្នុងប្រទេសកម្ពុជាមិនបានចែងអំពីករណីហ្នឹង។ វិធានរបស់សាលាក្ដីអន្តរជាតិ នៅក្នុងការបកស្រាយទៅលើបញ្ហានានានោះ គឺថាគេត្រូវមើលទៅលើមូលហេតុនៅពីក្រោយ។ ហើយដែលគេត្រូវពិចារណាទៅលើដើមបណ្ដឹងរដ្ឋប្បវេណីនីមួយៗដែលស្នើសុំសំណងផ្ទាល់របស់ខ្លួនមួយៗផងដែរ។ ហើយចំណុចហ្នឹង គឺត្រង់បញ្ហាដើមបណ្ដឹងរដ្ឋប្បវេណីនេះ មិនអាចចែង ឬក៏កំណត់ជាក់លាក់ដោយសហព្រះរាជអាជ្ញានោះទេ។ ហើយបញ្ហានេះ គឺថាបានដោះស្រាយនៅក្នុងសំណុំរឿង០០២/០១ និង០២។

ដើមបណ្ដឹងរដ្ឋប្បវេណីគាត់ចូលរួម ហើយសំណងរបស់គាត់ទទួលជាក្រុម។ អង្គបុរេជំនុំជម្រះទទួលស្គាល់អ៊ីចឹងដែរ ហើយការទទួលស្គាល់នោះ គឺជាការទទួលស្គាល់មួយត្រឹមត្រូវ។ បុគ្គលដើមបណ្ដឹងរដ្ឋប្បវេណីអាចចូលរួម ទោះបីជាពួកគាត់មិនមានឈ្មោះពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មទីតាំងមួយៗក៏ដោយ ហើយទោះបីជាពួកគាត់ហ្នឹងមិនទទួលព្យសនកម្មរងទីកន្លែងមួយៗ ក៏ពួកគាត់អាចចូលរួមផងដែរ។

[១១:០៦:០៧]

នីតិវិធីនៅក្នុងតុលាការនេះ គឺមានលក្ខណៈដោយឡែក និងពិសេស ខុសពីតុលាការជាតិ។ ដូច្នេះហើយយើងអាចយកនីតិវិធីជាតិរួមជាមួយ យកមកអនុវត្តចំពោះដើមបណ្តឹងរដ្ឋប្បវេណីដូចគ្នា។ ហើយនៅក្នុងករណីនេះ យើងដឹងហើយថាឧក្រិដ្ឋកម្មកើតឡើងទូទាំងប្រទេសទៅលើប្រជាពលរដ្ឋ។ ដូច្នេះដើម្បីជាផលប្រយោជន៍យុត្តិធម៌ វាមានលក្ខណៈសមហេតុផល ធ្វើការបកស្រាយទៅលើវិធាន ហើយអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាធ្វើការជ្រើសរើសទីតាំងឧក្រិដ្ឋកម្មមួយចំនួនយកមកបង្ហាញ។ ទោះបីជាទីតាំងឧក្រិដ្ឋកម្មបានលើកឡើងនៅក្នុងដីកាដំណោះស្រាយក៏ដោយ ប៉ុន្តែយើងមិនអាចរៀបរាប់ឈ្មោះជនរងគ្រោះទាំងអស់នោះទេ។ ដូច្នេះហើយទើបយើងស្នើសុំដូច្នេះ។ ក៏ប៉ុន្តែវាអាស្រ័យទៅលើការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ហើយប្រសិនបើវាមិនគ្រប់គ្រាន់ យើងអាចធ្វើវិសោធនកម្មដើម្បីឱ្យយើងអាចក្តោបរួមទៅលើបទចោទដែលឧក្រិដ្ឋកម្មបានកើតឡើង។ ក៏ប៉ុន្តែប្រសិនបើលោក លោកស្រីចៅក្រម គិតថាចង់ត្រូវតែធ្វើវិធានវិសោធនកម្មនោះ គឺយើងត្រូវតែធ្វើអ៊ីចឹងទៅ។ ដូច្នេះបើសិនជាចង់ឱ្យមានវិសោធនកម្ម គឺយើងមិនអាចចាប់ផ្តើមការជំនុំជម្រះរបស់យើងទេ ដរាបណា មិនទាន់មានវិសោធនកម្មនោះ។ ដូច្នេះយើងមិនចាំបាច់ធ្វើវិសោធនកម្មអ្វីនោះឡើយ តាមយើងខ្ញុំ យើងគ្រាន់តែចង់បង្ហាញអំពីគោលនយោបាយដែលកើតឡើងទូទាំងប្រទេសតែប៉ុណ្ណោះ។ ហើយដូចដែលខ្ញុំបញ្ជាក់អ៊ីចឹង ទោះបីជាឧក្រិដ្ឋកម្មកើតឡើងលើជនរងគ្រោះក៏ដោយ ក៏មិនមែនថាយើងយកឈ្មោះជនរងគ្រោះទាំងអស់ យកមកបង្ហាញនោះដែរ។ ហើយដូចដែលអង្គបុរេជំនុំជម្រះបានបញ្ជាក់និងរកឃើញនៅក្នុងសាលដីការបស់ខ្លួន។ យើងខ្ញុំយល់ឃើញថាអ្វីដែលយើងស្នើសុំនេះ វាមានលក្ខណៈជាក់ស្តែង ហើយដែលយើងអាចយកមកធ្វើការបកស្រាយ និងដើម្បីការពារទៅលើចំណុចនេះបាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោក ហ្សង់ម៉ាក ឡាវែន៍!

[១១:០៨:២៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា ដើម្បីឱ្យឈានទៅមុខបាននោះ យើងចាំបាច់ត្រូវបែងចែកបញ្ហាពីរឱ្យចេញពីគ្នា។ បញ្ហាទី១ បញ្ហាវិសាលភាពនៃការជំនុំជម្រះក្តី០០២/០២ និងបញ្ហាទី២ គឺអំពីជោគវាសនានៃបទចោទដែលនឹងមិនត្រូវបានដាក់ចូលក្នុងការជំនុំជម្រះនាពេលខាងមុខនេះ។ ដើម្បី

ចាប់ផ្តើម យើងអាចបន្តការអនុវត្តរបស់អង្គជំនុំជម្រះរហូតមកទាល់ពេលនេះ គឺថាពិនិត្យមើលថាតើត្រូវមានការចាត់វិធានការបំបែកនីតិវិធីឬក៏អត់។ ដូច្នេះវិសាលភាពនៃសំណុំរឿង០០២/០២ អាចកំណត់ដោយការចេញដីកាបំបែកបទចោទ។ ដូច្នេះ យើងត្រូវតែពិភាក្សាថាតើអ្វីដែលដាក់ចូល និងអ្វីដែលមិនត្រូវដាក់ចូលនៅក្នុងការជំនុំជម្រះក្តី។

ពាក់ព័ន្ធទៅនឹងជោគវាសនានៃបទចោទដែលនៅសេសសល់ ខ្ញុំយល់ឃើញថា អង្គជំនុំជម្រះតុលាការកំពូលបានចេញសេចក្តីចង្អុលបង្ហាញមួយចំនួន ក៏ប៉ុន្តែលោកប្រធានបានបញ្ជាក់រួចមកហើយថាការចង្អុលបង្ហាញរបស់អង្គជំនុំជម្រះតុលាការកំពូលនោះ លើកឡើងនូវបញ្ហាគតិយុត្តមួយចំនួន។ ជាបារាំង *"អ៊ីនឌិចមិន"* នេះមិនមែនបកថា "បទចោទ"ទេ, គឺបកថា "សេចក្តីសម្រេចបញ្ជូនទៅជំនុំជម្រះ"។ ហើយសេចក្តីសម្រេចបញ្ជូនទៅជំនុំជម្រះនេះគឺសំដៅទៅដល់សេចក្តីសម្រេចរបស់ចៅក្រម។ គឺនៅពេលដែលមានបញ្ហាណាមួយកើតឡើង គឺសហព្រះរាជអាជ្ញាអាចសម្រេចក្នុងការកែប្រែនូវអ្វីដែលទទួលបាននូវអាជ្ញាអស់ជំនុំរួចមកហើយ។ នេះជាសេចក្តីសម្រេចដែលធ្វើឡើងដោយចៅក្រម។ ក៏ប៉ុន្តែមានបញ្ហាជាច្រើន ដូច្នេះថ្ងៃនេះយើងមិនអាចចូលទៅពិភាក្សាស៊ីជម្រៅគ្នាឲ្យបានអស់គ្រប់ចំណុចនោះទេ។ ខ្ញុំគ្រាន់តែអាចលើកឡើងនូវចំណុចមួយចំនួនតែប៉ុណ្ណោះ។ នៅក្នុងវិធានផ្ទៃក្នុងរបស់យើងៗ មានវិធាន១០១ វិធាននេះគឺចម្លងចេញពីមាត្រា៣៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ វិធាននេះបញ្ជាក់ថាអ្វីដែលត្រូវធ្វើនៅពេលដែលសរសេរសាលក្រម គឺបង្ហាញអំពីកាតព្វកិច្ចរបស់ចៅក្រមនៅពេលដែលខ្លួនចេញសេចក្តីសម្រេច។

[១១:១១:២៣]

នៅកថាខណ្ឌ៣ នៃវិធាន១០១ បានបញ្ជាក់ថា អង្គជំនុំជម្រះត្រូវពិនិត្យលើបទ -- រាល់បទចោទនៅក្នុងដីការបញ្ជូនរឿងទៅជំនុំជម្រះ។ ជាភាសាអង់គ្លេសគឺបានបញ្ជាក់ថា បទចោទនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

នៅក្នុងសេចក្តីសម្រេចរបស់តុលាការកំពូល គឺបានយោងទៅលើសញ្ញាណមួយចំនួន ដែលត្រូវពិភាក្សាគ្នា។ ខ្ញុំកត់សម្គាល់ឃើញ ឧទាហរណ៍ដូចជាតុលាការកំពូលបានយោងទៅលើគោលការណ៍នៃការចោទប្រកាន់ជាកាតព្វកិច្ច។ មកដល់ពេលនេះគឺថា យើងអត់មានភាសាបារាំងទេនៃសេចក្តីសម្រេចរបស់តុលាការកំពូល ដូច្នេះវាមានការលំបាកសម្រាប់ខ្ញុំ។ ខ្ញុំមានចំណេះដឹងជាភាសាអង់គ្លេសតិចតួចទេ ហើយដូចជាជួនកាលទៅ ខ្ញុំដូចប្រថុយប្រថានធ្វើការបកប្រែ។ ហើយខ្ញុំសារភាពថា ខ្ញុំមិនដឹងថាតើបក

ប្រែសញ្ញាណនៃ “*ប្រូសេចឃ្យូថល លីហ្គលលីហ្សឹម*” នេះយ៉ាងម៉េចទេ ជាភាសាបារាំងនោះ។ ខ្ញុំគិតថា វាមានន័យថា “សហព្រះរាជអាជ្ញាមានកាតព្វកិច្ចក្នុងការធ្វើការចោទប្រកាន់”។ វាចោទជាបញ្ហាផងដែរ ពីព្រោះថាប្រសិនបើយើងចាត់ទុកថា ចំណុចនេះប្រព័ន្ធច្បាប់កម្ពុជានោះ ខ្ញុំសួរខ្លួនឯងថា តើវាស្របគ្នាទៅនឹងបទប្បញ្ញត្តិនៃវិធាន៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាដែរឬទេ? ដែលវិធាននេះផ្ទុះបញ្ចាំងអំពីគោលការណ៍មួយទៀតដែលមានឈ្មោះជាភាសាបារាំងថា គោលការណ៍នៃកាលានុវត្តភាពនៃការចោទប្រកាន់។ គឺមានន័យថា សហព្រះរាជអាជ្ញាមានលទ្ធភាពក្នុងការវាយតម្លៃថា តើខ្លួនត្រូវធ្វើការចោទប្រកាន់ ឬក៏ទម្លាក់ ឬក៏លើកលែងការចោទប្រកាន់? នេះគឺជាឧទាហរណ៍មួយចំនួនដែលខ្ញុំផ្តល់ជូន ខ្ញុំគិតថាប្រសិនបើយើងធ្វើការពិភាក្សាគ្នានោះគឺយើងត្រូវតែពិភាក្សាឲ្យបានប្រាកដប្រជា ហើយអង្គជំនុំជម្រះប្រហែលជានឹងផ្តល់សេចក្តីបង្ហាញអំពីអង្គច្បាប់ ដែលត្រូវពិនិត្យដោយភាគីទាំងអស់។ ហើយការពិភាក្សាគ្នានោះក៏ត្រូវធ្វើឡើងនៅក្នុងដំណាក់កាលក្រោយៗទៀត។ ដូច្នេះអាទិភាពបន្ទាន់ភ្លាមៗនេះគឺថា យើងត្រូវសម្រេចអំពីវិសាលភាពនៃការជំនុំជម្រះក្តីសិន ហើយយើងអាចពិភាក្សាគ្នាអំពីការបំបែកបទចោទនេះគឺជាសំណើរបស់ខ្ញុំ។ តើអស់លោកគិតយ៉ាងម៉េចដែរ?

[១១:១៤:០៤]

**លោក នីកូឡាស គូមជែន៖**

យើងខ្ញុំឯកភាពទាំងស្រុង។ ការជំនុំជម្រះអាចធ្វើទៅបាននៅពេលដែលយើងដឹងវិសាលភាពនៃការជំនុំជម្រះ នៅពេលដែលយើងថា តើទីតាំងឧក្រិដ្ឋកម្មណាខ្លះដែលយកមកជំនុំជម្រះ នោះថាយើងនឹងអាចធ្វើការពិចារណាទៅតាមហ្នឹង។ ហើយខ្ញុំដឹងថា ដូចដែលខ្ញុំបញ្ជាក់អ៊ីចឹង ៩០ថ្ងៃនៃការជំនុំជម្រះហ្នឹងអាចត្រូវការចំពោះករណីដែលយើងខ្ញុំលើកឡើងនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណហើយ ប៉ុន្តែបញ្ហាដែលខ្ញុំលើកឡើងអម្បាញ់មិញ គឺ កាលណាយើងកំណត់អំពីវិសាលភាពនៃអង្គហេតុដែលយើងត្រូវយកមកធ្វើសវនាការក្នុងសំណុំរឿង០០២/០២ ទំនងជាជៀសមិនផុតពីការជជែកវែកញែកគ្នារវាងសញ្ញាណនៃ -- ដូចលោក ហ្សង់ម៉ាក ឡាវែន៍ បានលើកឡើងអ៊ីចឹង។ តើយើងសម្រេចអំពីជោគវាសនានៃបទចោទដែលនៅសេសសល់ហ្នឹង តើដោយវិធីណា? ដោយការទម្លាក់ចោល ឬក៏ដោយការបំបែកកិច្ចដំណើរការនីតិវិធីសវនាការលើផ្នែកដែលនៅសេសសល់នេះទៀត ដើម្បីឲ្យទំហំ អា០២/០២ នេះអង្គជំនុំជម្រះមានសមត្ថភាពនិងលទ្ធភាព អាចធ្វើសវនាការបានចប់ចុង

ចប់ដើម។ នេះជាបញ្ហា មិនមែនរឿងមិនបញ្ហាទេ វាជាប់គ្នា។ ហើយបើយើងអត់ញែកអានេះឱ្យដាច់ទេ យើងអត់ដឹងថាតើយើងកំណត់អង្គហេតុដោយវិធីណាទេ តាមវិធីទម្លាក់ចោល ឬក៏តាមវិធីបំបែកកិច្ចដំណើរការនីតិវិធី? បញ្ហានេះគឺជាបញ្ហាស្មុគស្មាញផ្នែកខាងអង្គច្បាប់តាំងពីមានសេចក្ដីសម្រេចបំបែកកិច្ចដំណើរការសវនាការលើកទី១ របស់អង្គជំនុំជម្រះសាលាដំបូងដែលប្ដឹងសាទុក្ខប្រឆាំងនឹងដីកាសម្រេចនេះដោយភាគី ជាពិសេសដោយសហព្រះរាជអាជ្ញាមក គឺមានការខ្វែងគំនិតគ្នា បញ្ហាបកស្រាយលើបញ្ហាអង្គច្បាប់នេះពាក់ព័ន្ធជាមួយនឹងភាពជាតំណាង ឬក៏គ្មានភាពជាតំណាងនេះ។ ការអនុវត្ត ខំមិនឡូ ឬក៏ស៊ីវិលឡូ នៅក្នុងច្បាប់នៅក្នុងអ.វ.ត.ក នេះ។ នេះជាបញ្ហា មិនមែនរឿងអត់បញ្ហាទេ។ អ៊ីចឹងហើយបានជាយើងខ្ញុំដាក់ព្រឹកមិញថា ការដកចេញនូវបទចោទខ្លះនេះគឺវាបង្ហាញនូវកត្តាមួយថ្មីទៀត ដែលបញ្ហានេះគឺវាមានការស្មុគស្មាញពីបញ្ហាអង្គច្បាប់ដែលយើងពិភាក្សាបន្តបន្ទាប់មិនដាច់ស្រេចទេ។ នេះគ្រាន់តែជាការចាប់ផ្ដើម ហើយអាចថាពេលនេះក៏យើងមិនអាចជជែកឱ្យបានជ្រះស្រឡះទេ ប៉ុន្តែក៏យើងមានគំនិតខ្លះ ពីព្រោះដល់ពេលអង្គជំនុំជម្រះសម្រេចទៅកុំឱ្យវាមានបញ្ហាតទៅទៀត ព្រោះបញ្ហាម្ដងហើយ។ បើសិនជាយើងមានបញ្ហាម្ដងហើយម្ដងទៀតនោះវាមិនទំនងជាសមទេ។ សាធារណជនគេទំនងជាមិនគាំទ្រយើងទេនៅពេលដែលរឿងសម្រេចម្ដងហើយមានបញ្ហាប្ដឹងសាទុក្ខម្ដងជាពីរម្ដង ហើយម្ដងទៀតប្ដឹងពីរបីដងទៀតវាមិនទំនងទេ គឺយើងត្រូវពិភាក្សាគ្នាឱ្យបានច្បាស់លាស់។

[១១:១៧:០០]

ដើម្បីច្បាស់លាស់បានវាទាល់តែសមស្របផ្នែកខាងការយល់ដឹងក្នុងការបកស្រាយអំពីបញ្ហាអង្គច្បាប់និងការអនុវត្តដែរ។ បើសិនជាយើងទស្សនៈខ្វែងគ្នាតាំងពីទស្សនៈក្នុងការបកស្រាយអង្គច្បាប់និងការអនុវត្តនៅអ.វ.ត.ក វានឹងខ្វែងគ្នារហូត និងមានការប្ដឹងប្រទាញប្រទង់គ្នារហូតជាដរាបតទៅ ទោះបីករណីរឿងស្ថានភាពដដែលក៏ដោយ។ ឧទាហរណ៍បំបែកកិច្ចដំណើរការនីតិវិធីលើកទី២ នេះក៏មានរឿងស្ថានភាពដដែលប្រហែលនឹងលើកទី១ដែរ។ វាអាចមានបញ្ហាដដែល។ អ៊ីចឹងហើយបានជាយើងផ្ដើមគំនិតក្នុងការជជែកឱ្យហើយដើម្បីថានៅពេលដែលយើងសម្រេចចុងក្រោយនេះយើងមិនអាចប្រើពេលវេលាច្រើនដងទៀតទេ ពីព្រោះភាគីទាំងអស់សុទ្ធតែចុះ សុទ្ធតែរវល់ ហើយពេលវេលាក៏យើងទាមទារម្នាក់ៗឱ្យខ្លីដែរ មិនមែនយើងធ្វើ ធី.អឹម.អឹម នេះពីរបីដង បួនដងទៀតទម្រាំបានកាត់ក្ដីនោះទេ សាធារណជនគេមិនគាំទ្រយើងទេបើសិនជាយើងធ្វើដូច្នោះ។ យ៉ាងច្រើនយើងធ្វើម្ដងទៀតទេ ដល់ពេលយើងត្រូវបើកសវនាការបឋម ឬក៏ចាប់ផ្ដើមសវនាការលើអង្គសេចក្ដីហើយ។

បាទ ជាបន្តនេះសូមផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។

[១១:១៨:១៥]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគីទាំងអស់ សាធារណជន។ បាទ ខ្ញុំបាទសូមលើកក្នុងនាមក្រុមរួមនៃដើមបណ្តឹងរដ្ឋប្បវេណី។ ជាគោលការណ៍ចំពោះបញ្ហាវិសាលភាពនៃករណី០០២/០២ ដែលជាករណីបន្ទាប់ពី០០១ ហើយដែលនឹងត្រូវកាត់ក្តីនាពេលខាងមុខនេះ ដើមបណ្តឹងរដ្ឋប្បវេណីឯកភាពចំពោះវិសាលភាពដែលស្នើឡើងដោយសហព្រះរាជអាជ្ញា។ ការឯកភាពនេះ ដោយយល់ឃើញថាយើងត្រូវការឲ្យមានសាលក្រមមួយក្នុងពេលមួយសមស្របដោយយើងត្រូវគិតពិចារណាអំពីប្រយោជន៍នៃយុត្តិធម៌ យើងត្រូវគិតពិចារណាអំពីបញ្ហាសុខភាព អាយុរបស់ជនជាប់ចោទហើយជាពិសេសទៅទៀតគេត្រូវគិតពិចារណាផងដែរថាជនរងគ្រោះដែលជាដើមបណ្តឹងរដ្ឋប្បវេណី ឬក៏មិនមែនជាដើមបណ្តឹងរដ្ឋប្បវេណីពួកគាត់កំពុងតែបាត់ឱកាសក្នុងការរស់រានមានជីវិត ហើយឃើញសាលក្រមត្រូវបានចេញពាក់ព័ន្ធទៅនឹងអង្គហេតុរបស់គាត់។ ដូច្នេះ វាមានសារៈសំខាន់ណាស់ដែលមានសាលក្រមត្រូវបានចេញហើយនិយាយថា អង្គហេតុដែលពាក់ព័ន្ធនឹងពួកគាត់តើមានអ្នកណាជាអ្នកទទួលខុសត្រូវ។ នេះជាមូលហេតុដែលយើងខ្ញុំគាំទ្រទៅនឹងអ្វីដែលបានលើកឡើងក្នុងផ្នែកនៃវិសាលភាពរបស់សហព្រះរាជអាជ្ញា។ ការគាំទ្រនេះយើងខ្ញុំក៏មានការយល់ឃើញថាអ្វីដែលព្រះរាជអាជ្ញាស្នើឡើងនេះ គឺមានបទចោទទាំងបី នៅក្នុងនោះដែលជាបទចោទមាននៅក្នុងច្បាប់។ មានន័យថា បទចោទអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម។ ក៏ប៉ុន្តែដោយនៅក្នុងនោះមានការជ្រើសរើសយកអង្គហេតុ ឬក៏ទីតាំងឧក្រិដ្ឋកម្មមួយចំនួនដែលមានលក្ខណៈជាតំណាងយកមកបញ្ចូល យកមកដាក់នៅក្នុងបទចោទនីមួយៗ ហើយដោយបទចោទដទៃទៀតត្រូវបានទុកមួយឡែក។ ហើយនេះជាអ្វីដែលយើងខ្ញុំយល់។ ហើយការបញ្ចូលបទចោទទាំងអស់នេះនៅក្នុងនេះ វាមិនផ្ទុយទៅនឹងវិធានផ្ទៃក្នុង ហើយក៏មិនចូលករណីចាំបាច់ឲ្យធ្វើវិសោធនកម្មទៅលើវិធានផ្ទៃក្នុងនោះទេ។

[១១:២០:៥៨]

ហើយចំពោះអ្វីដែលនៅសល់ពីបទចោទទាំងអស់នោះ យើងខ្ញុំយល់ថាដើមបណ្តឹងរដ្ឋប្បវេណី -- នេះជាអ្វីដែលយើងបានជួបផ្ទាល់ជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី -- គឺគាត់ចង់ឲ្យអង្គហេតុដែលពាក់ព័ន្ធនឹងពួកគាត់ត្រូវបានស្តាប់នៅចំពោះមុខតុលាការនេះ។ ដូច្នេះ ពាក់ព័ន្ធនឹងអ្វីដែលសហព្រះរាជ

អាជ្ញាបាននិយាយថា គឺទម្លាក់អង្គហេតុទាំងអស់នោះ យើងខ្ញុំមានការលំបាកនៅក្នុងការនិយាយ ថាតើយើងឯកភាពថាទម្លាក់ ឬក៏យ៉ាងណា ក៏ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណី គឺគាត់ចង់បានឱ្យមានការកាត់ទៅលើអង្គហេតុទាំងអស់នោះ ហើយដែលយើងខ្ញុំយល់ថាទុកជូនលោក លោកស្រីចៅក្រមជាអ្នកសម្រេចពាក់ព័ន្ធទៅនឹងអង្គហេតុដែលនៅសេសសល់បន្ទាប់ពីករណី០០២/០២។

ចំពោះបញ្ហាពេលវេលា ឬក៏ការស្តាប់ទៅលើសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី យើងខ្ញុំសូមបញ្ជាក់ថា យើងមាននឹងមានបញ្ជីមួយដាច់ដោយឡែកពីបញ្ជីរបស់សហព្រះរាជអាជ្ញា។ ក៏ប៉ុន្តែក៏អាចមានជាន់គ្នានូវឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី អ្នកជំនាញ ហើយនិងសាក្សីផងដែរ។ ហើយយើងនឹងផ្តល់ជូនទៅលោក លោកស្រីចៅក្រមនៅពេលណាដែលមានការបញ្ជាក់អំពីវិសាលភាពច្បាស់លាស់នៃករណី០០២/០២ យើងខ្ញុំនឹងបញ្ជូនបញ្ជីទាំងអស់នោះទៅលោក លោកស្រីចៅក្រម។ ក៏ប៉ុន្តែគ្រាន់តែចង់សូមបញ្ជាក់បន្ថែមទៀតថា យើងខ្ញុំចង់ឱ្យមានការស្តាប់ទៅលើដើមបណ្តឹងរដ្ឋប្បវេណីជាពិសេសផងដែរនៅក្នុងចំនួនមួយសមស្រប ជាពិសេសដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវនិយាយអំពីការឈឺចាប់ ឬក៏ព្យសនកម្ម។ ដែលដោយសារតែអង្គហេតុ ហើយនិងបទចោទមានលក្ខណៈទូលាយដូចដែលបានស្នើដោយខាងសហព្រះរាជអាជ្ញា គឺយើងចង់ស្នើសុំឱ្យមានការស្តាប់ទៅលើបញ្ហាព្យសនកម្ម ហើយនិងការឈឺចាប់នេះ យ៉ាងតិចក្នុងរយៈពេលប្រាំបីថ្ងៃចំពោះដើមបណ្តឹងរដ្ឋប្បវេណី។

[១១:២៣:២២]

ហើយបែបជាការពិតយើងខ្ញុំចង់ឱ្យមានការស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងរយៈពេលច្រើនជាងដូចដែលបានធ្វើមកនៅក្នុងករណី០០២/០១នេះ។ ក៏ប៉ុន្តែដោយយល់ទៅឃើញថា អង្គជំនុំជម្រះមានរយៈពេលដែលមានកម្រិត ហើយយើងមិនអាចបន្លាយពេលវែងបាន យើងនឹងគិតពិចារណាជ្រើសរើសយកវិធីដដែលនៅក្នុងការស្តាប់ដើមបណ្តឹងរដ្ឋប្បវេណី ដែលនិយាយអំពីព្យសនកម្ម ហើយនិងការឈឺចាប់របស់ពួកគាត់។

បាទនេះគឺជាគំនិតរបស់ខាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹងវិសាលភាព និងបញ្ជីរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ បាទសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះខាងអន្តរជាតិ? សូមអញ្ជើញលោកមេធាវី!

**លោកស្រី បេនី យេះ**

សូមអរគុណលោកប្រធាន។ ខ្ញុំសូមបន្ថែមយោបល់មួយលើការពិភាក្សា ថាតើជោគវាសនាទៅលើបទចោទនោះយ៉ាងម៉េច? ហើយថាតើអាចទម្លាក់បានឬក៏អត់។

វាមានសារៈសំខាន់ដែលយើងត្រូវពិចារណា មានន័យយ៉ាងម៉េចទៅលើនិយមន័យនៃបទចោទ។ បទចោទ ចំពោះយើងគឺជាការកំណត់តាមផ្លូវច្បាប់ទៅលើអង្គហេតុ ដែលបានចោទប្រកាន់។ ដូច្នេះប្រសិនបើនិយមន័យអ៊ីចឹងមែន បទចោទគឺមិនអាចទម្លាក់បានទេ។ សម្រាប់ការពិចារណារបស់អង្គជំនុំជម្រះ យើងខ្ញុំនឹងដាក់សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរនាពេលអនាគត ប្រសិនបើលើកឡើងបញ្ហានេះនោះ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណនូវមតិយោបល់នេះ។ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ពាក់ព័ន្ធនឹងបញ្ហានេះ។ សូមអញ្ជើញ!

[១១:២៥:២៧]

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថាភាគីទាំងអស់គ្នានៅក្នុងបន្ទប់សវនាការនេះឯកភាពថាវាជាបញ្ហាអង្គច្បាប់ស្មុគស្មាញក្នុងការពិចារណាសម្រេច ថាតើបទចោទត្រូវ ឬមិនត្រូវទម្លាក់ ឬគួរ មិនគួរទម្លាក់នោះ។ ខ្ញុំគិតថាមានបញ្ហាច្រើនទៀតដែលវាលេចចេញមកពីចំណុចហ្នឹង។ ដើម្បីឆ្លើយតបត្រឡប់មកវិញទៅលើការលើកឡើងរបស់សហព្រះរាជអាជ្ញា អ.វ.ត.ក របស់យើង វាមិនមែនជាសាលាក្ដីអន្តរជាតិនោះទេ។ អ.វ.ត.ក ជាតុលាការមួយអនុវត្តទៅតាមនីតិវិធីជាតិ។ ចំណុចនេះគឺថាទម្លាក់បាន ឬមិនទម្លាក់បានហ្នឹង យើងត្រូវពិភាក្សាគ្នាទៀតនៅក្នុងដំណាក់កាលក្រោយ។ ក៏ប៉ុន្តែវាជាការល្អក្នុងការដែលយើងពិចារណាការងារជាក់ស្ដែង គឺបញ្ហាចោទថាតើការជំនុំជម្រះវគ្គទី២នេះអាចជាការជំនុំជម្រះចុងក្រោយតាមព្រឹត្តិហេតុដែរឬទេ។ វាមិនចាំបាច់ពិភាក្សាទៅលើករណីថាកូនក្ដីរបស់ខ្ញុំនេះ គាត់មានវ័យចំណាស់ ហើយសុខភាពទ្រុឌទ្រោមនោះទេ។ ក៏ប៉ុន្តែធ្វើយ៉ាងណាឲ្យមានលទ្ធភាពសម្រាប់ជនជាប់ចោទមានវត្តមានដោយផ្ទាល់នៅក្នុងពេលការជំនុំជម្រះវគ្គទី៣ ប្រសិនបើមាន។ ខ្ញុំគិតថាក្រោយពិចារណាទៅការជំនុំជម្រះវគ្គទី២នេះ គឺជាការជំនុំជម្រះចុងក្រោយតាមព្រឹត្តិហេតុ។

[១១:២៧:១២]

យើងខ្ញុំសូមលើកឡើងដូចខាងក្រោមថា អ្វីដែលមិនច្បាស់សម្រាប់យើងខ្ញុំនោះ គឺបញ្ហាចោទស្តីអំពីបញ្ហានានាផ្សេងទៀតដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ។ ប្រសិនបើយើងកម្រិតខ្លួនឯងទៅលើទីតាំងឧក្រិដ្ឋកម្មមួយចំនួនតែប៉ុណ្ណោះ។ តាមទ្រឹស្តីវាអាចមានលទ្ធភាពដែលថាបញ្ហាពាក់ព័ន្ធដទៃទៀតៗ គឺមិនយកមកពិភាក្សាជជែកគ្នា។ ដូចដែលយើងបានដឹងបញ្ហាលំបាកមួយនៅក្នុងការជំនុំជម្រះវគ្គទី១ គឺបញ្ហាចោទថាតើសំណួរដែលសួរទៅកាន់សាក្សីនោះ វាជាសំណួរមួយស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះ ឬក៏ស្ថិតនៅក្រៅវិសាលភាពនៃការជំនុំជម្រះ។ នេះជាបញ្ហាដែលយើងជួបប្រទះក្នុងវគ្គមុន។

[១១:២៨:០០]

ក្រុមមេធាវីការពារក្តីរបស់យើង ឆ្លងតាមបទពិសោធន៍ យើងបានសិក្សាឃើញថាចំណុចក្នុងការលាតត្រដាងការពិត ឬក្នុងវគ្គមុននោះគឺថាវាមិនជួយឲ្យយើងច្រើន ហើយវាមិនបង្ហាញអំពីការទទួលខុសត្រូវកូនក្តីរបស់យើងខ្ញុំបានច្រើននោះទេ។ ដើម្បីលើកជាឧទាហរណ៍មួយ ឬពីរចេញមកពីដីកាដំណោះស្រាយ ចំណុចមួយជាឧទាហរណ៍ដែលយើងខ្ញុំចង់យកមកពិភាក្សានៅក្នុងសវនាការវគ្គទី២ គឺជាបញ្ហាដែលមិនពាក់ព័ន្ធជាចាំបាច់ទៅនឹងទីតាំងឧក្រិដ្ឋកម្ម។ ជាឧទាហរណ៍ លទ្ធផលដែលសរសេរនៅក្នុងរបាយការណ៍របស់កម្ពុជាប្រជាធិបតេយ្យ ហើយនិងបញ្ហាចោទថាតើជនរងគ្រោះសរុបទាំងប៉ុន្មាននាក់ដែលរងគ្រោះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ចំណុចនេះវាមិនមែនថាមានសារៈសំខាន់តែប៉ុណ្ណោះនោះទេ នៅពេលដែលយើងមើលទៅវាធ្វើឲ្យមានសារៈសំខាន់ជាទូទៅ។ ដូច្នេះនៅពេលដែលយើងគិតថាយើងចង់កម្រិតខ្លួនឯងត្រឹមតែការជំនុំជម្រះវគ្គក្រោយតែមួយគត់ ថាតើយើងអាចមានលទ្ធភាពពិភាក្សាគ្នាទៅលើបញ្ហានេះដែរ ប្រជាសាស្ត្រនេះដែរឬទេ ទោះបីវាមិនពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្ម។

[១១:២៩:២៩]

ដូចដែលខ្ញុំបាន -- ដូចដែលលោក លោកស្រីបានជ្រាបអ៊ីចឹង យើងឃើញថាមានការយល់ឃើញខុសគ្នាទៅលើហេតុការណ៍នៃការបង្កើតគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើង។ យើងជឿថាគោលនយោបាយនោះមិនមែនជាគោលនយោបាយជាតិនោះទេ។ ហើយវាគឺជាគោលនយោបាយបង្កើតឡើង និងជំទាស់ដោយក្រុមខ្ទាស់គ្នា ក្រុមជម្លោះនៅក្នុងពេលនោះដែលកើតឡើងនៅក្នុងឆ្នាំ៧៥នោះតែប៉ុណ្ណោះ។

ដូច្នេះ តាមទ្រឹស្តីរបស់ក្រុមការពារក្តី គឺថាយើងធ្វើយ៉ាងមានលទ្ធភាពក្នុងការបង្កើតទ្រឹស្តីការពារក្តីនៅក្នុងវគ្គទី២។ ដូច្នេះ បញ្ហាចោទវាលេចឡើង ប្រសិនបើយើងកម្រិតតែទៅលើទីតាំងឧក្រិដ្ឋកម្មដូចដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញានោះ បើសិនធ្វើអ៊ីចឹង តើវាអាចអនុញ្ញាតឲ្យយើងធ្វើការស៊ើបអង្កេតជ្រាវស្រាវចំពោះអ្វីដែលកើតឡើងក្នុងហេតុការណ៍ឆ្នាំ៧៥-៧៩ ដែរឬទេ? ជាឧទាហរណ៍មួយខ្ញុំសូមលើកឡើង ប្រសិនបើក្រុមមេធាវីការពារក្តី នួន ជា ចង់បង្ហាញទ្រឹស្តីមួយថា គឺមេដឹកនាំនៅរស់ ញឹម នៅខាងឧត្តរតែប៉ុណ្ណោះ និងមេដឹកនាំខាងបូព៌ា គឺអ្នកដែលធ្វើការប្រឆាំងនឹងមជ្ឈិមបក្ស។ ដូច្នេះ តើយើងត្រូវបង្ហាញដោយរបៀបណា?

[១១:៣១:០៦]

ប្រសិនបើយើងមើលដីកាដំណោះស្រាយដាក់ស្តែង វាអាចមានទីតាំងឧក្រិដ្ឋកម្មមួយចំនួន តាមទ្រឹស្តីដែលវាអនុញ្ញាតឲ្យមេធាវីការពារក្តីធ្វើការបង្កើតទ្រឹស្តីការពារខ្លួនមួយសម្រាប់ខ្លួនឯង។ ខ្ញុំសូមលើកជាឧទាហរណ៍មួយ ឧក្រិដ្ឋកម្មមួយមិនបានលើកឡើងនៅក្នុងសំណើសុំរបស់សហព្រះរាជអាជ្ញាដែលឧក្រិដ្ឋកម្មនេះ គឺការផ្លាស់ទីលំនៅដំណាក់កាលទីបីទៅលើប្រជាជនពីភូមិភាគបូព៌ា។ កថាខណ្ឌ គឺមានចែងនៅក្នុងកថាខណ្ឌ២៨៣ទៅដល់៣០១ ការផ្លាស់ទីលំនៅដំណាក់កាលទី៣នេះ គឺយើងធ្វើយ៉ាងណាឲ្យយើងមើលឃើញថា វាជាបោសសម្អាតទៅលើពួកភូមិភាគបូព៌ា។ ហើយដែលក្នុងនោះ ដែលគេលើកឡើងថាជាការក្បត់របស់ភូមិភាគបូព៌ា។ យើងថាវាមិនមែនអ៊ីចឹងនោះ ក៏ប៉ុន្តែវាអាចថាមានហេតុការណ៍អ៊ីចឹងកើតឡើង ហើយខាងក្រុមមេធាវីការពារក្តីចង់បង្កើតទ្រឹស្តីការពារមួយសម្រាប់ខ្លួន។ ដូចជាផែនការការងារនៅខាងពាយ័ព្យអ៊ីចឹង គឺនៅទំនប់ត្រពាំងថ្ម ក៏បានលើកឡើងនៅក្នុងកថាខណ្ឌ៣២៣ ទៅដល់៣៥០ នៅក្នុងដីកាដំណោះស្រាយ ដែលថាការដ្ឋានត្រពាំងថ្មនេះ នៅក្នុងភូមិភាគពាយ័ព្យ។

បញ្ហាដែលចំណុចដែលសំខាន់ៗទៀត មានជាច្រើននៅក្នុងហ្នឹង ដែលយើងត្រូវការបង្កើតទ្រឹស្តីការពារខ្លួនសម្រាប់យើងខ្ញុំ ហើយដែលចំណុចទាំងអស់នោះ គឺវាការពារទៅលើទ្រឹស្តីរបស់យើងខ្ញុំ។ យើងទុកបញ្ហាស្មុគស្មាញមួយឡែកសិន ពាក់ព័ន្ធទៅនឹងការទម្លាក់បទចោទ ឬក៏ការបំបែកបទចោទ។ យើងត្រូវគិតថា តើវាអាចជាការជំនុំជម្រះចុងក្រោយតាមព្រឹត្តិហេតុនេះយ៉ាងម៉េច? ហើយយើងដោះស្រាយទៅលើបញ្ហានេះដោយរបៀបណា។ ខ្ញុំគិតថា ការជជែកជារួមទៅលើបញ្ហាអង្គច្បាប់នេះ វាជាលក្ខណៈមួយទូទៅ ដែលថាយើងត្រូវពិចារណាសម្រេច តើគួរយកឧក្រិដ្ឋកម្ម ទីតាំងឧក្រិដ្ឋកម្មណាមួយជាក់លាក់យកមកធ្វើការវិនិច្ឆ័យ។

[១១:៣៣:២៤]

ចំណុចទាំងអស់នេះ គឺចំណុចបឋមដែលខ្ញុំសូមលើកឡើង ហើយចំពោះរយៈពេលនៃការជំនុំជម្រះរបស់យើងវិញ ខ្ញុំជឿថាការជំនុំជម្រះនេះគឺវាស្មុគស្មាញដូចទៅនឹងការជំនុំជម្រះមុន។ ទោះបីជាមិនស្មុគស្មាញជាមុនក៏ដោយ យើងក៏ត្រូវដោះស្រាយទៅលើបទចោទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ហើយខ្ញុំមានការលំបាកក្នុងការជឿខាងសហព្រះរាជអាជ្ញាដែលលើកឡើងថា វាជាការពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មួយដែលងាយបង្ហាញនោះ ចុះចំណែកទីតាំងឧក្រិដ្ឋកម្មផ្សេងទៀត តើយើងត្រូវបង្ហាញយ៉ាងម៉េច? ហើយពេលខ្លះទៅសាលាក្ដីឧក្រិដ្ឋកម្មដទៃទៀតមិនបានធ្វើការងារបាននោះទេដោយវាមានលក្ខណៈស្មុគស្មាញ ជាពិសេសទៅលើការចោទប្រកាន់ទៅលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ហើយចំពោះការចោទប្រកាន់ទៅលើ ស-២១ នោះ ក៏វាមានលក្ខណៈស្មុគស្មាញដូចគ្នា។

ខ្ញុំសូមរំឭកអង្គជំនុំជម្រះថា ក្រុមមេធាវីការពារក្ដី នួន ជា មានជំហរខុសពីខាងសហព្រះរាជអាជ្ញា នៅពេលដែលយើងលើកឡើងអំពីស-២១។ តួនាទីរបស់ ឌុច គឺវាមានលក្ខណៈពីគេ ហើយវាខុសពីតួនាទីរបស់កូនក្ដីរបស់ខ្ញុំ។ តួនាទីរបស់ ឌុច តាមការចោទប្រកាន់ គឺវាមានលក្ខណៈខុសពីតួនាទីរបស់កូនក្ដីរបស់ខ្ញុំ វាមានលក្ខណៈខុសពីតួនាទីរបស់ជនជាប់ចោទនៅក្នុងសំណុំរឿង០០១។ ដូច្នេះហើយយើងមិនមែនថាយើងមិនមានសុទិដ្ឋិនិយមចំពោះរយៈពេលនៃការអង្គជំនុំជម្រះជារួមនោះទេ។ ក៏ប៉ុន្តែវា -- យើងត្រូវគិតផងដែរ នៅពេលដែលវាពាក់ព័ន្ធទៅនឹងបញ្ហាអង្គច្បាប់ជាក់ស្ដែងដែលយើងត្រូវយកមកជជែកគ្នា។ យើងបានយល់ស្របជាមួយគ្នាដែលថាយើងត្រូវយកបញ្ហាគ្រប់ទាំងអស់មកពិភាក្សាគ្នាជាមុនឲ្យដាច់ស្រេច ក៏ប៉ុន្តែពេលខ្លះទៅយើងមិនអាចយក ហើយយើងមិនអាចយកបញ្ហាស្មុគស្មាញហ្នឹងយកមកពិភាក្សាគ្នាក្នុងពេលជំនុំជម្រះដែលយើងកំពុងតែធ្វើឡើងនោះទេ។

[១១:៣៥:៣០]

ខ្ញុំសូមរំឭកថា តុលាការកំពូលបានសម្រេចថា បទចោទកម្រិតអប្បបរមាត្រូវយកមកជំនុំជម្រះ ដូច្នេះហើយវាអាចឲ្យយើងចាប់ផ្ដើមការជំនុំជម្រះទៅតាមបទចោទដូចដែលបានចង្អុលបង្ហាញតាមកម្រិតអប្បបរមាពីតុលាការកំពូល។ ហើយនៅក្នុងពេលជំនុំជម្រះ យើងធ្វើការវាយតម្លៃបន្ថែមទៀតទៅថា តើចាំត្រូវដាក់បញ្ចូលបទចោទបន្ថែមទៀតដែរឬទេ។ ដូច្នេះក្រុមមេធាវីការពារ បើយល់ឃើញថា បើសិនបើធ្វើតាមបែបនេះ គឺថាវាអាចឲ្យក្ដោបរួមទាំងស-២១ផងដែរ។ យើងខ្ញុំយល់ឃើញថា ខាងក្រុមមេធាវីការពារក្ដីអាចបង្កើតទ្រឹស្ដីការពារខ្លួនរបស់ខ្លួន នៅពេលដែលគេលើកឡើងអំពីស-២១ ហើយ

ដោយពុំចាំបាច់បន្ថែមនូវការផ្លាស់ទីលំនៅដំណាក់កាលទី៣ក៏បានដែរ បើសិនបើយើងអាចមានលទ្ធភាពដូច្នេះ។

ចំពោះខ្ញុំៗគិតថាវាចាំបាច់ក្នុងផលប្រយោជន៍នៃយុត្តិធម៌ក្នុងការពិភាក្សាទៅលើចំណុចមួយចំនួននោះៗទេ។ ក្នុងពេលយើងជំនុំជម្រះ ក្នុងពេលដែលយើងដំណើរការទៅមុខនោះ គឺថាយើងអាចយកចំណុចមួយចំនួនយកមកពិភាក្សាគ្នាថា តើគួរតែបញ្ចូលទីតាំងឧក្រិដ្ឋកម្មមួយចំនួន ឬក៏មិនគួរ។ ដូចដែលអង្គជំនុំជម្រះសាលាដំបូងបានធ្វើឡើងនៅក្នុងវគ្គទី១រួចមកហើយ គឺ១៤ខែទៅមុននោះគឺថាអង្គជំនុំជម្រះបានសម្រេច ហើយបានបញ្ចូលទួលពោធិ៍ជ្រៃយកមកដាក់វិនិច្ឆ័យជាទីតាំងឧក្រិដ្ឋកម្មមួយ។

ទាំងអស់នេះគឺជាយោបល់បឋមរបស់ខ្ញុំដែលយើងខ្ញុំមានក្នុងពេលនេះ ហើយយើងខ្ញុំឯកភាពយល់ស្របថា វាមានបញ្ហាផ្លូវច្បាប់ស្មុគស្មាញត្រូវសម្រេច ក៏ប៉ុន្តែទោះបីស្មុគស្មាញអ៊ីចឹងក៏ដោយ វាមិនអាចរារាំងយើងថាមិនឲ្យមានការជំនុំជម្រះវគ្គទី២ ទៅមុខបាននោះទេ ដរាបណាដែលយើងចង់ធ្វើឲ្យវាបានលឿនតាមដែលអាចធ្វើទៅបាននោះ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកប្រធាន អ៎! លោកមេធាវី។ បាទ សូមប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន។ សូមអញ្ជើញ!

[១១:៣៨:០២]

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ មិនជាទម្លាប់ទេ គឺថាយើងមិនមានគោលជំហរដូចគ្នាទេលើកនេះជាមួយក្រុម នួន ជា នេះ។ ទាក់ទងទៅនឹងការចាប់ផ្ដើមៗមុននឹងដោះស្រាយបញ្ហាច្បាប់ជាមុននោះ។ ខ្ញុំគិតថា យើងត្រូវតែយកបទពិសោធន៍ពីសំណុំរឿង០០២/០១នេះ។ ខ្ញុំគិតថាវាជាការសមរម្យក្នុងការចំណាយពេលដើម្បីរៀបចំឲ្យបានសមស្របពីបញ្ហាខ្វែងគំនិតគ្នាមុននឹងចាប់ផ្ដើមសវនាការ ហើយដំណើរការលឿនមានប្រសិទ្ធភាព។

ចំណុចទី១ ខ្ញុំមិននិយាយវែងឆ្ងាយទេ មិននិយាយលើចំណុចច្បាប់សំខាន់ៗនោះទេ ក៏ប៉ុន្តែខ្ញុំសូមរំឭកគោលជំហររបស់ ខៀវ សំផន នោះគឺថាសំណុំរឿង០០២/០២ នេះត្រូវតែចាប់ផ្ដើមនៅពេលដែលមានសាលដីកាជាស្ថាពររបស់តុលាការកំពូលសិន ពីព្រោះថានៅពេលដែលយើងដោះស្រាយបញ្ហាមួយចំនួននៅក្នុងសំណុំរឿង០០២/០១នេះហើយដែលអាចប៉ះពាល់ទៅដល់វគ្គ២នេះ ទាល់តែធ្វើយ៉ាងដូច្នេះ

ហើយបានយើងអាចដំណើរការសវនាការទៅលឿន ហើយមានប្រសិទ្ធភាព ហើយយើងអាចដោះស្រាយអំពីបញ្ហារបៀបទទួលខុសត្រូវ ហើយវាអាចប៉ះពាល់ទៅដល់ចំនួនមនុស្សដែលយើងកោះហៅមកផងដែរ ហើយនិងរបៀបចោទសំណួរជាដើម។ នេះជាចំណុចទី១។

[១១:៣៩:៥០]

ហើយដើម្បីរំឭកគឺថាគោលជំហររបស់យើងនេះមិនមែនជាគោលជំហរច្រងេងច្រងាងទេ ដូចដែលខាងសហព្រះរាជអាជ្ញាធ្វើឲ្យយើងយល់ឃើញយ៉ាងដូច្នេះ គឺដូចជានិយាយថាមានពេលវេលាតិចសម្រាប់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ក៏ដូចខាងសហព្រះរាជអាជ្ញាដែរ។ ខ្ញុំសូមរំឭកថានៅក្នុងសារណារបស់ពួកគាត់ របស់សហព្រះរាជអាជ្ញាចុះថ្ងៃទី០៣ តុលា ឆ្នាំ២០១១, E124/4/2, ខ្ញុំសូមរំឭកថានៅក្នុងសេចក្ដីសម្រេចឯកសារ E284 អង្គជំនុំជម្រះសាលាដំបូងបានសរសេរនៅក្នុងកថាខណ្ឌ១៥៤ ថាមេធាវីនាំមុខហើយនិងសហព្រះរាជអាជ្ញាថាសំណុំរឿង០០២/២ នេះមិនអាចចាប់ផ្ដើមបានមុនពេលដែលមានបញ្ហាចម្រូងចម្រាសនោះត្រូវបានដោះស្រាយទេ។ ត្រូវតែដោះស្រាយបញ្ហាហើយបានចាប់ផ្ដើម។ ដូច្នេះនៅពេលនោះគេយល់ដូចគ្នាតែឥឡូវបែរជាប្រែក្រឡាស់គោលជំហរវិញ។ គឺហាក់ដូចជាថាប្រែប្រួលតាមបរិយាកាសដូចជាថាធ្វើយ៉ាងម៉េចបំពេញចិត្តអ្នកផ្ដល់ជំនួយជាដើម ក៏ប៉ុន្តែខ្ញុំសង្កត់ធ្ងន់លើផ្នែកច្បាប់។ ទាក់ទងនឹងផ្នែកច្បាប់នេះជាការពិតណាស់ តើអ្វី -- អង្គហេតុដែលមាននៅក្នុងដីកាដំណោះស្រាយនោះគឺអ្វីដែលសម្រេចដោយចៅក្រម ហើយសំខាន់ណាស់។ អ៊ីចឹងយើងត្រូវដឹងពីចំណុចនេះ អ៊ីចឹងត្រូវដឹងថាអង្គហេតុអីខ្លះដែលចេញ ហើយអ៊ីចឹងមុននឹងចាប់ផ្ដើមសវនាការ។ យើងអាចទទួលមតិយោបល់ពីភាគីបានត្រង់ចំណុចនេះ។

[១១:៤១:៥៥]

ខ្ញុំយល់ច្បាស់ណាស់ថាសហព្រះរាជអាជ្ញាដែលបានជ្រើសរើសអង្គហេតុមួយចំនួននោះ គឺថាជ្រើសរើសដើម្បីគាំទ្រទស្សនៈរបស់ខ្លួនទាំងអស់ គឺថាអង្គហេតុដែលជាតំណាង -- គាត់ចង់និយាយថាអ្វីៗទាំងអស់នោះគឺថាកើតមានឡើងដូចគ្នានៅទូទាំងប្រទេសនៃកម្ពុជា ប៉ុន្តែខាងការពារក្ដីមិនគិតអ៊ីចឹងទេ។ អ៊ីចឹងយើងនឹងដាក់សារណាដើម្បីពន្យល់ថាហេតុអ្វីបានសាក្សីណា ទីតាំងឧក្រិដ្ឋកម្មណាដែលត្រូវយកមកពិភាក្សាសួរដេញដោល ហើយការខកខានអំពីសំណាក់ចៅក្រមនេះដែលមិនបានពិចារណាលើចំណុចមួយចំនួននោះ យើងនឹងពន្យល់ពីមូលហេតុ យើងនឹងបញ្ចេញយោបល់យើងផងដែរលើចំណុចទាំងអស់នេះ។

ហើយការជ្រើសរើសអង្គហេតុជាតំណាងនេះ បើតាមសហព្រះរាជអាជ្ញាក៏ដោយ បើតាមខាងការពារក្ដីក៏ដោយ គឺថាមានទស្សនៈមួយនៅក្នុងការជំនុំជម្រះក្ដីមួយមានទស្សនៈផ្សេងៗគ្នា។ ចំណុចទី៣ ខាងការពារក្ដីនឹងធ្វើសារណា ហើយនិងនិយាយអំពីឯកសារដែលនៅសល់ទាំងប៉ុន្មានដែលគាំទ្រកថាខណ្ឌនៃដីកាដំណោះស្រាយដែលសល់ ហើយត្រូវជំនុំជម្រះ។ ហើយយើងត្រូវរកលទ្ធភាពដោះស្រាយបញ្ហានេះយើងត្រូវរៀបចំសវនាការនេះគឺយើងត្រូវតែមានពេលវេលាគ្រប់គ្រាន់ ហើយនិងមានធនធានមនុស្សគ្រប់គ្រាន់ដើម្បីបំពេញការងារហ្នឹង ដើម្បីឲ្យតុលាការនេះអាចដំណើរការសវនាការបានស្រួលនៅថ្ងៃមុខ។ នៅពេលដែលយើងអត់មានធនធានយ៉ាងនេះយើងមិនដឹងថាធ្វើយ៉ាងម៉េចការពារកូនក្ដីយើងឲ្យមានប្រសិទ្ធភាពនិងឲ្យបានពេញលេញនោះទេ។ នេះគឺជាការកត់សម្គាល់ដំបូងរបស់ខ្ញុំ។ បាទខ្ញុំសូមរំឭកថាគោលជំហររបស់យើងនៅដដែលទេ។ គឺថាយើងយល់ឃើញថា នៅពេលដែលមានសាលដីកាស្ថាពរ វាអាចឲ្យយើងចំណេញពេលវេលានូវសំណុំរឿង ០០២/២ នេះ។ ហើយទោះបីជាយ៉ាងណាក្ដីក៏យើងទាក់ទងនឹងពេលវេលានេះ ហើយនិងដើម្បីឲ្យភាគីទាំងអស់នោះមានពេលគ្រប់គ្រាន់ នៅពេលដែលអស់លោក លោកស្រីចៅក្រម ចេញសាលក្រមនេះទុកពេលវេលាអាចប្ដឹងឧទ្ធរណ៍បាន។ អ៊ីចឹងត្រូវតែរៀបចំកាលវិភាគសវនាការឲ្យគ្រប់គ្រាន់លោកប្រធាន។

ខ្ញុំមិននិយាយវែងឆ្ងាយអីទៀតទេ ក៏ប៉ុន្តែចំណុចច្បាប់អង្គច្បាប់ដែលលោកចៅក្រមឡាវែន៍ ហើយលោកប្រធាន ហើយនិងភាគីផ្សេងទៀតបានលើកឡើងនេះ វាតម្រូវឲ្យយើងពិចារណាលើចំណុចច្បាប់នេះឲ្យបានច្បាស់លាស់មុននឹងយើងចាប់ផ្ដើមដំណើរការសវនាការវគ្គ២/២ នេះលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីមេធាវី!

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍!

[១១:៤៥:២៥]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

សូមអរគុណលោកប្រធាន។ ជាបឋមមេធាវី អង់តា ហ្គីសសេ ការសន្និដ្ឋានរបស់លោកស្រីគឺត្រូវរង់ចាំទាល់តែមានសាលក្រមស្ថាពរ ដែលសម្រេចដោយអង្គជំនុំជម្រះតុលាការកំពូល។ ហើយទើបបានចាប់ផ្ដើមសវនាការលើរឿងក្ដី០០២/០២បាន។ ប៉ុន្តែយើងអាចធ្វើតេស្ដពីភាពជាក់ស្ដែង ខ្ញុំមិនចាំអំពីការកំណត់ពេលវេលាលាក់ជាក់ទេ ប៉ុន្តែតាមដែលខ្ញុំចាំ បន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងនេះបានចេញ

សេចក្ដីសម្រេចរឿងសាលក្រម រឿងក្ដី១ ឌុច គឺថាអាចនឹងប្រើពេលប្រហែលជាមួយឆ្នាំជាងឯណោះ ដើម្បីឲ្យអង្គជំនុំជម្រះតុលាការកំពូលនោះអាចនឹងសម្រេចចុងក្រោយបាន ហើយខ្ញុំអាចនឹងមិនច្បាស់លាស់ចំណុចនេះ។ ប៉ុន្តែតើលោកស្រីគិតថាពេលដែលតុលាការកំពូលត្រូវការទេ ក្នុងការលើកឡើងពីការពន្លឿននីតិវិធីនោះដែរឬទេ។ ហើយខ្ញុំក៏មានសំណួរខ្លីមួយដែរជូនទៅលោក វ៉ិចទ័រ កូប៉េ នោះ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកស្រីចៅក្រម ខ្ញុំដឹងអំពីរយៈពេលដើម្បីចេញសេចក្ដីសម្រេចនេះហើយ ក៏ប៉ុន្តែដោយសារសាលដីកាចុងក្រោយ ដែលតុលាការកំពូលចេញហ្នឹងក៏អាចចេញនៅពេលដែលយើងចាប់ផ្ដើមដំណើរសវនាការហើយ។ ឧទាហរណ៍០០២ នេះ ស្គាស០២ចាប់ផ្ដើមចេញទៅហើយ។ ដូច -- យើងកំពុងតែនិយាយអំពីរបៀបទម្រង់ទំនួលខុសត្រូវ ហើយនិងយើងសួរសាក្សីជាច្រើន។ បើសិនជាពេលនោះតុលាការកំពូលចេញសាលដីកាមួយ ដើម្បីចេញមកបដិសេធគោលជំហររបស់ចៅក្រមយើងសព្វថ្ងៃនេះ ហើយដែលត្រូវអនុវត្តនោះ អ៊ីចឹងការយើងចាប់ -- ការដែលយើងធ្វើសវនាការមុនពេលចេញសេចក្ដីសម្រេចនោះ វាជាការរំលោភលើសេចក្ដីសម្រេចនោះហើយ។ ដោយក្នុងន័យនេះហើយដែលខ្ញុំថា ពេលដែលយើងចាប់ផ្ដើមលឿននោះ គឺថាមិនមែនទៅលឿននោះទេ។ យើងចាំឲ្យបានចេញសាលដីកាសិនហើយ យើងមានមូលដ្ឋានសមរឹងមាំមួយបានយើងចេញដំណើរការសវនាការ ខ្ញុំគិតថាអាចទៅលឿនជាង។ នេះគឺជាបញ្ហាការយល់ទស្សនៈទេ ហើយកាលណាយើងដឹងច្បាស់លាស់អំពីអង្គច្បាប់ហើយ យើងអាចចេញដំណើរបានលឿន។ នេះហើយដែលការយល់ឃើញដូច្នេះហើយដែលខ្ញុំទាញការសន្និដ្ឋានថា នៅពេលដែលចេញសាលដីកាហើយ យើងអាចទៅមុខលឿនជាងនោះ។

[១១:៤៨:៣២]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណ។ ឥឡូវនេះយើងនិយាយពីបញ្ហាថាតើអង្គជំនុំជម្រះតុលាការកំពូលអាចមានលទ្ធភាពនឹងបញ្ចប់បណ្ដឹងសាទុក្ខរឿងក្ដី០០២/០១នោះ នៅក្នុងពេលកំណត់មួយដែលអនុញ្ញាតឲ្យមេធាវីការពារក្ដីអាចនៅក្រុមដដែល ហើយដោះស្រាយនូវបញ្ហាអនុវត្តផ្សេងៗ ដើម្បីដោះស្រាយអនុវត្តការងារនោះដែរឬទេ។ ប៉ុន្តែ ឥឡូវនេះខ្ញុំសួរទៅលោក វ៉ិចទ័រ កូប៉េ ទាក់ទងទៅនឹងនីតិវិធីដែលត្រូវអនុវត្តក្នុងរឿងក្ដី០០២/០១នោះ។ អង្គជំនុំជម្រះបានទុកចំហអំពីវិសាលភាព ហើយយើងបន្ថែម ហើយយើងដកចេញខ្លះនៅពេលដែលយើងដំណើរការទៅ។ តើយើងចាត់ទុកថាជាទម្លាក់អនុវត្តដែលអង្គជំនុំជម្រះ

តុលាការកំពូលបានរិះគន់យើងទេ ឬក៏ចំណុចអ្វីដែលលោកអះអាងខាងដើមនោះ?

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំយល់ពីសំណួរនេះ ប៉ុន្តែយើងចង់ដឹងវិសាលភាពមុននឹងយើងអនុវត្តទៅមុខបាន។ ពីព្រោះជាចាំបាច់នេះយើងមិនបញ្ជាក់ថា នេះជាអ្វីដែលត្រូវធ្វើមុនយើងចាប់ផ្តើមនោះទេ។ ឥឡូវនេះខ្ញុំយោងទៅរកពីចំណុចដែលខ្ញុំចាប់ផ្តើមនោះ។ ចំណុចដែលសំខាន់នៃការរិះគន់នោះ គឺថាយើងមិនមានលទ្ធភាពនឹងលើកឡើងនូវបញ្ហាដែលយើងគិតថាវាមានភាពពាក់ព័ន្ធទៅនឹងទស្សនៈរបស់យើង។ ជាពិសេសការបកស្រាយទាក់ទងទៅនឹងការបំបែកដំណើរការនីតិវិធីដាក់ឲ្យទៅជាអនុវត្តជាដើមនោះ។

នេះវាអាចមានភាពខុសគ្នា នៅក្នុងសវនាការបន្ទាប់ ពីព្រោះថាបើមិនបានពិនិត្យពីវិសាលភាពនៃរឿងក្តីទេ យើងនឹងមានបញ្ហាច្រើននៅតាមផ្លូវដែលយើងបានធ្វើដូចនៅក្នុងការជំនុំជម្រះវគ្គទី១ ដូច្នេះ។ នេះហើយដែលយើងគិតថាមានបញ្ហាទាក់ទងគ្នា។ អ្វីដែលយើងមានការខកចិត្តនោះគឺថាយើងចង់ទៅតាមផ្លូវមួយ ប៉ុន្តែយើងមិនបានធ្វើបានទេ ដោយហេតុថាមានការបញ្ជាក់ថាអាចនឹងបញ្ជាក់ថាក្រៅពីវិសាលភាពនៃសំណុំរឿងដែលត្រូវជំនុំជម្រះ។ ដូច្នេះហើយបានយើងខ្ញុំចង់បានថាឲ្យកំណត់វិសាល-ភាពជាមុនឲ្យច្បាស់ បន្ទាប់មកយើងអាចនឹងមិនមានបញ្ហាច្រើនទេនៅពេលដែលយើងធ្វើសវនាការបន្ទាប់នេះ គឺវាអាចនឹងប្រសើរជាងក្នុងវគ្គទី១ដែលយើងជួបប្រទះនូវបញ្ហាទាំងនោះ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ បាទសូមអញ្ជើញលោកសហព្រះរាជអាជ្ញារងអន្តរជាតិ!

[១១:៥១:៤០]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

ខ្ញុំសូមអនុញ្ញាតឆ្លើយតបដោយសង្ខេបទៅនឹងបញ្ហាមួយចំនួន ជាពិសេសដែលលើកឡើងដោយមេធាវីការពារក្តី។ ខ្ញុំសូមឆ្លើយតបទៅការអានរបស់មេធាវីការពារក្តីលោក ខៀវ សំផន ដែលថាសហព្រះរាជអាជ្ញាបានប្តូរជំហររបស់ខ្លួនថាការជំនុំជម្រះទី២ អាចចាប់ផ្តើមឡើងបានរហូតទាល់តែមានសាលដីកាបណ្តឹងសាទុក្ខរឿងក្តី០០២/០១ ឯណោះ។

ចំណុចទី១ បញ្ហាដែលបានលើកឡើងទៅជូនចៅក្រម ខាតវ៉ាយថ៍ គឺថាសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្តី០០១ គឺចេញនៅថ្ងៃ -- ខែកក្កដា ឆ្នាំ២០១០ ហើយសេចក្តីសម្រេចលើ

បណ្តឹងសាទុក្ខមិនបានចេញទេ រហូតទាល់តែថ្ងៃទី០៣ ខែមករា ឆ្នាំ២០១២។ ដូច្នេះប្រហែលជាប្រើពេលវែងជិតមួយឆ្នាំឯណោះ។

ជំហររបស់សហព្រះរាជអាជ្ញាមិនកែប្រែទេ អ្វីដែលយើងមាននេះគឺថាយើងមានការបង្គាប់ពីតុលាការកំពូលថា សវនាការលើកភស្តុតាងលើរឿងក្តី០០២/០២ ត្រូវតែចាប់ផ្តើមឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ដូច្នេះយើងមិនមានហេតុផលអីនឹងដើម្បីតទល់គ្នាទេ យើងមិនត្រូវរង់ចាំថាមានសាលដីកាលើបណ្តឹងសាទុក្ខ ឬក៏សាលក្រមរបស់សាលាដំបូងទេ។ នៅពេលដែលតុលាការកំពូលបង្គាប់ថាឲ្យបានឆាប់តាមដែលអាចធ្វើទៅតាមនៅក្នុងកថាខណ្ឌ៧២ហ្នឹង គឺថាត្រូវចាប់ផ្តើមភ្លាមៗបន្ទាប់ពីការប្រជុំរៀបចំសវនាការ។ ដូច្នេះ ខ្ញុំស្តាប់ឮមេធាវីនៅក្នុងពេលនេះ គឺថាហាក់ដូចជាខ្លួនបំភ្លេចអំពីដីកាបង្គាប់របស់តុលាការកំពូលត្រូវរង់ចាំមានសាលដីកាបណ្តឹងសាទុក្ខទៅវិញ។ នេះគឺជាការបង្គាប់មិនមានទុកលទ្ធភាពឲ្យលោកបត់បែនបានទេ។

[១១:៥៣:៤០]

ចំពោះបញ្ហាផ្សេងទៀត ជាពិសេសលោក កូប៉េ បានលើកពីបញ្ហាមួយ។ ហើយខ្ញុំសូមឆ្លើយតបទៅលោកថា បើលោកមានឱកាសដើម្បីពិនិត្យជាលម្អិតនៅកថាខណ្ឌនៃដីកាដំណោះស្រាយដែលយើងខ្ញុំបានស្នើថាដាក់បញ្ចូលនោះ ការព្រួយបារម្ភរបស់គាត់ដែលគាត់ឡើងហ្នឹង គឺថាគាត់មិនមានទៀតទេ។ នៅពេលដែលយើងមើលសំណើយើងខ្ញុំនោះ តុលាការត្រូវដាក់បញ្ចូលនូវការចោទប្រកាន់ទូលំទូលាយអំពីគោលនយោបាយ អំពីសហឧក្រិដ្ឋកម្មរួម ដែលដាក់បញ្ចូលនៅក្នុងផ្នែកផ្សេងៗនៅក្នុងមូលដ្ឋានបទឧក្រិដ្ឋ។ ហើយយើងដាក់បញ្ចូលនៅក្នុងសំណើគម្រោងរបស់យើងខ្ញុំ កថាខណ្ឌបន្ថែមមួយចំនួនដែលយើងត្រូវគិតថាអាចនឹងដាក់បញ្ចូលនោះ។ ចំណុចទាំងអស់នោះគឺថាមានការចោទប្រកាន់ដ៏ទូលំទូលាយដូចជាការបោសសម្អាតនៅភូមិភាគបូព៌ា។

ហើយប្រសិនបើលោកពិនិត្យមើលកថាខណ្ឌមួយចំនួនដែលនឹងដាក់បញ្ចូលនៅក្នុងការជំនុំជម្រះបន្ទាប់នេះ គឺអនុញ្ញាតឲ្យមេធាវីអាចលើកឡើងបញ្ហាទាំងអស់នោះ គឺនិងបញ្ហាផ្សេងទៀតដែលបានលើកឡើង។ ហើយចំណុចទី២ មេធាវីការពារក្តីគប្បីតែពិនិត្យ មានពេលពិនិត្យសំណើរបស់យើងខ្ញុំ។ ហើយខ្ញុំយល់ស្របថាមេធាវីការពារក្តីគប្បីនឹងត្រូវបានអនុញ្ញាតឲ្យប្រើទ្រឹស្តីរបស់ខ្លួនក្នុងការការពារ។ ហើយមិនត្រូវចាត់ទុកថា យើងធ្វើការងាររបស់យើងដើម្បីបង្រួមចង្អៀតនូវការចោទប្រកាន់នោះទេ ក៏ប៉ុន្តែយើងនឹងផ្តោតទៅលើបញ្ហាទូលំទូលាយ ដូចជាគោលនយោបាយរបស់របបនោះ ទាក់ទងទៅនឹងផ្នែក

និយាយអំពីសហឧក្រិដ្ឋកម្មរួម ក៏ត្រូវតែដាក់បញ្ចូលជំនុំជម្រះបន្ទាប់នេះដែរ។

ចំណុចចុងក្រោយ ខ្ញុំចង់ជម្រាបជូន ហើយនិងយោងទៅរកការពិភាក្សាដែលយើងបានជជែកព្រឹកនេះ។ ខ្ញុំបានកត់ត្រាថា អាចនឹងថាខែឧសភា ឆ្នាំនេះនៃការជំនុំជម្រះ។ ខ្ញុំមិននិយាយអំពីដើមបណ្ដឹងរដ្ឋប្បវេណីដែលធ្វើសេចក្ដីថ្លែងអំពីផលប៉ះពាល់ទៅជនរងគ្រោះ។ ខ្ញុំកត់ត្រាផ្ទាល់នោះ គឺថាមានសាក្សីប្រាំពីររូបដែលបានបញ្ចប់នៅក្នុង ប្រហែលជាមួយត្រឹមាសទេ ហើយសាក្សីប្រាំរូបទៀត អាចបញ្ចប់បានកន្លះថ្ងៃបាទ។ រីឯខាងដើមនោះ គឺថាម្នាក់ៗតិចជាងកន្លះថ្ងៃ។ អ៊ីចឹងយើងពិនិត្យឃើញថា សាក្សីដែលនិយាយអំពីមូលដ្ឋានបទល្មើសនោះ គឺថាបញ្ជាក់ខ្លីៗទេ។ សក្ខីកម្ម គឺថាភាគច្រើននៃពួកគាត់នោះ គឺប្រើពេលតិចជាងមួយថ្ងៃ។

[១១:៥៦:៣២]

ហើយលោកមានការព្រួយបារម្ភពីបញ្ហាហ្នឹង ហើយខ្ញុំសូមបញ្ជាក់ថា យើងមិនបញ្ជាក់អ្វីដាក់ជូនអ្វីដែលថាតាមចិត្តចេតនា ឬក៏ការប៉ុនប៉ងរបស់យើងទេ គឺថាយើងផ្អែកទៅលើបទពិសោធន៍ដែលយើងបានធ្វើ។ ដូច្នេះ គឺថាសាក្សីដែលបញ្ជាក់ពីមូលដ្ឋានបទល្មើសនោះ គឺប្រើពេលខ្លីៗទេ។ លើកលែងតែភាគី ឬក៏ចៅក្រម មានសំណួរអ្វីទៀត ខ្ញុំសូមផ្អាកត្រឹមនេះសិន បាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ភាគី និងសាធារណជនសាជាថ្មី។

ខ្ញុំមានបំណងក្នុងការឆ្លើយតបទៅលើចំណុចដូចគ្នា ដូចដែលជាចំណុចទី១របស់ អូ.ស៊ី.ភី – ការិយាល័យសហព្រះរាជអាជ្ញាបានលើក។ ឆ្លើយតបទៅនឹងការដែលលោកស្រី អង់តា ហ្គីសសេ មេធាវីរបស់លោក ខៀវ សំផន លើកថាយើងបានប្ដូរគោលជំហររបស់យើង។ ជាការពិត ការិយាល័យសហព្រះរាជអាជ្ញាបានលើកជាការត្រឹមត្រូវ គឺយើង -- គោលជំហររបស់យើងគឺយើងចង់បានសវនាការករណី០០២ហ្នឹង ដំណើរការឱ្យបានឆាប់រហ័ស ហើយយើងក៏គោរពទៅតាមអ្វីដែលជាគំនិតរបស់អង្គជំនុំជម្រះតុលាការកំពូលដែរ។

អ្វីដែលបានយើង -- ដែលបានគិតពីដំបូង យើងចង់បានឱ្យមានសាលក្រមករណី០០១ -- អ៎! ០០២/០១ ត្រូវបានចេញនៅក្នុងករណី ឱ្យបានលឿន ដោយយើងមានការព្រួយបារម្ភអំពីសុខភាពរបស់

ជនជាប់ចោទ។ ហើយពេលនេះ ដោយសារថាយើងមានសេចក្ដីសម្រេចរបស់តុលាការកំពូល យើងគិតថាក៏មានសារៈសំខាន់ផងដែរ នៅពេលដែលយើងអាចមានលទ្ធភាពចាប់ផ្ដើមករណី០០២/០២ បន្តទៀត យើងគួរតែជំរុញករណីនេះឱ្យបានទៅលឿន ដោយយើងក៏គិតពិចារណាថា មានបញ្ហាមួយចំនួនដែលគួរឱ្យព្រួយបារម្ភ ហើយដែលយើងគួរតែជំរុញឱ្យលឿន។ ដូចគ្នាដែរគឺករណីសុខភាព ទាំងជនជាប់ចោទ ទាំងសុខភាពរបស់ខាងដើមបណ្ដឹងរដ្ឋប្បវេណី និងជនរងគ្រោះនានា ដែលនេះជាបញ្ហាដែលធ្វើឱ្យយើងគិតថាវាចាំបាច់ណាស់ ដែលដំណើរការសវនាការទៅលើភស្តុតាងនៃករណី០០២នេះ គួរតែចាប់ផ្ដើមឱ្យឆាប់រហ័ស។

[១១:៥៩:១៨]

ពាក់ព័ន្ធទៅនឹងអ្វីដែលបានលើកឡើងរបស់លោកស្រី អង់តា ហ្គីសសេ ក៏ដូចជាក្រុមការពារក្ដីរបស់ជនជាប់ចោទ ខៀវ សំផន បើយើងគិតអំពីរយៈពេលដែលករណី០០២/០២ ដែលអាចចាប់ផ្ដើមយោបល់របស់គាត់ មានន័យថាគឺយើងត្រូវចាំរហូតទាល់តែមានសាលក្រមករណី០០២/០១ ដែលអាចប្រើពេលរហូតទៅដល់ខែមិថុនា ឆ្នាំ២០១៤ ហើយភាគច្រើននឹងអាចមានការប្ដឹងសាទុក្ខតុលាការកំពូលទៀត ហើយរង់ចាំរហូតទៅដល់មានសេចក្ដីសម្រេចរបស់តុលាការកំពូល ពាក់ព័ន្ធទៅនឹងការប្ដឹងសាទុក្ខនេះទៀត។ អ៊ីចឹងអាចចំណាយពេលរហូតទៅដល់មួយឆ្នាំបន្តទៀត។ អ៊ីចឹង វាអាចប្រើពេលលើសពីមួយឆ្នាំកន្លះ។ ដូច្នេះ ក្នុងរយៈពេលនេះ យើងនឹងចំណាយពេលកំពុងរង់ចាំ ដែលយើង ដែលពេលវេលាកាន់តែកន្លងផុតទៅ ហើយពេលវេលា ឱកាសដែលយើងអាចមានលទ្ធភាពនៅក្នុងចាប់ផ្ដើមសវនាការនេះឱ្យបានឆាប់រហ័ស យើងបោះបង់ចោលឱកាសនេះ ហើយក៏មានន័យផងដែរថាយើងមិនបានគិតអំពីការទន្ទឹងរង់ចាំក្នុងការទទួលនូវសាលក្រមទៅលើអង្គហេតុដែលពាក់ព័ន្ធទៅនឹងជនរងគ្រោះ ក៏ដូចជាដើមបណ្ដឹងរដ្ឋប្បវេណីទេ។

ដូច្នេះ ជាថ្មីម្ដងទៀត យើងខ្ញុំយល់ថា វាមានសារៈសំខាន់ណាស់ដែលយើង -- សវនាការទៅលើភស្តុតាងករណី០០២/០២ នេះ អាចចាប់ផ្ដើមបានឆាប់រហ័ស។ សូមអរគុណ។

[១២:០០:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ បាទ ឥឡូវនេះ ដល់ពេលសម្រាកថ្ងៃត្រង់ហើយ យើងផ្អាកកិច្ចប្រជុំរបស់យើងនៅព្រឹកនេះត្រឹមនេះ ហើយកិច្ចយើងបន្តធ្វើនៅរសៀលនេះ ចាប់ផ្ដើមពីម៉ោងមួយ និង

សាមសិននាទី។ សូមអញ្ជើញឯកឧត្តម អស់លោក លោកស្រី នាងកញ្ញា អញ្ជើញចូលរួមប្រជុំនៅក្នុងរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០១ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣២:៤៣]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

ខ្ញុំប្រកាសបើកបន្តកិច្ចប្រជុំពិភាក្សារបស់យើង។ ហើយកិច្ចប្រជុំពិភាក្សាដែលបានធ្វើមួយថ្ងៃកន្លះកន្លងមកនេះយើងបានធ្វើរបៀបវារៈចំនួនបីរួចហើយ ហើយនៅរសៀលនេះយើងនៅតែពីររបៀបវារៈទៀតប៉ុណ្ណោះ។ ឥឡូវនេះខ្ញុំដាក់ជូននូវរបៀបវារៈទីបួន ការកំណត់កាលបរិច្ឆេទបណ្ដោះអាសន្នសម្រាប់សវនាការលើសំណុំរឿង០០២/០២។ របៀបវារៈទី៤នេះគឺទាក់ទងនឹងការវិភាគបណ្ដោះអាសន្នសម្រាប់ដំណើរការសំណុំរឿង០០២/០២។

អង្គជំនុំជម្រះយល់ឃើញថាកាលបរិច្ឆេទសម្រាប់សំណុំរឿង ០០២/០២ អាស្រ័យទៅលើកត្តាមួយចំនួនរួមមានបញ្ហាថាតើក្រុមប្រឹក្សាជំនុំជម្រះទី២ នឹងត្រូវតែងតាំងឬក៏អត់ ព្រមទាំងការសម្រេចទៅលើវិសាលភាពនៃសំណុំរឿង០០២។ អាស្រ័យហេតុនេះការពិភាក្សានៅក្នុងរបៀបវារៈទី៤នេះ នឹងត្រូវកម្រិតត្រឹមតែការបញ្ជាក់ពីសំណាក់ភាគីនានាអំពីលទ្ធភាពអាចចូលរួមរបស់ខ្លួននាពេលអនាគតតាមការប្រមើលមើលតែប៉ុណ្ណោះ។ តើភាគីអាចបញ្ជាក់បានដែរឬទេថា តាមដែលលោក លោកស្រីមានលទ្ធភាពនៅពេលនេះ ថាតើមានអ្វីដែលប្រហែលជាអាចនឹងរារាំងមិនអាចឲ្យលោក លោកស្រីចូលរួមនៅក្នុងកិច្ចប្រជុំរៀបចំសវនាការ ឬសវនាការដេញដោលភស្តុតាង រួមទាំងសវនាការបឋមក្នុងរយៈពេល១២ខែទៅមុខទៀតនេះដែរឬទេ?

ជាដំបូងនេះខ្ញុំសូមប្រគល់វេទិកាជូនទៅខាងសហព្រះរាជអាជ្ញាដើម្បីឆ្លើយតបទៅនឹងសំណួរនេះ។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ យើងដឹងថាយើងនៅទីនេះដើម្បីជំនុំជម្រះទៅលើសំណុំរឿង ក៏ដូចជាបទចោទនានា ហើយវាជាសំណុំរឿងដ៏សំខាន់ គឺសំណុំរឿង០០២។ ដូច្នេះ ខ្ញុំគិតថាវាជាការទទួលខុសត្រូវ និងជាកាតព្វកិច្ចរបស់យើង។ ដូច្នេះហើយគឺថាយើងមានវត្តមានគ្រប់ពេលនៅពេលដែលអង្គជំនុំជម្រះកោះហៅ គឺអត់មានបញ្ហាអ្វីទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះខាងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី?

[១៣:៣៥:៤៩]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពេលនេះយើងមានមេធាវីនាំមុខជាតិដែលនៅប្រចាំនៅទីកន្លែង ដែលសវនាការ អង្គតុលាការនេះ។ ក៏ប៉ុន្តែមេធាវីនាំមុខអន្តរជាតិ អេលីហ្សាបេត ស៊ីម៉ុនណូហ្វត គាត់នៅមិននៅក្នុងប្រទេសទៀតទេ។ ហើយយើងមិនដឹងថាតើនឹងមានមេធាវីនាំមុខបរទេសមួយមកជំនួសនៅពេលក្រោយទៀត យើងមិនអាចដឹងបានទេ អាស្រ័យទៅលើចំណាត់ការរបស់ខាងរដ្ឋបាល។ ក៏ប៉ុន្តែជាទូទៅតាមវិធានផ្ទៃក្នុង ហើយនិងវត្តមានរបស់មេធាវីផ្សេងៗទៀតខាងដើមបណ្តឹងរដ្ឋប្បវេណី យើងខ្ញុំយល់ថាវាមិនចោទជាបញ្ហាសម្រាប់ការចូលរួមនៅក្នុងសវនាការនេះទេ។

ហើយខ្ញុំសូមបញ្ជាក់បន្តិចពាក់ព័ន្ធទៅនឹងអ្វីដែលខ្ញុំនិយាយព្រឹកមិញបន្តិច គឺខ្ញុំបាននិយាយថា បទចោទមិនអាចទម្លាក់បានទេ ក៏ប៉ុន្តែអង្គហេតុគឺគេអាចទម្លាក់បាន។ បាទសូមបញ្ជាក់បន្តិច សូមអរគុណព្រោះអាចមានការបកប្រែភ័ន្តច្រឡំព្រឹកមិញនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ សូមអញ្ជើញលោកស្រីមេធាវី!

**លោកស្រី បេនី យេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់បន្ថែមបន្តិចក្នុងនាមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ គឺថាគាត់អាចបំពេញការងារពីបរទេសបាននៅក្នុងអំឡុងពេលរៀបចំសវនាការ និងនៅពេលខាងមុខទៀត។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះខាងក្រុមមេធាវីការពារក្តី លោក វ៉ិចទ័រ កូប៉េ?

[១៣:៣៨:១១]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ យើងមានវត្តមានគ្រប់ពេលនៅឆ្នាំក្រោយ គឺក្នុងរយៈពេល១២ខែនេះគឺយើងអាចមានវត្តមានគ្រប់ពេល។ ប៉ុន្តែខ្ញុំមានមតិមួយបន្ថែមបន្តិច គឺថាយើងបានបញ្ជូនលិខិតកាលពីថ្ងៃចន្ទ ដែលបញ្ជាក់នៅក្នុងលិខិតនោះថា ជំនួសឱ្យមេធាវីជាតិគឺយើងមានអ្នកផ្តល់ប្រឹក្សាដើម្បីជំនួសឱ្យមេធាវីជាតិ គឺលោក សួន វិសាល គាត់អាចមានវត្តមាន។ ប៉ុន្តែខ្ញុំមិនដឹងថាតើយើងអាចពិភាក្សានៅក្នុងបញ្ហានេះបានឬក៏អត់នោះទេ ព្រោះថាដោយសារតែមានបញ្ហាសុខភាពរបស់សហការីជាតិរបស់ខ្ញុំ។ ដូច្នេះថាតើអាចឱ្យលោក សួន វិសាល ជំនួសមេធាវីការពារជាតិខ្ញុំបានដែរឬមួយក៏យ៉ាងដូចម្តេច។ ប៉ុន្តែ ខ្ញុំចង់បញ្ជាក់បន្ថែមទៀតថា នៅឆ្នាំក្រោយខ្ញុំមានការរវល់តែមួយសប្តាហ៍ប៉ុណ្ណោះ។ ដូច្នេះពេលវេលាដទៃទៀត គឺខ្ញុំទំនេរអាចចូលរួមបាន។

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤០:២៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះក្រុមមេធាវីការពារក្តីលោក ខៀវ សំផន យ៉ាងម៉េចដែរ?

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ទាក់ទងនឹងបញ្ហាជាក់លាក់នៃភាពទំនេរ ហើយនិងកត្តាដែលអាចធ្វើឱ្យយើងមិនទំនេរបាននោះ ចំពោះការរៀបចំសវនាការ ឬក៏ការពិភាក្សាដេញដោលគ្នា -- ដដែលខ្ញុំសូមនិយាយដដែល គឺថាចំពោះលោក ខៀវ សំផន ហើយនិងខាងការពារក្តីគាត់ អ្វីដែលយើងចង់បាននោះ គឺថាពិភាក្សាគ្នាអំពីភស្តុតាងឱ្យបាន -- ពីរឿងរ៉ាវផ្សេងៗ ច្រើនទៀត ផ្សេងទៀតនៅក្នុងវគ្គ២ នេះ ហើយអ្វីៗទាំងអស់ហ្នឹងក៏អាស្រ័យទៅនឹងចំនួនបុគ្គលិកនៅកន្លែងការពារក្តីនេះផងដែរ។
អ៊ីចឹងត្រង់ចំណុចនេះ ខ្ញុំមិនទាន់ដឹងច្បាស់ទេថា ខ្ញុំមានអ្វីខ្លះនៅក្នុងដៃ គឺថាដើម្បីបង្កលទ្ធភាពក្នុងការត្រៀមលក្ខណៈក្នុងការចូលរួមសវនាការពេលខាងមុខលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។

បាទ ដោយខ្លីទេ លោកស្រីមេធាវី ខ្ញុំដឹងថាលោកស្រីនិយាយអំពីការរឹតត្បិតផ្នែកថវិកា ដែលធ្វើឲ្យក្រុមការងាររបស់លោកស្រីមិនគ្រប់គ្រាន់ ក៏ប៉ុន្តែសំណួរបញ្ហារបស់យើងនៅពេលនេះ គឺថាសួរពីភាពទំនេរ។ គឺថាលោកស្រីទំនេរដែរឬទេ? ហើយតើលោក វែកគែន ទំនេរដែរឬទេ? តើលោកស្រីអាចជម្រាបជូនបានទេថាតើអាចមានបញ្ហា ឬក៏យ៉ាងម៉េចក្នុងការមានវត្តមាននៅក្នុងរយៈពេលខែខាងមុខនេះ?

[១៣:៤២:៤៩]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំអាចឆ្លើយតែចំពោះផ្ទាល់ខ្លួនខ្ញុំបានទេ ចំពោះលោក វែកគែន ខ្ញុំអត់ដឹងទេ។ ព្រោះថាយើងមកធ្វើការនៅទីនេះ យើងឆ្លាស់ពេលគ្នា យើងចែកពេលម៉ោងគ្នា។ ដូច្នេះរហូតដល់ពេលនេះ យើងតែងតែសម្រួលគ្នា ធ្វើយ៉ាងណាឲ្យម្នាក់ៗទំនេរ ហើយខ្ញុំគិតថា យើងអាចបន្តអ៊ីចឹងបានទៀត ក៏ប៉ុន្តែដោយសារឥឡូវនេះ ដោយសារគេកាត់ម៉ោងធ្វើការយើងទៀត។ អ៊ីចឹងខ្ញុំក៏ពិបាកឆ្លើយដែរ មិនដឹងថាយ៉ាងម៉េចទេ ក៏ប៉ុន្តែយើងនឹងព្យាយាមធ្វើយ៉ាងណា យើងដាក់វេនគ្នាដើម្បីឲ្យធ្វើដំណើរការទៅមុខបាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះលោក គង់ សំអុន មានបញ្ហាអីទេ?

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំគ្មានបញ្ហាអីទេ ប៉ុន្តែគ្រាន់ថានីតិវិធីរបស់តុលាការកាលណាបើត្រូវបានកោះអញ្ជើញតាមត្រឹមត្រូវតាមនីតិវិធី យើងនឹងអាចធ្វើតាមនោះ។ បាទ សូមអរគុណ។

[១៣:៤៣:៣៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយភាគីពាក់ព័ន្ធទាំងបី ដូចជាមិនទាន់បានគិតអំពីការកំណត់នៅសវនាការបឋមទេ។ ហើយសវនាការដែលចាប់ផ្តើមដំបូង ដែលតាមសំណើសុំរបស់សហព្រះរាជអាជ្ញា គឺលោកលើកឡើងថា គួរតែត្រូវចាប់ផ្តើមនៅចុងខែ២ ឆ្នាំ -- ក្នុងខែកុម្ភៈ ឆ្នាំ២០១៤ ខាងមុខនេះ នៅដំណើការ

ចាប់ផ្ដើមធ្វើសវនាការដេញដោលលើអង្គសេចក្ដី លើសំណុំរឿង០០២/០២ ដែលបានស្នើសុំនេះ ហើយយើងជជែកគ្នារួចហើយ គាត់បាននៅតែប្រកាន់ជំហរថា លទ្ធភាពនេះ គឺអាចធ្វើកើត ប៉ុន្តែចុះខាងភាគីដទៃទៀតវិញ បើសិនជាចាប់ផ្ដើមធ្វើសវនាការលើសំណុំរឿង០០២ នៅចុងខែកុម្ភៈនេះ តើវាបញ្ហាប្រឈមអ្វីដែរឬទេ?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ សម្រាប់ខាងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីមិនមានបញ្ហាអ្វីដែលគួរឲ្យកត់សម្គាល់ទេ។ ប្រសិនបើសវនាការអាចចាប់ផ្ដើមនៅខែកុម្ភៈ ខាងយើងខ្ញុំក៏ធ្វើយ៉ាងណាអាចចាប់ផ្ដើមជាមួយគ្នាបានដែរ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

ខាងក្រុមមេធាវីការពារក្ដី លោក វ៉ិចទ័រ កូប៉េ?

[១៣:៤៥:២២]

**លោក វ៉ិចទ័រ កូប៉េ៖**

ដូចដែលខ្ញុំបានបញ្ជាក់ពីមុនរួចមកហើយ គឺថាយើងមានវត្តមានគ្រប់ពេលនៅក្នុងឆ្នាំនេះ។ ប៉ុន្តែខ្ញុំដូចមិនមានសុទិដ្ឋិនិយមថាអាចមានសវនាការនៅខែកុម្ភៈនោះ ព្រោះថាការកំណត់នេះវាហាក់ដូចជាមិនមានទិដ្ឋភាពពិតប្រាកដអីសោះ។ ប៉ុន្តែខ្ញុំយល់ស្របជាមួយការលើកឡើងរបស់ព្រះរាជអាជ្ញាដែលថាយើងមិនចាំបាច់មានសវនាការ មិនចាំបាច់មានសារណាផ្ដើមសវនាការនោះឡើយ។ ប៉ុន្តែលោកនួន ជាបានបញ្ជាក់មកខាងមេធាវីថា គាត់ចង់បញ្ជាក់ជាមួយតុលាការបន្តិច ចង់ថ្លែងជាមួយតុលាការបន្តិចនៅក្នុងសវនាការបឋម។ ព្រោះថាដោយសារតែមានបញ្ហាមួយចំនួនដូចជារយៈពេលនៃសវនាការ ក៏ដូចជាអាយុរបស់គាត់ជាដើមនោះ។ ប៉ុន្តែយ៉ាងណាក៏ដោយ យើងចង់ឲ្យមានឱកាសសម្រាប់មេធាវីដើម្បីឡើងថ្លែងនៅសវនាការបឋមដំបូងបន្តិច។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជារឿងធម្មតាទេ គឺថាក្រុម ខៀវ សំផន យល់ឃើញថានៅខែកុម្ភៈហ្នឹងដូចជាយើងមិនគិតពីការពិតសោះ។ ថាបើយើងនិយាយពីបញ្ហាច្បាប់ កាលដែលយើងលើកឡើង

ពីព្រឹកមិញហ្នឹង គឺថាយើងត្រូវរៀបចំលក្ខណៈឲ្យបានគ្រប់គ្រាន់ ហើយដើម្បីកុំឲ្យប្រព្រឹត្តកំហុសដដែលៗដូចកាលសំណុំរឿង០០២/០១។ ធ្វើយ៉ាងណាឲ្យប្រសើរជាងកាលណោះ។ អ៊ីចឹងយើងនៅតែប្រកាន់គោលជំហរដដែល គឺថាទាល់តែចេញសាលក្រមហើយបានយើងបន្តទៀត។ នេះគឺជាអ្វីដែលល្អឥតខ្ចោះ។ យើងមិនអាចចាប់ផ្ដើមដំណើរការសំណុំរឿង០០២/០២នេះទេ មុនពេលចេញដីកានោះ។ អ៊ីចឹងទាល់តែសម្រេចលើបញ្ហាសំខាន់ៗមួយចំនួនឲ្យអស់សិនបានអាចចូលទៅបាន។ ហើយការរៀបចំលក្ខណៈនេះ គឺថាយើងរៀបចំដើម្បីឲ្យយើងបង្កើតបញ្ជីឯកសារ អាចពិភាក្សាពីឯកសារ ពីអង្គហេតុហើយនិងអំពីសាក្សីដែលយើងត្រូវកោះហៅមកទីនេះ។ ហើយយើងត្រូវការពេលវេលាច្រើន ការងារច្រើន។ ខ្ញុំនិយាយដដែលៗទេ ក៏ប៉ុន្តែខ្ញុំគិតថា បើយើងគិតពីគុណភាពសល្បត្រូវតែនិយាយដដែលនេះឯង។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៣:៤៨:២៥]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទសូមអរគុណលោកប្រធាន។ ខ្ញុំគិតថាដើម្បីពិភាក្សាបានហ្មត់ចត់អំពីកាលបរិច្ឆេទ គឺថាយើងអាចគ្រោងដំណើរការសវនាការលើអង្គសេចក្ដីនេះ ត្រូវតែពិភាក្សាអំពីដំណាក់កាលដែលត្រូវឆ្លងកាត់មុននឹងចូលទៅដល់ដំណាក់កាលអង្គសេចក្ដីនេះ។

ដំបូងយើងត្រូវរៀបចំសវនាការ គឺថាយើងត្រូវតែចេញសេចក្ដីសម្រេច។ លោកប្រធានត្រូវតែចេញសេចក្ដីសម្រេចលើការតែងតាំង ឬក៏អត់នូវក្រុមប្រឹក្សាជំនុំជម្រះទី២។ ហើយបន្ទាប់មកជំហានទី២នេះគឺថាដោយសារដោយច្បាស់ណាស់ត្រូវតែកំណត់វិសាលភាពនៃសំណុំរឿង០០២/០២នេះទេ។ ហើយនៅពេលដែលយើងធ្វើសេចក្ដីសម្រេចនេះហើយ គឺថាត្រូវមានការពិភាក្សាស៊ីជម្រៅជាងនេះ។ ឥឡូវនេះយើងគ្រាន់តែពិភាក្សាលំៗទេលើបញ្ហាទាំងអស់នេះ។ ហើយនៅពេលដែលថាយើងកំណត់វិសាលភាពរួចហើយៗនៅថ្ងៃអនាគតនោះ យើងនឹងអាចពិភាក្សាអំពីបញ្ជីសាក្សី បញ្ជីឯកសារនានាហើយបន្ទាប់មកទៀតយើងក៏ត្រូវពិចារណាពីការជំទាស់បឋម ដែលនឹងអាចត្រូវលើកឡើងនៅពេលចាប់ផ្ដើមវគ្គពីរយើងនេះ មុននឹងពេលបំបែកដំណើរការនីតិវិធី ហើយអញ្ញត្រកម្មបឋមនេះនឹងត្រូវបានដោះស្រាយ ហើយយើងនឹងពិចារណាថាតើត្រូវធ្វើយ៉ាងណាទៀតនៅពេលនោះ។ តែនៅមានបញ្ហាមួយចំនួនទៀតដែលអាចចោទឡើងដែរ បញ្ហាមួយដែលយើងនឹងពិចារណា ហើយខាងការពារក្ដីនឹងអាចបញ្ជាក់ប្រាប់យើងបាន

គឺថាទាក់ទងនឹងកាយសម្បទានរបស់ជនជាប់ចោទ។ ប៉ុន្មានខែកន្លងមកនេះដែលយើងបានធ្វើកោសល្យវិច័យ ដែលធ្វើការវាយតម្លៃ ដែលធ្វើដោយគ្រូពេទ្យជំនាញខាងមនុស្សចាស់។ អ៊ីចឹង យើងចង់ដឹងថាតាមរយៈការកត់សម្គាល់ខាងការពារក្តីនេះ ថាតើជាការចាំបាច់ដែរឬទេ ក្នុងការធ្វើការពិនិត្យលើបញ្ហាពីខាងកាយសម្បទាក្នុងការទទួលការជំនុំជម្រះពីសំណាក់ជនជាប់ចោទ ឬក៏ខាងការពារក្តីគិតថាបញ្ហានេះមិនចាំបាច់យកមកនិយាយទៀតទេ មិនមានអីចោទទៀតទេ។

[១៣:៥១:៣៣]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនមែនជាវេជ្ជបណ្ឌិត ហើយក៏មិនមែនជាអ្នកឯកទេសខាងវេជ្ជសាស្ត្រនោះដែរ។ ប៉ុន្តែខ្ញុំចង់កត់សម្គាល់ទាក់ទងទៅនឹងអ្វីដែលខ្ញុំបានឃើញជាមួយកូនក្តី គឺថាខ្ញុំមិនមានហេតុផលអ្វីមួយដែលថាអាចសន្និដ្ឋានថាស្ថានភាពកូនក្តីខ្ញុំមានការផ្លាស់ប្តូរតាំងពីមុនរហូតមកដល់ឥឡូវនេះ។ ដូច្នេះហើយខ្ញុំអាចបញ្ជាក់បានតែប៉ុណ្ណេះទេ ថាមិនមានអ្វីប្រែប្រួលទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ ខ្ញុំសូមបញ្ជាក់មួយ។ នៅពេលដែលខ្ញុំនិយាយពីសម្បទានក្នុងការទទួលការកាត់ក្តីហ្នឹង ខ្ញុំមិននិយាយថាទាំងអស់ទេ។ ចង់និយាយថា ទាល់តែមានវត្តមាននៅទីនេះនោះទេ ក្នុងសាលសវនាការទេ គឺថាគ្រាន់តែចង់និយាយអំពីរបៀបរៀបចំសវនាការ គាត់អាចទទួលការជំនុំជម្រះតាមរបៀបណា។ តើយើងអាចទទួលធ្វើដូចពីមុនៗហ្នឹងមក គឺថាគាត់មកទីនេះបួនថ្ងៃមួយសប្តាហ៍ ឬក៏យើងត្រូវរៀបចំកន្លែងណាមួយសម្រាប់គាត់។ លោកចង់ឲ្យយើងគ្រោងធ្វើអ្វី ឬក៏យ៉ាងម៉េច? នេះហើយ ចំណុចទាំងអស់នេះហើយដែលយើងចាប់អារម្មណ៍។

[១៣:៥២:៤៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំចាំបាច់ត្រូវសួរកូនក្តីខ្ញុំឡើងវិញ ដើម្បីឲ្យគាត់អាចណែនាំមកខ្ញុំបាន។ ដូច្នេះ ក្នុងពេលឥឡូវនេះខ្ញុំមិនអាចឆ្លើយជូនលោកចៅក្រមបានទេ។

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំគ្រាន់តែអាចចង្អុលបង្ហាញបន្តិចបន្តួចទេ គឺថាពីរបីខែមុននេះ យើងបានសុំឲ្យកែប្រែម៉ោងពេលសវនាការហ្នឹង សូមឲ្យសម្រាកពេលអាហារថ្ងៃត្រង់ឲ្យបានយូរជាងហ្នឹងបន្តិច ដើម្បីឲ្យលោក ខៀវ

សំផន សម្រាកបានច្រើនជាងហ្នឹង។ ដោយសារមានការ -- គឺថាមានការសម្រាកខ្លី តិចអ៊ីចឹង។ អ៊ីចឹង បើសិនជាក្នុងដំណាក់កាលបន្ទាប់មកនេះ យើងនឹងសុំឲ្យកែប្រែម៉ោងសវនាការ ដើម្បីសម្រួលដល់សុខភាពលោក ខៀវ សំផន។

អ៊ីចឹង ចំពោះម៉ោងនោះ គឺថាបួនថ្ងៃក្នុងមួយសប្តាហ៍ ដូចអង្គាល់សំណុំរឿង០០២/១នេះ ចំពោះលោក ខៀវ សំផន ប្រហែលជាពិបាកនឹងទ្រាំទ្រណាស់ ដោយយោងទៅអាយុគាត់នោះ។

[១៣:៥៤:០២]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ កាលពីម្សិលមិញ យើងបានស្តាប់អំពីទុក្ខកង្វល់របស់មេធាវីលោក ខៀវ សំផន ទាក់ទងទៅនឹងបញ្ហាច្បាប់ ទាក់ទងទៅនឹងការតែងតាំងចៅក្រម ក្រុមប្រឹក្សាជំនុំជម្រះទី២។ គឺថាមានការជំទាស់អំពីភាពស្របច្បាប់នូវការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២នេះ។ អ៊ីចឹង តើមាន -- ហើយថែមទាំងមានការសុំបណ្តឹងជំទាស់ដែរ ឧទាហរណ៍ដូចជា ចៅក្រមបម្រុង ឬក៏ចៅក្រមពេញសិទ្ធិមួយចំនួនដែលនឹងអាចយកទៅបំពេញការងារនៅក្នុងក្រុមប្រឹក្សាជំនុំជម្រះទី២នេះ។ ក៏ប៉ុន្តែខ្ញុំសូមទាញចំណាប់អារម្មណ៍ភាគីទៅលើចំណុចមួយទៀត ក្នុងករណីដែលពុំមានការបង្កើត ឬក៏តែងតាំងចៅក្រមថ្មី។

នៅក្នុងសេចក្តីសម្រេចចុះថ្ងៃទី០៨ កុម្ភៈ ឆ្នាំ២០១៣ គឺជាសេចក្តីសម្រេចទី១របស់តុលាការកំពូលទាក់ទងទៅនឹងដីកាបំបែកដំណើរការនីតិវិធី តុលាការកំពូលបានចង្អុលបង្ហាញដូចតទៅនេះ៖ "អ.វ.ត.ក ត្រូវតែបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២ នៅក្នុងអង្គជំនុំជម្រះសាលាដំបូងដើម្បីជួយសម្រួលដល់ការជំនុំជម្រះឲ្យបានឆាប់រហ័សទៅលើបទចោទផ្សេងៗទៀតនៅក្នុងសំណុំរឿង០០២"។

[១៣:៥៥:៣០]

អង្គជំនុំជម្រះតុលាការកំពូលក៏បានប្រកាសផងដែរ ថាការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២ នេះនឹងអាចការពារបានចំពោះការព្រួយបារម្ភណាមួយទៅលើភាពលម្អៀងជាក់ស្តែង ឬក៏ច្បាស់ក្រឡែតរបស់ចៅក្រមវគ្គទី១ នេះដែលនឹងត្រូវជំនុំជម្រះវគ្គទី២ បន្តទៀត។ ដូច្នេះច្បាស់ណាស់គឺតុលាការកំពូលនេះបានលើកបញ្ហាពាក់ព័ន្ធទៅនឹងការបណ្តឹងជំទាស់លើចៅក្រមនៃចៅក្រមសព្វថ្ងៃនេះ ក្នុងករណីដែលចៅក្រមណាមួយនៅក្នុងអង្គជំនុំជម្រះនេះទៅបំពេញការងារនៅក្នុងក្រុមប្រឹក្សាទី២។ ខ្ញុំមិនដឹងថាយើងត្រូវនិយាយអំពីអ្វីទេ? តែគ្រាន់តែថា យើងត្រូវមានគំនិតជាក់លាក់អំពីកាលបរិច្ឆេទក្នុងការដំណើរការសវនាការ តើនៅថ្ងៃនេះ ឥឡូវនេះ តើយើងមានគ្រោងថានឹងដាក់បណ្តឹងជំទាស់ដែរឬទេភាគីទាំងអស់

នេះ? ពីព្រោះថានៅក្នុងសេចក្តីសម្រេចទី១ នៃតុលាការកំពូលនោះមិនត្រូវបានបញ្ជាក់តែម្តងទៀតទេនៅក្នុងសេចក្តីសម្រេចទី២របស់ខ្លួន។ អ៊ីចឹងសុំយោបល់ពីខាងសហព្រះរាជអាជ្ញា តើមានការចង់បណ្តឹងជិតចិត្តអីដែរឬទេទៅលើចៅក្រមសព្វថ្ងៃនេះ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញា!

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ គឺថាខាងព្រះរាជអាជ្ញាមិនបានរំពឹងថានឹងមានបណ្តឹងជិតចិត្តអ្វីណាមួយនោះឡើយទោះបីថាមានចេញសាលក្រមហើយ ប្រសិនបើមានការចាំបាច់គឺថាយើងអាចនឹងប្តឹងបាន។ ដូច្នេះចំពោះភាគីដែលមិនពេញចិត្តជាមួយនឹងសេចក្តីសម្រេចរបស់ចៅក្រមមិនអាចយកមូលហេតុហ្នឹងមកប្តឹងជិតចិត្តនោះបានឡើយ។ ការសម្រេចសាលក្រមគឺជាសិទ្ធិរបស់ចៅក្រម ដូច្នេះវាមិនអាចទាក់ទងទៅនឹងការប្តឹងជិតចិត្តនោះឡើយ លុះត្រាតែមានការលម្អៀងរបស់ចៅក្រមទើបយើងអាចប្តឹងជិតចិត្តបាន។ ដូច្នេះ ទោះបីថាលោកចៅក្រមចេញសេចក្តីសម្រេចប្រឆាំងជាមួយនឹងអ្វីក៏ដោយក៏វាមិនអាចបង្ហាញថាជាការលម្អៀងនោះឡើយ។ គឺថាយើងផ្អែកទៅលើភស្តុតាងដែលយើងរកឃើញ។ ហើយចៅក្រមដដែលនោះគឺអាចបន្តទៅមុខទៀតបាន។ ដូច្នេះហើយ គឺយើងអាចមានសវនាការជាបន្តបន្ទាប់ជាបណ្តុំគ្នាទៅវិញទៅមកគឺជាអ្វីដែលយើងធ្វើការដោះស្រាយ។

[១៣:៥៨:២៦]

ដូច្នេះ វាមិនមែនជារឿងចម្លែកនោះឡើយដែលចៅក្រមធ្វើការសម្រេចទៅលើភស្តុតាងក្នុងការជំនុំជម្រះទាំងនៅក្នុងរឿងក្តីណាមួយក៏ដោយ នៅពេលនោះគឺថាមេធាវីការពារក្តីអាចលើកជាសារណាមកបាន។ ប្រសិនបើចៅក្រមចេញសេចក្តីសម្រេចដែលមិនគាំទ្រដល់មេធាវីការពារក្តី ក៏មិនអាចលើកហេតុផលហ្នឹងថាជាការលម្អៀងនោះឡើយ។ ដូច្នេះខ្ញុំចង់បញ្ជាក់ថា វាជាការត្រឹមត្រូវហើយយើងនឹងឯកភាព ហើយគម្រោងដែលយើងចង់ស្នើឡើងគឺផ្អែកទៅលើការពិតដែលថាភស្តុតាងនៅក្នុងសំណុំរឿង ០០២/០១ នឹងក្លាយទៅជាកំណត់ត្រាសម្រាប់សំណុំរឿងបន្ទាប់។ ហើយផ្អែកទៅលើភស្តុតាងទាំងអស់នោះដើម្បីឲ្យវាមានប្រសិទ្ធភាព គឺថាជាជាងការយើងមានចៅក្រមថ្មី យើងចង់ឲ្យមានចៅក្រមដដែលដែលបានដឹងឮរឿងទាំងអស់នោះ។ ហេតុដូច្នេះហើយទើបយើងចង់ដឹងថាតើមានចៅក្រមរូបណាដែលចាកចេញ ហើយចៅក្រមរូបណាដែលនៅនៅក្នុងសំណុំរឿង០០២/០២នេះ? ព្រោះថាយើងចង់ដឹងនៅ

ពេលឥឡូវនេះជាជាងរង់ចាំនៅពេលខាងមុខ ដើម្បីឲ្យយើងដឹងអំពីព័ត៌មានទាំងអស់នេះ។ ដូច្នេះខ្ញុំនឹងមិនរំពឹងថាយើងនឹងបណ្ដឹងជិតចិត្ត ឬក៏បណ្ដឹងអ្វីប្រឆាំងជាមួយនឹងចៅក្រមក្នុងសំណុំ០០២/០២ នោះឡើយ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញក្រុមមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

[១៤:០០:០៣]

**លោកស្រី បេនី យេះ៖**

សូមអរគុណលោកប្រធាន។ ក្នុងនាមដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំក៏មិនរំពឹងថានឹងមានសារណាប្ដឹងទៅលើការលម្អៀង ឬក៏អ្វីនោះឡើយ គឺយើងយល់ស្របដូចគ្នាទៅនឹងសហព្រះរាជអាជ្ញាអន្តរជាតិ។ តាមយើងៗយល់ឃើញថា ការបំបែកកិច្ចដំណើរការនីតិវិធីមិនបង្ហាញថា អង្គជំនុំជម្រះនឹងមិនគួរជំនុំជម្រះនៅដោយចៅក្រមដដែលអ្វីនោះឡើយ។ ដូច្នេះប្រសិនបើយើងអាចជំនុំជម្រះដោយក្រុមប្រឹក្សាដដែល គឺវាជាការល្អ ព្រោះវាអាចនឹងមានការចំណេញពេលវេលា ឬក៏មានបញ្ហាស្រួល សម្រួលការងារនានា។

**ប្រធានអង្គជំនុំ៖**

សូមអរគុណ។ ចុះក្រុមមេធាវីការពារក្ដីយ៉ាងម៉េចដែរ?

**លោក វ៉ិចទ័រ កូប៉េះ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំប្រាកដថា គឺថាមេធាវីការពារក្ដីមានការលំបាកក្នុងការឆ្លើយនូវសំណួរនេះណាស់។ វាអាស្រ័យទៅលើកាលៈទេសៈទាំងអស់ ហើយនិងការវិវត្តន៍នៅក្នុងការលទ្ធភាពដែលបើកការជំនុំជម្រះ។ ក្នុងពេលនេះគឺយើងមិនទាន់ពិចារណាអ្វីបានទេ ប៉ុន្តែខ្ញុំអាចជម្រាបបានថា នឹងមានខណៈពេលពីរនៅពេលខាងមុខនោះ ដែលអាចនឹងធ្វើឲ្យមានការពិចារណាជាថ្មី គឺថាបើសិនជាមានសេចក្ដីសម្រេចថាតើដាក់ចូលមន្ទីរស-២១ ហើយនិងត្រូវជម្រះដោយក្រុមប្រឹក្សាចៅក្រមដដែល ដែលបានជំនុំជម្រះករណីរឿងស-២១ នៅក្នុងរឿងក្ដី០០១របស់ ឌុច នោះ។ ពេលនោះជាកាលៈទេសៈមួយហើយ។

[១៤:០១:៥៥]

ហើយមួយទៀត គឺថាចៅក្រមរូបទាំងនោះឯង គឺថាអាចនឹងបានធ្វើសេចក្ដីសម្រេចនៅក្នុងរឿង

នោះ។ នេះជាកាលៈទេសៈពីរ ដែលយើងនឹងពិនិត្យមើល ហើយក្រៅពីហ្នឹងគឺថាខ្ញុំយល់ថាខាងមេធាវីការពារក្តីខ្ញុំនេះមានការលំបាកនឹងឆ្លើយឲ្យជាក់លាក់ណាស់។ សូមអរគុណបាទ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកស្រីមេធាវីការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនដឹងថាយើងអាចចោទបញ្ហានេះថាទៅជាបណ្តឹងជិតចិត្តនោះទេ។ យើងបណ្តឹងជិតចិត្តនោះទាល់តែយើងមើលឃើញថាមានភាពលម្អៀង។ ឥឡូវនេះអស់លោកលោកស្រីចៅក្រមកំពុងតែធ្វើការសម្រេច។ អ៊ីចឹងនៅក្នុងវគ្គ០២/២នេះ គឺថាយើងទាល់តែចាំតុលាការកំពូលចេញសាលដីកាសិន ហើយខ្ញុំគិតថានេះវាសមហេតុផលជាងផ្នែកច្បាប់។ យើងមានបញ្ហាមួយចំនួនដែលថាមិនទាន់ដោះស្រាយនៅក្នុងវគ្គ២/២ហ្នឹង ហើយយើងនឹងមានការពិភាក្សាបន្ត ហើយខ្ញុំត្រូវតែច្បាស់អំពីអង្គច្បាប់មួយចំនួនសិន។ អ៊ីចឹងបើតាមផ្លូវច្បាប់នោះខ្ញុំមិនអាចគ្រោងមុនបានទេ ថាបណ្តឹងជិតចិត្ត ឬមិនជិតចិត្តហ្នឹង ខ្ញុំគិតតែអំពីភាពសមហេតុផល ហើយនិងភាពច្បាស់លាស់នៃការពិភាក្សាតាមផ្លូវច្បាប់តែប៉ុនន្ទុំងទេ។

[១៤:០៣:៥៥]

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់ថា ប្រហែលជាលឿនពេកសម្រាប់យើងក្នុងការធ្វើការសន្និដ្ឋានថា តើមានបណ្តឹងជិតចិត្តឬអត់ ក្នុងខណៈពេលដែលយើងមិនដឹងថាលោកចៅក្រមរូបណាដែលត្រូវបានតែងតាំងនោះ ហើយស្ថានភាពអ្វីខ្លះដែលអាចប៉ះពាល់ទៅដល់ការធានានូវឯករាជ្យភាព ឬក៏ភាពមិនលម្អៀងរបស់លោកចៅក្រមរូបណានោះទេ។

ហេតុដូច្នេះទោះបីជានៅពេលនេះយើងថា យើងមិនមានការប្តឹងជិតចិត្ត ក៏សិទ្ធិនៅក្នុងការធ្វើបណ្តឹងជិតចិត្តនេះនៅតែអាចប្រើប្រាស់បាននៅពេលក្រោយដដែលទេ។ ហើយអ៊ីចឹងខ្ញុំសូមជូនយោបល់ថាយើងមិនអាចផ្តល់ជាអនុសាសន៍អ្វីទាក់ទងទៅនឹងថាតើមានបណ្តឹងជិតចិត្តឬក៏អត់នោះទេ។ ហើយយើងរក្សាសិទ្ធិក្នុងការពិនិត្យទៅលើនីតិវិធីទាំងឡាយដែលពាក់ព័ន្ធទៅនឹងការធ្វើបណ្តឹងជិតចិត្តនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណលោកប្រធាន។ អ្វីដែលខ្ញុំកត់សម្គាល់ពីការពិភាក្សាយើងនេះ គឺថាយើងត្រូវធ្វើសេចក្ដីសម្រេចមួយចំនួន។ ខ្ញុំក៏កត់សម្គាល់ឃើញផងដែរថា ការ -- សេចក្ដីសម្រេចទៅលើវិសាលភាពនៃការកាត់ក្ដីយើងនេះ ប្រហែលជាអាចថាមានការប្ដឹងឧទ្ធរណ៍ដែរ។ ប្រហែលជាភាគីមិនមានគោលជំហរដូចគ្នាដែរទេ ថាត្រូវបញ្ចូលអ្វីនៅក្នុងវិសាលភាពនៃវគ្គពីរយើងនេះ តើយើងត្រូវគិតពីភាក្សាឲ្យបានស៊ីជម្រៅទាក់ទងនឹង -- ស៊ីជម្រៅនៅពេលណា នៅពេលដែលយើងមិនទាន់បានសម្រេចវិសាលភាពនេះ ត្រូវសម្រេចវិសាលភាពសិន។ អ៊ីចឹងអាច -- ព្រោះថាវាអាចប៉ះពាល់ទៅដល់ការប្ដឹងជិតចិត្តទៀតផង។

[១៤:០៥:៥៨]

ខ្ញុំគិតថា ឥឡូវនេះប្រហែលជាអ៊ីចឹងហើយ ប្រហែលមិនអាចប្ដឹង ធ្វើបណ្ដឹងជិតចិត្តបានទេនៅពេលនេះ។ ឥឡូវនេះ តើមានសេចក្ដីសម្រេចផ្សេងទៀត ឬក៏ជំហានផ្សេងទៀតត្រូវឆ្លងកាត់ជាមុនដែរឬទេក្នុងដំណើរការនីតិវិធីមុននឹងយើងចាប់ផ្ដើមនិយាយអំពីអង្គសេចក្ដី? តើអស់លោកទាំងអស់នេះ គិតថាត្រូវសម្រេចអ្វីជាមុនសិនទេ មុននឹងចូលទៅដល់អង្គសេចក្ដីនេះ?

**លោក នីកូឡាស គូមជែន៖**

ចំណុចមួយដែលខ្ញុំគិតឃើញនោះ ដែលថាសំខាន់ក្នុងការរៀបចំពេលនេះហ្នឹង គឺថាតើអង្គជំនុំជម្រះទទួលយកសំណើរបស់សហព្រះរាជអាជ្ញាដែលថា រឿងក្ដី០០២/០២ ជាការបន្តរឿងក្ដី ០០២/០១ ដែរឬទេ? ដើម្បីឲ្យយើងអាចប្រើភស្តុតាងនៅក្នុងរឿងក្ដី០០២/០១ នុ៎ង គឺថាយកមកប្រើបាន ដែលថាគេបានធ្វើការដេញដោលទាំងអស់ ហើយឯកសារទាំងឡាយដែលបានដាក់តទល់ដោយភាគីចំពោះជនជាប់ចោទនេះ គឺថាទាក់ទងទៅនឹងការត្រៀមរៀបចំហ្នឹង ថាតើឯកសារទាំងនោះអាចនឹងទទួលចូលក្នុងវគ្គពីរនេះដែរឬទេ? អ៊ីចឹងអង្គជំនុំជម្រះតុលាការកំពូលនោះក៏បានបង្គាប់ថា ការជំនុំជម្រះទី២ នេះត្រូវតែចាប់ផ្ដើមឲ្យបានឆាប់ៗ គឺថាបន្ទាប់ពីការបញ្ចប់នូវសវនាការពិភាក្សា -- បញ្ចប់ការពិភាក្សាដេញដោលរឿងក្ដី០០២/០១ ក៏បន្ទាប់ពី ធី.អឹម.អឹម នេះ គឺថាយើងមិនអាចរង់ចាំប្រាំបីខែក្រោយពីនោះទេ។ នេះជាដីកាបង្គាប់។

[១៤:០៧:៥០]

ផែនការរបស់យើងខ្ញុំដែលយើងបានដាក់ជូនហ្នឹង គឺយ៉ាងហោចណាស់ត្រូវចាប់ផ្ដើមពាក់កណ្ដាលពេលវេលានោះគឺថាក្នុងរយៈពេលបួនខែ។ អ៊ីចឹងវាជា -- វាអាស្រ័យទៅលើថាតើភស្តុតាងនៅក្នុងរឿងក្ដី ០០២/០១ នោះអាចនឹងទទួលយកជាភស្តុតាងក្នុងវគ្គទី២ដែរឬអត់ទេ? បើយើងនិយាយបែបនោះថាដាក់ចូលបាន បើយើងប្រើគឺថាអាចនឹងរឿងក្ដី ០០២/០២ អាចនឹងប្រើពេលតិចជាង គឺមិនអាចថាប្រើពេលមួយឆ្នាំ ឬមួយឆ្នាំកន្លះដូច ០០១ នោះទេ។ បាទ បើយើងទទួលយកនោះ គឺថាអាចនឹងធ្វើឲ្យរយៈពេលខ្លីជាងនៅក្នុងរឿងក្ដី០០២/០២ នេះ។ ពេលនោះតុលាការនឹងពិចារណាលើភស្តុតាងពីឆ្នាំទី១ ដូចបានធ្វើរួចហើយ ០០២/០១ នោះ ហើយនិងភស្តុតាងផ្សេងទៀតដែលដាក់នៅក្នុងវគ្គបន្ទាប់នេះ។

បើសិនជាមិនមានការទទួលស្គាល់ទេ ខ្ញុំមិនឮការជំទាស់ពីភាគីផ្សេងៗទេ នៅក្នុងការប្រជុំនេះ ហើយបើសិនជាមិនមានការជំទាស់ទេ យើងអាចនឹងបន្តជាមួយផែនការរបស់យើង។ បើសិនជាមានការជំទាស់ គឺយើងមានជម្រើសមួយទៀត ថាតើត្រូវធ្វើតាមការបង្គាប់តុលាការកំពូល ហើយនិងបន្ទាប់ពីមានការសម្រេចរបស់អង្គជំនុំជម្រះតុលាការដំបូងនេះផងដែរនោះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

**កញ្ញា អង់តា ហ្គីសសេះ៖**

លោកប្រធាន លើចំណុចនេះ ដើម្បីនិយាយអំពីឧទាហរណ៍របស់សហព្រះរាជអាជ្ញាឡើងវិញ ដែលថាទាក់ទងឯកសារដែលដាក់ចូលសំណុំរឿង ហើយដែលបង្ហាញ -- ដាក់បង្ហាញជូនហើយ តើនៅក្រុមប្រឹក្សាជំនុំជម្រះដដែលនេះ នេះគឺថាយើងនឹងមានបញ្ហាថា លោកស្រីចៅក្រមហ្នឹងនឹងធ្វើសេចក្ដីសម្រេចដូចគ្នានៅក្នុងពេលនេះទេ។ អ៊ីចឹងពេលនោះហ្នឹង ថាបណ្ដឹងឧទ្ធរណ៍នោះនឹងលែងមានហើយ។ បើសិនជាយើងត្រូវធ្វើបណ្ដឹងឧទ្ធរណ៍ពីសេចក្ដីសម្រេចចិត្តរបស់លោក លោកស្រីចៅក្រមគឺថាយើងត្រូវធ្វើនៅក្នុងពេលជាមួយគ្នា នៅពេលចេញសាលដីកាលើអង្គសេចក្ដី។ អ៊ីចឹងមិនទាក់ទងទៅនឹងការទទួលយកភស្តុតាងមួយចំនួន ទោះបីជាមានការជំទាស់ក៏ដោយ។ បញ្ហានេះក៏មិនអាចមានកើតឡើងដែរ ប្រសិនបើយើងបានសេចក្ដីសម្រេចជាចុងក្រោយមួយនោះ សាលដីកា ហើយនៅក្នុងពេលជំនុំជម្រះ ០០២/២នេះ។ បើសិន--

**អ្នកបកប្រែ៖**

លោកប្រធាន សូមឲ្យគាត់បន្ថយបន្តិច ព្រោះអ្នកបកប្រែចាប់អត់បាន។

**កញ្ញា អង់តា ហ្គីសសេ៖**

ឥឡូវខ្ញុំសូមសង្ខេប។ ប្រសិនបើយើងត្រូវប្ដឹងឧទ្ធរណ៍អំពីសាលដីកានេះ នៅក្នុងសំណុំរឿង ០០២/១នេះ ខាងការពារក្ដីនឹងប្ដឹងឧទ្ធរណ៍លើអង្គសេចក្ដី ហើយនិងលើសេចក្ដីសម្រេចមួយចំនួនដែល លោក លោកស្រីចៅក្រមបានធ្វើ ហើយដែលកាលណោះយើងអត់ទាន់បានប្ដឹងឧទ្ធរណ៍ទេ។ អ៊ីចឹង យើងនឹងប្ដឹងឧទ្ធរណ៍ក្នុងពេលជាមួយ ហើយតាម -- នៅក្នុងសេចក្ដីសម្រេចទាំងអស់នេះ មានសេចក្ដី សម្រេចមួយចំនួនទៅលើឯកសារ ដែលអស់លោក លោកស្រីចៅក្រមទទួលយកជាភស្តុតាង។ អ៊ីចឹង យើងនឹងជំទាស់ផងដែរ។

[១៤:១១:២៤]

ហើយនៅក្នុងសំណុំរឿង០០២/២នេះ នឹងមានការ -- ផលប៉ះពាល់របស់សេចក្ដីសម្រេចរបស់ តុលាការកំពូលទៅលើភាពទទួលយកបាននៃឯកសារនៅក្នុងសំណុំរឿង០០២/២នេះ។ អានេះគ្រាន់តែជា ការប្រមើលគិតជាមុនទេ។ ប្រសិនជាចៅក្រមទាំងអស់ហ្នឹង សព្វថ្ងៃនេះ ដូចជាព្រះរាជអាជ្ញាគាត់សុំ ឲ្យដាក់ឯកសារទាំងអស់នេះ ចូលទៅក្នុងសំណុំរឿង០០២/២។ អ៊ីចឹងនៅពេលហ្នឹង យើងមិនអាច -- យើងមានរឿងត្រូវទៅជំទាស់ទេ បើពេលនោះ នឹងចេញសេចក្ដីសម្រេចដូចគ្នាដដែលជាដដែលទេ។ ក៏ ប៉ុន្តែបើសិនជាមានចៅក្រមជំនុំជម្រះទី២ ពេលនោះ ដោយសារគាត់មិនបានចូលរួមក្នុងការពិភាក្សាអំពី ឯកសារនៅក្នុងសំណុំរឿងយើងនេះទេនេះ អ៊ីចឹងដោយសារគាត់មិនបានធ្វើអ៊ីចឹង អ៊ីចឹងមិនអាចមានការ សង្កេតតាមផ្លូវច្បាប់ ឬក៏ថាដែលគាត់ចៅក្រមថ្មីនោះ អ៊ីចឹងគោលជំហររបស់ពួកខ្ញុំនេះនឹងផ្លាស់ប្ដូរដែរ។ អ៊ីចឹង ខាងការពារក្ដីនេះនឹងធ្វើការសម្រេចចិត្ត បើសិនជាមានការបង្កើតក្រុមជំនុំជម្រះទី២។ វាជាការ លំបាកណាស់ បើថាបើយើងមិនចាំសាលដីកាទេ តើយើងត្រូវយ៉ាងហោចណាស់ ក៏ដឹងថាយកចៅក្រម សព្វថ្ងៃនេះទៅជំនុំជម្រះ ឬក៏បង្កើតក្រុមប្រឹក្សាទី២។ គោលជំហរយើងប្រែប្រួលទៅតាមនុ៎ងឯង។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ចំណុចនេះវាត្រឡប់ទៅជំហររបស់យើងខាងដើម ទាក់ទង

ទៅនឹងការរង់ចាំរហូតដល់សាលក្រមចូលស្ថាពរ ទើបឲ្យមានសវនាការលើកទី២។ ក៏ប៉ុន្តែទន្ទឹមនេះ បើតុលាការត្រូវកម្រិតថាឲ្យត្រូវមានការបើកសវនាការលើកទី២នេះក្នុងពេលឆាប់ៗ។ អ៊ីចឹងការពិភាក្សាដេញដោលទៅលើភស្តុតាងដែលបានធ្វើរួចមកហើយនោះ មិនអាចកម្រិតថាយកភស្តុតាងដែលមាននៅក្នុងសំណុំរឿង០០២/០១នោះជាបានការទាំងស្រុង ដោយមិនឲ្យមានការដេញដោលនៅក្នុងដំណាក់កាលទី២នេះទេក្នុងករណីដែលជាប់ពាក់ព័ន្ធនោះ ពីព្រោះថាភស្តុតាងដែលមាននៅក្នុងដំណាក់កាលក្នុងសំណុំរឿង០០២/០១នោះមិនទាន់ចូលជាស្ថាពរ អ៊ីចឹងការដេញដោលវានៅតែៗលទ្ធភាពរបស់ភាគីអាចធ្វើបានដដែល។ អានេះវាអាចបង្កើតឲ្យមានភាពស្មុគស្មាញនៅក្នុងសវនាការនៅក្នុងសំណុំរឿង០០២/០២នេះផងដែរ។

អ៊ីចឹងការស្នើសុំឲ្យលោកប្រធានបញ្ជាក់អំពីស្ថានភាពនៃសំណុំរឿង០០២/០២ថាវាជាសំណុំរឿងដោយឡែក ឬមួយក៏ជាសំណុំរឿងតែមួយនៅក្នុង០០២/០១នេះជាមួយគ្នា? អានេះវាក៏ជាចំណុចចាំបាច់មួយសម្រាប់បញ្ជាក់ទៅលើស្ថានភាពនៃសំណុំរឿងនេះផងដែរ។ សូមអរគុណ។

[១៤:១៤:៤៩]

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការសាជាថ្មី។ សម្រាប់បញ្ហាផ្សេងទៀតគឺយើងមិនមានអ្វីដែលជាបញ្ហាដែលគួរឲ្យកត់សម្គាល់ទេដោយសារលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ បានលើកអស់ហើយនូវអ្វីដែលជាដំណាក់កាលផ្សេងៗនៅក្នុងដំណាក់កាលរៀបចំមុននឹងមានសវនាការទៅលើភស្តុតាង។ ក៏ប៉ុន្តែ ខ្ញុំគ្រាន់តែខ្ញុំចង់ធ្វើការកត់សម្គាល់បន្តិចលោក គង់ សំអុន អម្បាញ់មិញគាត់និយាយថា យកភស្តុតាងពីករណី០០២/០១ យកមកធ្វើជាបានការ។ នៅក្នុងករណី០០២/០២ ខ្ញុំគិតថាករណីនេះខ្ញុំឯកភាពតាម ក៏ប៉ុន្តែប្រហែលជាខាងសហព្រះរាជអាជ្ញាគាត់និយាយអំពីព័ត៌មាន ឬក៏ប្រតិចារឹកដែលមាននៅក្នុងករណី០០២/០១ យកមកប្រើប្រាស់មិនមែនយកជាបានការនៅក្នុងករណី០០២នេះ។ ហើយខ្ញុំគិតថា--

*(មានបញ្ហាបច្ចេកទេស)*

[១៤:១៦:៣២]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ ខ្ញុំសុំការបំភ្លឺពីសហព្រះរាជអាជ្ញា។ នៅពេលដែលលោកនិយាយថា យើងអាចចាប់ផ្តើមសវនាការនៅចុងខែកុម្ភៈនេះបាន តើលោកគ្រោងក្នុងការបើកការជំនុំជម្រះតែម្តង ឬក៏គ្រាន់តែបើកសវនាការអង្គសេចក្តីតែប៉ុណ្ណោះ?

**លោក នីកូឡាស គូមជែន៖**

គឺការចាប់ផ្តើមនូវសវនាការដេញដោលលើភស្តុតាង ស្តាប់ភស្តុតាងបាទ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

អ៊ីចឹងគឺបានន័យថាការងារត្រៀមលក្ខណៈត្រូវបានបំពេញរួចហើយ អ៊ីចឹងយើងអាចចេញសេចក្តីសម្រេច -- ខ្ញុំគិតថាយើងទាំងអស់គ្នាប្រហែលយល់គ្នាហើយ។ ខ្ញុំពុំមានសំណួរអីសួរទៀតទៅភាគីទេលោកប្រធាន។

[១៤:១៧:៣៨]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះយើងចូលទៅរបៀបវារៈទី៥ ដែលជារបៀបវារៈចុងក្រោយទាំងអស់នៅក្នុងកិច្ចពិភាក្សានៃកិច្ចប្រជុំនេះ។ ការកំណត់អំពីបញ្ហាស្នូលនៃសំណុំរឿង ០០២/០២ មុននឹងបញ្ចប់កិច្ចប្រជុំរៀបចំសវនាការនេះ អង្គជំនុំជម្រះសូមអញ្ជើញភាគីឲ្យធ្វើការកំណត់អំពីបញ្ហាមួយចំនួនដែលលោក លោកស្រីគិតថាជាបញ្ហាស្នូលជាសារវន្តនៃសំណុំរឿង០០២/០២ ហើយដែលមិនទាន់ត្រូវបានលើកឡើងនៅក្នុងកិច្ចប្រជុំពិភាក្សានៅពេលនេះ។ អង្គជំនុំជម្រះសូមបញ្ជាក់ថា ពាក់ព័ន្ធទៅនឹងរបៀបវារៈដែលបានពិភាក្សារួចហើយនេះ គោលបំណងនៃកិច្ចប្រជុំនេះគឺដើម្បីដោះស្រាយបញ្ហាបច្ចេកទេស បញ្ហានៃការអនុវត្តសម្រាប់ត្រៀមរៀបចំលើសំណុំរឿង០០២/០២។ ហេតុដូច្នេះរបៀបវារៈនេះត្រូវកម្រិតត្រឹមតែការលើកឡើងពីបញ្ហាគន្លឹះនានាប៉ុណ្ណោះដោយមិនចាំបាច់ពង្រីកដល់ការផ្តល់នូវសារណា ឬទឡ្ហីករណ៍អំពីបញ្ហាទាំងឡាយនេះទេ។ ហើយអាស្រ័យហេតុនេះសារណានិងទឡ្ហីករណ៍នានា នឹងត្រូវធ្វើការដោះស្រាយនៅក្នុងសវនាការពិភាក្សាដេញដោលនៅពេលខាងមុខ ឬក៏តាមរយៈសារណាជាលាយលក្ខណ៍អក្សរ។

ហើយជាដំបូងនេះសូមផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញាដើម្បីលើកឡើងនូវការកំណត់អំពីបញ្ហាស្នូលជាសារវន្តដែលក្នុងកិច្ចប្រជុំនេះយើងមិនទាន់បានលើកឡើងប្រសិនបើមាន។

[១៤:១៩:២៩]

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន លោកស្រីចៅក្រម។ យើងជឿជាក់ថា ខ្ញុំបានទទួលឱកាសដើម្បីលើកនូវបញ្ហាសំខាន់ៗដែលយើងខ្ញុំយល់ថា មានការចាំបាច់ក្នុងការត្រៀមរៀបចំដើម្បីចាប់ផ្ដើមហើយនិងការបញ្ចប់រឿងក្ដី០០២/០២ ដោយមានប្រសិទ្ធភាព។

ចំណុចបន្ថែមដែលខ្ញុំចង់ស្នើនោះ គឺផ្អែកទៅលើភស្តុតាងដ៏ច្រើនដែលយើងទទួលបានពីលោកប្រធានរដ្ឋបាលស្តីទី និងអនុប្រធានរដ្ឋបាលនិយាយអំពីថ្លៃចំណាយសរុប ដែលថានឹងបើកចំហដល់លោកលោកស្រីចៅក្រមសម្រេច។ ជម្រើសដែលយើងបានស្នើនោះគឺចង់រក្សាទុកអង្គជំនុំជម្រះដដែលដើម្បីនឹងធ្វើសវនាការលើភស្តុតាងលើរឿងក្ដីបន្ទាប់។ នៅក្នុងប្រធានរបៀបវារៈនោះ គឺថានឹងរក្សាទុកនូវបុគ្គលិកដែលមាន ហើយរដ្ឋបាលក៏បានបញ្ជាក់បែបនោះថាអាចធ្វើទៅបាន។ ដូច្នេះគឺឃើញមានជម្រើសបែបនេះ។ យើងបានស្ដាប់ពីរដ្ឋបាលថា គឺថាប្រហែលជា១,១លានសម្រាប់ចំណាយកន្លែងមកនេះ។ ដូច្នេះក្នុងរយៈពេលមិនលើសពីប្រាំមួយខែ អ៊ីចឹងគឺថាអាចកន្លះលាន ឬក៏១លាន។

ចំពោះការបន្ថែមចៅក្រមផ្សេងថ្មី គឺថាអាចនឹងបង្កើនថ្លៃចំណាយហ្នឹងថែមទៀតដែរ។ ប៉ុន្តែខ្ញុំចង់ជម្រាបថា ជម្រើសដែលចំណាយលុយច្រើនជាងគេនោះគឺថាការបន្លាយពេល ឬក៏ការអូសបន្លាយពេលមិនបានចាប់ផ្ដើមឲ្យបានទាន់ពេលនោះឯងនៅក្នុងរឿងក្ដី០០២/០២។ ពីព្រោះថា បើយើងពិនិត្យទៅគឺថាតុលាការចំណាយច្រើនជាង១លានដុល្លារក្នុងមួយខែ។

[១៤:២១:២៥]

ដូច្នេះ រៀងរាល់ថ្ងៃដែលយើងបានអូសបន្លាយ ឧទាហរណ៍ថា ប្រាំបីខែគឺយើងអាចចំណាយ៨លានដុល្លារនោះដែរ។ យើងបានធ្វើការតិចជាង បើយើងអាចចាប់ផ្ដើមបានឆាប់រហ័សមួយនឹងចៅក្រមដដែល។ បើសិនយើងចាត់តាំងអង្គជំនុំជម្រះថ្មី នាំចៅក្រមថ្មីនឹងចំណាយលើសហ្នឹងទៅទៀត។ អ៊ីចឹងសេចក្ដីសម្រេច ឬក៏សាលដីការបស់អង្គជំនុំជម្រះតុលាការកំពូលនោះគឺ បង្គាប់ហើយថា គឺថាត្រូវតែចាប់ផ្ដើមរឿងក្ដី០០២ឲ្យបានឆាប់ គឺថាដោយផ្អែកទៅលើជម្រើសផ្សេងៗដែលអង្គចៅក្រមសាលាដំបូងមាន ហើយនិងផ្អែកតាមសំណើរបស់យើងខ្ញុំ គឺថាអង្គជំនុំជម្រះជំនុំជម្រះសាលាដំបូងដដែលហើយនិងប្រើឯកសារ និងភស្តុតាងដែលប្រើក្នុងរឿងក្ដី០០២/០១ហ្នឹង សម្រាប់ប្រើនៅក្នុងវគ្គទី២ហើយនិងចាប់ផ្ដើមការជំនុំជម្រះឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

ខ្ញុំមានសំណួរមួយ តើលោកមិនជឿទេថាពេលវេលាចាំបាច់សម្រាប់អង្គជំនុំជម្រះក្នុងការតាក់តែងសាលាក្រមនោះ ជាពេលវេលាមួយដែលថាអ្នកទាំងអស់គ្នាមិនយល់ទេ។ នៅពេលដែលយើងចាប់ផ្ដើមសវនាការ០០២/០២ ហើយនៅក្នុងពេលទន្ទឹមគ្នានោះយើងតាក់តែងសាលក្រមនៃរឿងក្ដី -- នៃការជំនុំជម្រះក្ដីមុននោះ តើវាអាចឲ្យចំណេញពេលវេលាដែរឬទេ?

នេះជាការកត់សម្គាល់ផ្ទាល់ខ្លួនរបស់ខ្ញុំ នៅពេលដែលយើងមានសវនាការមានការលំបាកណាស់ក្នុងការផ្ដោតអារម្មណ៍ទៅលើសវនាការផង ហើយទៅលើការរៀបចំសរសេរសាលក្រមផង។ នេះជាបញ្ហាបច្ចេកទេសវាពិបាកណាស់ យើងមិនអាចធ្វើបញ្ហាពីរទៅទន្ទឹមគ្នាអ៊ីចឹង។ ដូច្នេះ យើងមិនអាចត្រឹមតែត្រូវការបុគ្គលិកបន្ថែមទេ ដើម្បីជួយសម្រួលឲ្យសរសេរសាលក្រមនោះ យើងត្រូវមានលទ្ធភាពក្នុងការផ្ដោតអារម្មណ៍យ៉ាងស៊ីជម្រៅទៅលើបញ្ហាចម្រូងចម្រាស ហើយដែលត្រូវការពេលវេលានោះ។

[១៤:២៤:០៦]

នៅពេលដែលលោកនិយាយថា បើយើងចាប់ផ្ដើមភ្លាមៗនោះយើងចំណេញរាប់លានដុល្លារ។ ខ្ញុំដូចជាភ្ញាក់ផ្អើលណាស់នូវសម្ដីរបស់លោកបែបនេះនោះ។ ពីព្រោះទោះជាយ៉ាងណាក៏ដោយ យើងមិនអាចធ្វើរឿងពីទន្ទឹមគ្នា គឺថាយើងកំពុងតែរវល់នៅក្នុងការសរសេរសាលក្រមផង ហើយមកមមាញឹកក្នុងការធ្វើសវនាការ មកស្ដាប់សាក្សីស្ដាប់អីអ៊ីចឹងក្នុងវគ្គ០២ទៀតនោះ វាដូចជាពិបាកណាស់។ យើងពិបាករៀបចំខ្លួនណាស់។ ដូច្នេះយើងមិនអាចធ្វើឲ្យដូចជាដំបងវេទមន្តអីឲ្យយើងមកដោះស្រាយបញ្ហាបានទេ វាជាការលំបាក។ ដូច្នេះខ្ញុំចង់ឲ្យអស់លោក លោកស្រីចាប់អារម្មណ៍ទៅលើសំណួររបស់ខ្ញុំនេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានជាទីគោរព! ខ្ញុំមានចំណុចមួយដើម្បីត្រឡប់ទៅលើអ្វីដែលលោកចៅក្រម ឡាវ៉ែន៍ទើបតែលើកឡើងអម្បាញ់មិញនេះ។ ក្នុងក្របខ័ណ្ឌនៃការពិចារណារបស់អង្គជំនុំជម្រះទៅលើការចាប់ផ្ដើមសវនាការ០០២/០២ ហើយនៅសវនាការនៅពេលខាងមុខនេះ ខ្ញុំសូមរំឭកថា ប្រសិនបើមានជំហរថាចាប់ផ្ដើមក្រោយសាលក្រម ០០២/០១ នោះ គឺថាចាប់ពីពេលដែលអង្គជំនុំជម្រះចេញសាលក្រមនោះ

គឺថាយើងគិតរយៈពេលប្តឹងសាទុក្ខ ហើយភាគីក្នុងពេលនុ៎ងគឺគាត់ត្រូវតែរៀបចំដើម្បីធ្វើបណ្តឹងសាទុក្ខនេះ ដោយមានពេលវេលាខ្លី ហើយយើងត្រូវមានកាតព្វកិច្ចក្នុងការដាក់ឯកសារជាពីរភាសាទៀត។ ហើយយើងត្រូវតែប្តឹងសាទុក្ខទៅលើសាលក្រមនៃអង្គសេចក្តីផង និងសេចក្តីសម្រេចផ្សេងៗរបស់អង្គជំនុំជម្រះផងក្នុងពេលទន្ទឹមគ្នា។ ដូច្នេះ វាជាបញ្ហាធំណាស់ចំពោះពួកយើងនៅពេលដែលយើងគិតថាចាប់ផ្តើមសវនាការ ០០២/០២ ក្នុងពេលដំណាលគ្នានឹងការរៀបចំការធ្វើបណ្តឹងសាទុក្ខនោះ។ ដូច្នេះ ដូចលោកចៅក្រមបានបញ្ជាក់អ៊ីចឹងថា អង្គជំនុំជម្រះមិនអាចបើកសវនាការផង សរសេរសាលក្រមផងទេ។ អ៊ីចឹងយើងក៏ ពួកយើងក៏អ៊ីចឹងដែរ យើងមានការលំបាកដូចគ្នា យើងមិនអាចរៀបចំសវនាការផង រៀបចំការសួរសំណួរសាក្សីដើម -- អ្នកជំនាញផង ហើយក្នុងពេលដំណាលគ្នាហ្នឹងសរសេរសារណាបណ្តឹងសាទុក្ខដែលមានបញ្ហាពិបាកៗទៀតនៅក្នុងក្របខ័ណ្ឌនៃសវនាការយើងនេះ។ ដូច្នេះនេះជាចំណុចមួយដែលសំខាន់បំផុត ដែលខ្ញុំត្រូវតែលើកឡើងចំពោះអង្គជំនុំជម្រះ។

[១៤:២៦:៥៩]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ចុះភាគីដទៃទៀតមានបញ្ហាអ្វីដែលចង់លោកឡើងដែរឬទេ?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន! ចំពោះបញ្ហាសំខាន់ៗផ្សេងទៀតក្រៅពីអ្វីដែលបានលើកនេះ ខាងដើមបណ្តឹងរដ្ឋប្បវេណីពុំមានអ្វីដែលលើកឡើងទេនៅពេលនេះ។ ក៏ប៉ុន្តែគ្រាន់តែចង់សុំធ្វើការកត់សម្គាល់បន្តិចពាក់ព័ន្ធទៅនឹងពេលវេលារបស់លោក លោកស្រីចៅក្រម សម្រាប់ធ្វើការតាក់តែងសាលក្រមចាប់ផ្តើមជាដំបូងពាក់ព័ន្ធទៅនឹងអ្វីដែលលើកឡើងដោយលោកស្រី អង់តា ហ្គីសសេ។

បទពិសោធន៍ដែលយើងបានឃើញកន្លងមក គឺថានៅពេលដែលយើងមានសវនាការបណ្តើរភាគីទាំងខាងសហព្រះរាជអាជ្ញា ហើយទាំងខាងភាគីមេធាវីរបស់ជនជាប់ចោទ គាត់មានលទ្ធភាពនៅក្នុងការដាក់ពាក្យសុំផ្សេងៗច្រើនណាស់ក្នុងពេល ទន្ទឹមពេលដែលយើងមានសវនាការ។ ហើយដូច្នេះ ខ្ញុំគិតថាសវនាការមិនធ្វើជាឧបសគ្គសំខាន់ទៅដល់ភាគីនៅក្នុងការធ្វើពាក្យបណ្តឹងឧទ្ធរណ៍ទៅលើសាលក្រមករណី ០០២/០១ នោះទេ។ ប្រសិនបើចោទជាបញ្ហាពាក់ព័ន្ធក្នុងបញ្ហានេះ ខ្ញុំគិតថាភាគីអាចបង្កើនចំនួនបុគ្គលិកនៅក្នុងក្រុមមេធាវីរបស់ខ្លួន។ ខ្ញុំគិតថាដូចគ្នាដែរ ចំពោះករណីលោកលោកស្រីចៅក្រម ខាងសហព្រះរាជអាជ្ញា នៅពេលដែលយើងបានពិភាក្សាគ្នា សហព្រះរាជអាជ្ញាក៏បានលើកឡើងថានៅក្នុង

សាលាក្តីអន្តរជាតិផ្សេងៗទៀត គឺលោក លោកស្រីចៅក្រមនៅទីនោះ គឺអាចក្នុងពេលជាមួយគ្នា សរសេរសាលក្រម ហើយក៏ដំណើរការសវនាការរឿងករណីផ្សេងៗទៀតដែរ។

[១៤:២៨:៥៥]

ខ្ញុំគិតថា នៅក្នុងជីវិតវិជ្ជាជីវៈលោក លោកស្រីចៅក្រម ដូចគ្នាដែរ គឺលោក លោកស្រីចៅក្រម ដំណើរការសវនាការទៅលើករណីជាច្រើនក្នុងករណីជាមួយគ្នា ហើយក៏មានការតាក់តែង ឬក៏ចេញសេចក្តីសម្រេចអីផ្សេងៗដែរ។ ខ្ញុំគិតថា បញ្ហានេះមិនចោទជាបញ្ហាសំខាន់ចំពោះលោក លោកស្រីចៅក្រមទេ តែប្រសិនបើវាប៉ះពាល់ទៅដល់ការងារតាក់តែង ក៏ដូចដឹកនាំនៅក្នុងសវនាការទៅលើសារធាតុ ខ្ញុំគិតថា លោក លោកស្រីចៅក្រម អាចស្វែងរកឲ្យមានបុគ្គលិកបន្ថែមដើម្បីសម្រួលទៅដល់ការងាររបស់លោក លោកស្រីចៅក្រមនៅក្នុងការតាក់តែងសវនាការនេះ។ បាទសូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណច្រើន។

តើភាគីណាមានមតិយោបល់អ្វីផ្សេងទៀតទេ? គ្រាន់តែលើកឡើងបំផុស រំលេចកនូវបញ្ហាគន្លឹះ បញ្ហាចម្បងសំខាន់ៗដែលទំនងជាខាងអង្គជំនុំជម្រះនឹងមិនបានដាក់មក កំណត់ជារបៀបវារៈសម្រាប់ប្រជុំពិភាក្សានៅពេលនេះ ដើម្បីយើងខ្ញុំនឹងមានមូលដ្ឋានដើម្បីលើកទៅដាក់នៅក្នុងកិច្ចប្រជុំពិភាក្សានៅពេលលើកក្រោយៗ បន្ទាប់ពីនេះទៀត ដើម្បីឲ្យកិច្ចដំណើរការរបស់យើងទៅមុខហ្នឹង គឺបានរលូន។ យើងដោះស្រាយបញ្ហាអស់ ដែលវាមានប្រឈម។

បាទ ហើយបើសិនជាគ្មានទេ ដល់ពេលនេះ កិច្ចប្រជុំរៀបចំត្រៀមរៀបចំសវនាការរបស់យើងបានឈានដល់ទីបញ្ចប់ហើយ។ ហើយមុននឹងបិទបញ្ចប់កិច្ចពិភាក្សានេះ អង្គជំនុំជម្រះសាលាដំបូងសូមជម្រាបជូនភាគី និងសាធារណជនឲ្យបានជ្រាបថា អង្គជំនុំជម្រះសាលាដំបូងនៅតែខិតខំប្រឹងប្រែងដើម្បីធានាថា សំណុំរឿង០០២/០២ និងត្រូវយកមកជំនុំជម្រះឲ្យបានឆាប់ តាមដែលអាចធ្វើទៅបាន។ ដោយស្របទៅនឹងគោលការណ៍យុត្តិធម៌នៃការជំនុំជម្រះ និងសិទ្ធិប្រយោជន៍របស់ភាគី។

[១៤:៣១:១០]

ក្នុងនាមប្រធានអង្គជំនុំជម្រះ ខ្ញុំសូមគាំទ្រទាំងស្រុងនូវទស្សនទានទាំងឡាយដែលបានលើកឡើងដោយភាគី ដែលជំរុញឲ្យមានការចាប់ផ្តើមការជំនុំជម្រះលើសំណុំរឿង០០២/០២ ឲ្យបានឆាប់រហ័ស។ កិច្ចប្រជុំត្រៀមរៀបចំដែលបានធ្វើនេះ គឺមានគោលបំណងនេះហើយ។ បញ្ហាថ្មីសម្រាប់អង្គជំនុំជម្រះ

សាលាដំបូងដែលបានលេចឡើង ក្រោយពីអង្គជំនុំជម្រះបានកំណត់កាលបរិច្ឆេទប្រជុំរៀបចំសវនាការនេះ គឺបញ្ហាត្រង់ថា តើក្រុមប្រឹក្សាជំនុំជម្រះទី២នៃអង្គជំនុំជម្រះសាលាដំបូង គួរតែត្រូវបង្កើតឡើងដើម្បីជំនុំជម្រះលើសំណុំរឿង០០២/០២នេះ ឬមិនត្រូវបង្កើតឡើងទេ។ ប្រសិនបើអង្គជំនុំជម្រះទី២ ត្រូវបង្កើតឡើង តើកាលបរិច្ឆេទណាដែលអាចមានលទ្ធភាពចាប់ផ្តើមជំនុំជម្រះបានឆាប់បំផុតនោះ។

បញ្ហានានា ទាក់ទងនឹងនីតិវិធី និងបញ្ហាផ្លូវច្បាប់ផ្សេងៗទៀត ដែលអង្គជំនុំជម្រះមានបំណងពិនិត្យពិចារណាក្នុងកិច្ចប្រជុំនេះ នឹងលើកយកទៅពិនិត្យពិចារណានៅក្នុងកិច្ចប្រជុំត្រៀមរៀបចំសវនាការថ្មីមួយទៀត ដែលកាលបរិច្ឆេទនៃកិច្ចប្រជុំនេះនឹងត្រូវជម្រាបជូនដល់ភាគី និងសាធារណជននាពេលឆាប់ៗខាងមុខនេះ។

បាទ នេះជាការបញ្ជាក់ឲ្យបានច្បាស់លាស់អំពីកិច្ចប្រឹងប្រែងរបស់អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងការពិនិត្យលទ្ធភាពក្នុងការរៀបចំកិច្ចដំណើរការសវនាការលើសំណុំរឿង០០២/០២។

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញា ដែលជាសមាជិកសមាជិកានៃកិច្ចប្រជុំរៀបចំសវនាការនេះ ព្រមទាំងអ្នកចូលរួមក្នុងកិច្ចប្រជុំទាំងអស់ជាទីរាបអាន។ ក្នុងនាមខ្ញុំជាប្រធាន និងជំនួសមុខឲ្យចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះលទ្ធផលដែលបានសម្រេចតាមរយៈកិច្ចប្រជុំរៀបចំសវនាការលើសំណុំរឿង០០២/០២ លើកដំបូងក្នុងរយៈពេលពីរថ្ងៃមកនេះ។

[១៤:៣៣:៥០]

អង្គជំនុំជម្រះសង្កេតឃើញថា ក្នុងកិច្ចប្រជុំនេះមានការចូលរួម និងពិភាក្សាយ៉ាងផុលផុសពីសំណាក់ឯកឧត្តមប្រធាន លោកអនុប្រធាន ការិយាល័យរដ្ឋបាល សហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញារង សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីការពារក្តីលោក នួន ជា សហមេធាវីការពារក្តីលោក ខៀវ សំផន។ អង្គជំនុំជម្រះនឹងយកខ្លឹមសារ លទ្ធផលនៃកិច្ចប្រជុំពិភាក្សានេះទៅពិនិត្យពិចារណា ដោះស្រាយលើបញ្ហានានាដែលពាក់ព័ន្ធដូចដែលបានលើកឡើងនៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរៀបចំសវនាការនេះ នឹងបានពិភាក្សាពេលកន្លងមកនេះ។

អង្គជំនុំជម្រះនឹងជូនដំណឹងដល់ប្រធាន អនុប្រធានការិយាល័យរដ្ឋបាល ភាគីដែលពាក់ព័ន្ធ ព្រមទាំងសាធារណជនបានជ្រាបក្នុងពេលសមស្របខាងមុខ អំពីចំណាត់ការលើបញ្ហាទាំងនេះរបស់អង្គជំនុំ

ជម្រះសាលាដំបូង។

ក្នុងនាមខ្ញុំជាប្រធាន និងតំណាងឲ្យចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងទាំងអស់ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី សហព្រះរាជអាជ្ញា សហព្រះរាជអាជ្ញារង សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី មេធាវីការពារក្ដីឲ្យជនជាប់ចោទ មន្ត្រីបុគ្គលិកទាំងអស់នៃអង្គភាពផ្នែកចំណុះឲ្យការិយាល័យរដ្ឋបាល ផ្នែកសន្តិសុខ ផ្នែកច្បាប់ ក្រឡាបញ្ជីបុគ្គលិកនៃអង្គជំនុំជម្រះសាលាដំបូងទាំងអស់ និងអ្នកបកប្រែដែលបានចូលរួម និងខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តជួយជ្រោមជ្រែងសម្របសម្រួលដល់កិច្ចដំណើរការប្រជុំពិភាក្សានេះប្រព្រឹត្តទៅបានរលូន និងបានទទួលជោគជ័យដូចការរំពឹងទុក។

សូមជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី នាង កញ្ញាទាំងអស់ជួបតែសំណាងល្អ និងទទួលបានជោគជ័យត្រចេះត្រចង់ក្នុងការបំពេញភារកិច្ចដ៏ឧត្ដុង្គឧត្ដម នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ។ ខ្ញុំប្រកាសបិទកិច្ចប្រជុំរៀបចំសវនាការលើសវនាការសំណុំរឿង០០២/០២ លើកនេះត្រឹមនេះ។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៤:៣៦ នាទី)*